១

# កម្ពុជសុរិយា

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៤២ ខែ មករា

ព.ស. ២៥១៣ គ.ស. ១៩៧០

– ភ្នំពេញ –

១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

បេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ — ផ្នែកសាសនា — ទំព័រ


១.– និរាសនសិក្ខាបទទី ១ ក្នុងសេក្ខិយវត្ត ព្រះរាជនិពន្ធន៍នៃសម្ដេចព្រះសង្ឃរាជ (ជ.ណ.) ជោតញ្ញាណោ . . . . . ១

២– រឿងសង្ខិប្តសង្គ្រាមលោក លោក ប៊ូ-ប៉ូ ប្រែរៀបរៀង . . . . ១៣


## ផ្នែកអក្សរសាស្ត្រ


៣– វិបនានុប្រមស់ស្ត្រីខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង. . . ៣១

៤– រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . ៣៤

៥– រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ អ្នកស្រីពេជ-សល់ ប្រែរៀបរៀង . . ៥០

៦– ល្បើកសីលប្រាំ ឧកញ៉ាព្រះឃ្លាំងនង រៀបរៀង សហ លី-ធាមតេង បម្លងផ្ទៀងផ្ទាត់ . . . . . . . . . ៦៧

៧– រឿងខ្ញី ១ មានន័យវែង សហ. ផល-ទិត នៅក្រុមជំនុំព្រះត្រៃបិដករៀបរៀង ៨០

## ផ្នែកកំណត់-ប្រវត្តិការណ៍


៨— លទ្ធផលនៃការប្រឡងប្រជែងឯកសារទំនៀមទម្លាប់ ឆមាសទី ២ ឆ្នាំ ១៩៦៩ និង សេចក្តីប្រកាសប្រឡងដូចគ្នានេះ សម្រាប់ឆមាសទី ១ នៃឆ្នាំ ១៩៧០ ៩៦

៩— អនុសំវច្ឆរៈ មហាសន្និបាតលើកទី ២៦ នៃមន្ត្រីសង្ឃ . . . ១០៦


មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ០០ ៛

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមួយ ឲ្យធ្វើល្អទៅ,
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា ។

ក. ព

# និទានសិក្ខាបទទី ១ ក្នុងសេខិយវត្ត

(បរិមណ្ឌលំ និវាសេស្សាមីតិ សិក្ខា ករណីយា)

រាជនិពន្ធ នៃសម្ដេចព្រះសង្ឃរាជ

ជួន-ណាត (ជោតញ្ញាណោ)

---

សម័យមួយនោះ ពួកឆព្វគ្គិយភិក្ខុ ស្លៀកស្បង់ខ្ជីខ្ជាផ្សេង ៗ តាមទំនើងកល់រូប, ស្លៀកដូចពួកគ្រហស្ថ ដែលគេស្លៀកតាមទម្លាប់របស់គេ គឺអ្នកខ្លះស្លៀកបែបនេះ អ្នកខ្លះស្លៀកបែបនោះ, ព្រះភគវ័តបរមសាស្ដា ទ្រង់ជ្រាបហើយ ទ្រង់បញ្ញត្តហាមមិនឲ្យស្លៀកស្បង់បែបនោះ ៗ ពុទ្ធប្បញត្តិមិនឲ្យភិក្ខុស្លៀកដូចគ្រហស្ថនោះ ដូចបែបស្លៀកខាងក្រោមនេះ ៖

១- ហត្ថិសោណ្ឌកៈ ស្លៀកបែបស្រដៀងនឹងសណ្ឋានប្រមោយដំរី គឺស្លៀកមូរប្រមូលសាច់ស្បង់ខាងមុខ តាំងពីមុខគល់ផ្ចិតសំយុង

ស្លួលចុះមកខាងក្រោម ស្រដៀងនឹងប្រមោយដំរី, បែបដូចសម្លៀករបស់ពួកស្ត្រីនៅក្នុងចោឡរដ្ឋ ។

២- មច្ឆវាលកា: ស្លៀកឲ្យសំពត់កែកកំពាងស្រដៀងនឹងកន្ទុយត្រី គឺស្លៀកឲ្យសាច់សំពត់ម្ខាងជាជាយ ម្ខាងទៀតជាបែបអន្ទាក់កែកកំពាងចុះក្រោម ។

៣- ចតុក្កណ្ណកា: ស្លៀកឲ្យមានមុំបួន គឺស្លៀកឲ្យប៉ែកខាងលើមានមុំ ២ ប៉ែកខាងក្រោមមានមុំ ២ ជាបួនមុំ ។

៤- តាលបណ្ណកា: ស្លៀកឲ្យសំពត់មានសណ្ឋានស្រដៀងនឹងកំពូលស្លឹកត្នោត គឺស្លៀកសម្ពុយ ឲ្យសំណុំរមូរសំពត់មានអាការៈដូចស្រួចខាងចុង ស្រដៀងនឹងកំពូលស្លឹកត្នោត ។

៥- សតវល្លិកា: ស្លៀកបំពេនច្រើនស្រទាប់ គឺស្លៀកបំពេនផ្នត់សំពត់ច្រើនស្រទាប់ ដូចបែបរន្ធើលឬស្រទប ព័ទ្ធពីខាងឆ្វេងមកខាងស្តាំច្រើនផ្នត់ (ត្រង់ការស្លៀកបែបនេះ, អដ្ឋកថាប្រាប់ថា បើស្លៀកឲ្យមានផ្នត់ស្បង់តាំងពីជង្គង់ឡើងមក ត្រឹមតែមួយផ្នត់ពីរផ្នត់បាន, មិនត្រូវអាបត្តិទុក្កដទេ; បើសាមណេរ ក៏មិនត្រូវទណ្ឌកម្មឡើយ) ។

៦- សំវេល្លិយ: ស្លៀកចងក្បៀន ។ អដ្ឋកថាបញ្ជាក់ថា ពោះបើភិក្ខុមានជំងឺក្ដី ភិក្ខុដើរតាមផ្លូវ (ឥតមានភូមិស្រុក) ក្ដី ពុំត្រូវស្លៀកចងក្បៀនឡើយ ។ មួយទៀតថា ភិក្ខុដើរតាមផ្លូវ (ឥតមានស្រុកភូមិ)

ហើយមុំ ឬ ជាយស្បង់ខាងក្តី តាំងពីខាងក្តី យកមកសៀតញាត់ត្រង់ចង្កេះ, ឬភិក្ខុស្លៀកពីរជាន់, ហើយស្បង់មួយជាន់ ខាងក្នុងក្តី ខាងក្រៅក្តី កន្ទើញយកមកសៀតញាត់ត្រង់ចង្កេះក្តី កាន់ជាប់នឹងដៃហើយកន្ទើញឡើងក្តី, បែបស្លៀកទាំងអស់នេះ ពុំគួរឡើយ ព្រោះសុទ្ធតែជាអាការៈនៃអាបត្តិទុក្កដ (បើសាមណេរ ត្រូវទណ្ឌកម្ម) ។

ភិក្ខុក្តី សាមណេរក្តី ត្រូវវៀរជាខ្ទិច នូវការស្លៀកជាគិហិនិវាសនៈ តាំងនេះ និងបែបស្លៀកដទៃក្រៅពីនេះ ទោះបែបណាក៏ដោយ ដែលផ្សេងពីការស្លៀកជាបរិមណ្ឌល ដូចបានពោលខាងលើរួចមកហើយនោះ, ត្រូវស្លៀកឲ្យជាបរិមណ្ឌលគ្រប់ពេល ទើបសមជាសមណៈសមរម្យក្នុងព្រះពុទ្ធសាសនា គួរជាទីជ្រះថ្លាពេញចិត្តខ្លួនឯងនិងអ្នកដទៃ ។

## អំពីការស្លៀកពីរជាន់

ក្នុងគម្ពីរកង្ខាវិតរណីប្រាប់ថា អត្តលាភេន ទ្វេ និវាសេន្តេន សគុណំ កត្វា និវាសេតព្វំ ភិក្ខុមិនមានជំងឺ កាលបើត្រូវការស្លៀកពីរជាន់ ត្រូវតម្រួតកាសាវពស្ត្រជាពីរជាន់ស្លៀកបាន ។ គម្ពីរកង្ខាយោជនាមហាដីកានៃកង្ខាវិតរណី បញ្ជាក់ថា សគុណំ កត្វាតិ អហតកាសាវេ ពហិកាសាវំ សហាឧបដលំ កត្វា ត្រង់ពាក្យថា ឲ្យតម្រួតកាសាវពស្ត្រជាពីរជាន់នោះ គឺឲ្យ

ធ្វើកាសាវព័ស្ត្រខាងក្រៅ ជាមួយនឹងកាសាវព័ស្ត្រខាងក្នុង ឲ្យមានផ្ទៃសំពត់ស្មើគ្នា គឺកុំស្លៀកឲ្យលៀនសាប់សំពត់ខាងក្នុងចេញមកខាងក្រៅឡើយ ។ បញ្ជាក់ឲ្យដឹងថា ស្លៀក ២ ជាន់បាន ប៉ុន្តែត្រូវស្លៀកស្បង់តែសំពត់ផ្សេលក់ពណ៌អម្ចត់ទាំង ២ ដូចគ្នា កុំស្លៀកសំពត់ឥតពណ៌អម្ចត់ឡើយ, ទោះបីខាងក្នុងជាសំពត់សាដក ក៏ត្រូវផ្សេលក់ឲ្យមានពណ៌អម្ចត់ដូចគ្នាដែរ ។

អនាបត្តិ គឺការមិនត្រូវអាបត្តិក្នុងនិរសេនសិក្ខាបទទី ១ មាន ៦ គឺ អសញ្ចិច្ច មិនក្លែង ១ អសតិយា ដោយមិនមានស្មារតី ១ អជានន្តស្ស ភិក្ខុល្ងង់មិនទាន់ចេះស្លៀក ១ គិលានស្ស ភិក្ខុមានជំងឺ ១ អាបទាសុ ក្នុងកាលមានភយន្តរាយ ១ ឧម្មត្តកាទិនញ្ច ភិក្ខុទាំងឡាយ ដែលមានហេតុមិនគួរត្រូវអាបត្តិ មានភិក្ខុវិកលចរិតជាដើម ១ ។ ត្រង់ អជានន្តស្ស ដែលថាភិក្ខុល្ងង់មិនទាន់ចេះស្លៀកនោះ លោកប្រាប់ថា ត្រូវតែខំប្រឹងរៀនឲ្យចេះស្លៀកឡើង ។

មួយទៀត, ភិក្ខុ ដែលមានជើងកំពួកក្តី មានពកដើបដុបនៅជើងក្តី មានជើងស្អុកទ្រើងក្តី បើស្លៀកសម្ពុយឲ្យស្រុងចុះជាង ៨ ធ្នាប់ក៏បាន ។ ភិក្ខុមានដំបៅត្រង់ស្មងក្តី ត្រង់កជើងក្តី អាចស្លៀកបន្ទើចឬស្លៀកឲ្យស្រុយចុះក្រោមក៏បាន តាមគួរដល់ការសម្រួលកាយ ។ល។

# បារុបនសិក្ខាបទទី ២

(បរិមណ្ឌលំ បារុបិស្សាមីតិ សិក្ខា ករណីយា)

គ្រង់បារុបនសិក្ខាបទទី ២ ក្នុងបរិមណ្ឌលវគ្គ ថា បរិមណ្ឌលំ បារុបិស្សាមីតិ សិក្ខា ករណីយា នេះ គម្ពីរកង្ខាវិតរណី-អដ្ឋកថាបាតិមោក្ខ ប្រាប់សេចក្តីពិស្តារថា ព្រះសម្ពុទ្ធទ្រង់បញ្ញត្តហាមថា ន ភិក្ខវេ គិហិបារុតំ បារុបិតព្វំ, យោ បារុបេយ្យ អាបត្តិ ទុក្កដស្ស ម្នាលភិក្ខុទាំងឡាយ, ភិក្ខុមិនត្រូវដណ្តប់ឬគ្រងចីវរដូចគ្រហស្ថឡើយ, ភិក្ខុណាដណ្តប់ឬគ្រងដូចគ្រហស្ថ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

ព្រោះហេតុនោះ, ការមិនដណ្តប់ ឬមិនគ្រងបែបគ្រហស្ថដែលទ្រង់ហាមយ៉ាងនោះ, ដណ្តប់ឬគ្រងធ្វើជាយទាំង ២ ឲ្យស្មើគ្នា ឈ្មោះថាការដណ្តប់ឬគ្រងជាបរិមណ្ឌល គឺដណ្តប់ឬគ្រងត្រឹមត្រូវ ។

ការដណ្តប់ឬគ្រងដូចគ្រហស្ថនោះ មានបែបយ៉ាងនេះជាដើមគឺ

១– សេតបដបារុបនៈ ដណ្តប់ឬគ្រងសំពត់ស ដូចជាអឡ្យ-ផលកនិគ្រន្ថ គឺនិគ្រន្ថដែលដណ្តប់សំពត់ស តែត្រឹមពាក់កណ្តាលខ្លួន ។

២– បរិព្វាជកបារុបនៈ ដណ្តប់ឬគ្រងដូចពួកបរិព្វាជក គឺដូចបរិព្វាជកមួយពួក ដណ្តប់សំពត់បើកចំហទ្រូង បង់សំពត់ដណ្តប់លើចង្ងយស្មាទាំង ២ ខាង ។

៣ – ឯកសាដកបារុបនៈ ដណ្ដប់ឬគ្រងដូចឯកសាដកមនុស្ស គឺពួកមនុស្សដែលមានតែសាដកមួយ ស្លៀកផង ដណ្ដប់ផង, គេយកជាយម្ខាងនៃសាដកដែលគេស្លៀកនោះដណ្ដប់ខ្លួន, គេលើកជាយទាំង ២ បង់លើចង្កួយស្មាទាំង ២ ខាង ។

៤ – សុរាសោណ្ឌកបារុបនៈ ដណ្ដប់ឬគ្រង ដូចមនុស្សប្រមឹក គឺដូចពួកមនុស្សប្រមឹកជាដើម ដែលដណ្ដប់សាដករុំកសំយុងជាយទាំង ២ មកលើពោះ ឬបោះជាយទាំង ២ នោះគ្រវាត់ពីទ្រូងទៅលើខ្លួន ។

៥ អន្តេបុរិកបារុបនៈ ដណ្ដប់ឬគ្រងដូចបែបពួកស្រីអ្នកបុរី គឺដូចពួកស្រីអ្នកក្រុងជាដើម ដែលដណ្ដប់ទទូរក្បាលជិត ទុកឲ្យសល់តែប្រឡង់ភ្នែក ។

៦ – មហាជេដ្ឋកបារុបនៈ ដណ្ដប់ឬគ្រងដូចមហាជេដ្ឋកមនុស្ស គឺដូចពួកមេជាងឈើធំ ៗ ដែលស្លៀកសាដកវែង ដណ្ដប់សរីរកាយទាំងមូល ដោយចុងជាយម្ខាង នៃសាដកខ្លួនស្លៀកនោះឯង ។

៧ – កុដិប្បវេសកបារុបនៈ ដណ្ដប់ឬគ្រងដូចជាកសិករ គឺអ្នកធ្វើស្រែ ឬអ្នកធ្វើចម្ការ ៗ ឯពួកកសិករដែលគេចូលទៅកខ្ទមស្រែ ឬខ្ទមចម្ការ គេច្រើនតែចាប់ក្រសោបសាដកហើយញាត់ទៅក្នុងក្លៀក រួចគេដណ្ដប់សរីរកាយ ដោយចុងម្ខាងនៃសាដកនោះឯង ។

៨- ព្រាហ្មណបារុបនៈ ដណ្តប់ឬគ្រងដូចពួកព្រាហ្មណ៍ គឺដូចពួកព្រាហ្មណ៍ដែលញាត់សាដកទៅតាមចន្លោះគុម្ពក្លៀកទាំង ២ ហើយលើកដាក់លើចង្កយស្មាទាំង ២ ។

៩- បាលិការកបារុបនៈ ដណ្តប់ឬគ្រងដូចបាលិការក-ភិក្ខុ គឺដូចភិក្ខុអ្នករៀបឲ្យពួកបព្វជិតផងគ្នាអង្គុយ ឬឈរតាមលំដាប់លំ-ដោយ, ឯភិក្ខុអ្នកចាត់របៀបនោះ តែងតែបើកចំហដើមដៃខាងឆ្វេងដែលខ្លួនគ្រងស្មាម្ខាង ហើយសើយចីវរដាក់លើស្មាម្ខាងទៀត គឺគ្រងចីវរគ្រ-វាត់គ្រវែងឲ្យមាំ កុំឲ្យធ្លាក់រយីករយាក ។

(បើធៀបតាមសម័យយើងសព្វថ្ងៃនេះ, ដែលធ្លាប់បានឃើញភិក្ខុឬសាមណេរបួខ្លះ បង់កចីវរដែលរំកាញ់ឬដែលចាប់ប្រមូលក្រសោបដាក់លើស្មាឆ្វេង ឬ ជួនកាលដាក់លើស្មាស្តាំ សំយុងផ្តត់ចំពរទៅខាងមុខនិងខាងក្រោយ ដូចជាគ្រហស្ថបង់កសំពត់ខ្លូតឬក្រមានោះ ក៏ជា គិហិបា-រុបនៈ "ដណ្តប់ដូចគ្រហស្ថដែរ" ជាទំនាស់នឹងព្រះពុទ្ធបញ្ញត្តិ ដែលបានពោលមករួចហើយថា ន ភិក្ខវេ គិហិបារុតំ បារុបិតព្វំ, យោ បារុបេយ្យ អាបត្តិ ទុក្កដស្ស នោះឯង) ។

អដ្ឋកថាឈ្មោះកង្ខាវិតរណី ប្រាប់ថា បព្វជិតមិនត្រូវគ្រងចីវរបែបគ្រហស្ថ ដែលបានពោលរៀបរាប់ខាងលើហើយនោះឡើយ, ត្រូវគ្រងឲ្យជាបរិមណ្ឌលត្រឹមត្រូវជាដរាប, បើមិនអើពើ មិនយកចិត្តទុកដាក់ ត្រូវ

អនាទរទុក្កដ, បើសាមណេរ ត្រូវទណ្ឌកម្ម ហៅថាអនាទរទណ្ឌកម្ម ។ ព្រោះហេតុនោះ តាំងភិក្ខុតាំងសាមណេរ ត្រូវសិក្សាថា បរិមណ្ឌលំ និវាសេស្សាមិ, បរិមណ្ឌលំ បារុបិស្សាមិ អាត្មាអញនឹង ស្លៀកស្បង់ ឲ្យជាបរិមណ្ឌល, នឹងគ្រងចីពរ ឲ្យជាបរិមណ្ឌល គឺឲ្យ ត្រឹមត្រូវជាសមណសារុប: " ។

កង្ខាវិតរណី ប្រាប់បញ្ជាក់ថា អារាមេ វា អន្តរឃរេ វា ទោះក្នុងវត្តក្តី ទោះក្នុងភូមិក្តី ត្រូវតែប្រតិបត្តិឲ្យជាបរិមណ្ឌលជាដរាប ។

## សុប្បដិច្ឆន្នសិក្ខាបទទី ៣

[សុប្បដិច្ឆន្នោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា]

កង្ខាវិតរណីអដ្ឋកថា ប្រាប់សេចក្តីថា សុប្បដិច្ឆន្នោតិ សុដ្ឋុ បដិច្ឆន្នោ ។ គ្រង់ពាក្យថា "បិទបាំងកងកាយដោយប្រពៃ គឺបិទបាំងកងកាយដោយត្រឹមត្រូវ" គឺឃុំចីវរ ។ កណ្ឋកំ បដិមុញ្ចិត្វា អនុវាតន្តេន គីវំ បដិច្ឆាទេត្វា ឧភោ កណ្ណេ សមំ កត្វា បដិសំហរិត្វា យាវ មណិពន្ធំ បដិច្ឆាទេត្វា អន្តរឃរេ គមិស្សាមីតិ អាភោគោ ។ សេចក្តីពន្យល់ថា "អាត្មាអញ នឹងពាក់ក្ដុំ បិទបាំងករដោយទីបំផុតនៃអនុវាត ធ្វើជាយទាំងពីរ

ឲ្យស្និតគ្នា ហើយមូរបិទបាំងត្រឹមកដៃ ដើរក្នុងចន្លោះផ្ទះ" ។ តថា អកត្វា បន ជាណុំ វា ខនំ វា វិវរិត្វា គច្ឆន្តស្ស ទុក្កដំ បើភិក្ខុមិនធ្វើដូច្នោះទេ កំពុងដើរ បើកជង្គង់ក្តី ពោះក្តី ត្រូវអាបត្តិទុក្កដ ។

## សុប្បដិច្ឆន្នសិក្ខាបទទី៤

(សុប្បដិច្ឆន្នោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា)

ក្នុងវិតរណី អដ្ឋកថា ប្រាប់សេចក្តីថា គលវាតកាតោ បដ្ឋាយ សីសំ, មណិពន្ធតោ បដ្ឋាយ ហត្ថេ, បិណ្ឌិកមំសតោ បដ្ឋាយ បាទេ វិវរិត្វា; សេសំ ឆាទេត្វា និសិន្នោ សុប្បដិច្ឆន្នោ នាម ហោតិ ដែលឈ្មោះថា ភិក្ខុឃ្លុំត្រឹមត្រូវអង្គុយ ខាងសីសៈ ត្រូវបើកពីត្រឹមគល់កមក, ខាងដៃទាំងពីរ ពីត្រឹមកដៃមក, ខាងជើងទាំងពីរ ពីត្រឹមកំភួនជើងមក, ឯសរីរាវយវៈក្រៅពីនោះ ត្រូវបិទបាំងឲ្យជិតទាំងអស់ ។ ឯត្ថ បន វាសុបគតស្ស អនាបត្តិ ក្នុងសិក្ខាបទនេះ ភិក្ខុអ្នកចូលកាន់លំនៅ ជាអនាបត្តិ គឺមិនត្រូវអាបត្តិឡើយ ។

# រឿងព្រះមហាអានន្ទឃ្លុំចីវរ

ក្នុងសម័យមួយ, ព្រះមហាអានន្ទ ឃ្លុំសង្ឃាដីនិងឧត្តរាសង្គៈដែលតម្រួតគ្នាជាពីរ ចូលទៅបិណ្ឌបាតក្នុងភូមិ, ខ្យល់កំបុតត្បូងធំ បក់បំប៉ើងសង្ឃាដីនិងឧត្តរាសង្គៈនោះ ឡេះឧមុខប្រហើឡើង ។ លុះព្រះមហាអា-នន្ទត្រឡប់មកអារាមវិញ ក៏តំណាលប្រាប់ពួកភិក្ខុ ។ ពួកភិក្ខុក្រាបទូលព្រះសម្មាសម្ពុទ្ធ អំពីរឿងនោះ ។ ព្រះភគវ័តទ្រង់អនុញ្ញាតថា អនុជា-នាមិ ភិក្ខវេ គណ្ឋិកំ បាសកំ ម្នាលភិក្ខុទាំងឡាយ, អញតថាគតអនុញ្ញាត នូវឡេវក្ដុំនិងអន្ទាក់ឡេវ ។ ពួកឆព្វគ្គិយភិក្ខុ ធ្វើឡេវក្ដុំផ្សេង ៗ មានឡេវមាស ឡេវប្រាក់ជាដើម តាមចំណង់ចិត្តរៀង ៗ ខ្លួន ។ ព្រះភគវ័ត ទ្រង់ហាម ហើយទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ គណ្ឋិកំ អដ្ឋិមយំ ទន្តមយំ វិសាណមយំ នឡមយំ វេឡុមយំ កដ្ឋមយំ ជតុមយំ ផលមយំ លោហ-មយំ សង្ខនាភិមយំ សុត្តមយំ ម្នាលភិក្ខុទាំងឡាយ អញតថាគតអនុញ្ញាតនូវឡេវក្ដុំ ដែលធ្វើដោយឆ្អឹង, ដោយភ្លុក, ដោយស្នែង, ដោយបបុស, ដោយឫស្សី, ដោយឈើ, ដោយជ័រឈើ, ដោយផ្លែឈើ, ដោយលោហៈ, ដោយគ្រូចស័ង្ខ, ដោយសូត្រឬអំបោះ ។ ភិក្ខុទាំងឡាយដេរភ្ជាប់ឡេវនិងអន្ទាក់ឡេវក្ដុំ នាផ្ទៃចីវរ ។ ចីវរក៏រហែក

ដាច់ ៗ ព្រះភគវ័តទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ គណ្ឋិកាផលកំ ។ បាសកាផលកំ ម្នាលភិក្ខុទាំងឡាយ, អញ្ញតថាគតអនុញ្ញាត នូវទ្រនាប់ឡេវ និងទ្រនាប់អន្ទាក់ឡេវក្តី ៗ ពួកភិក្ខុដេរភ្ជាប់ទ្រនាប់ឡេវ និងទ្រនាប់អន្ទាក់ឡេវក្តីត្រង់ទីបំផុត គឺត្រង់មុំជាយ ឬត្រង់ចុងរំមជាយចីវរ ៗ មុំជាយចីវរបេះតែរបើក គឺរបេដាច់ត្រង់មុំនោះ ៗ ព្រះភគវ័តទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ គណ្ឋិកាផលកំ អន្តេ អប្បេតុំ បាសកាផលកំ សត្តង្គុលំ វា អដ្ឋង្គុលំ វា ឱគាហេត្វា អប្បេតុំ ម្នាលភិក្ខុទាំងឡាយ, អញ្ញតថាគត អនុញ្ញាតឲ្យភិក្ខុ ដេរភ្ជាប់សំពត់ទ្រនាប់ឡេវក្តី ត្រង់ទីបំផុតនៃចីវរ, ដេរភ្ជាប់សំពត់ទ្រនាប់អន្ទាក់ឡេវក្តី បន្ថយចូលមកខាងក្នុងត្រឹម ៧ ធ្នាប់ ឬ ៨ ធ្នាប់ ៗ

ព្រះពុទ្ធានុញ្ញាតនេះ មានក្នុងគម្ពីរវិនយបិដក ត្រង់ខន្ធកវត្តក្ខន្ធកៈ ជាអនុញ្ញាតចុងក្រោយបង្អស់ ៗ

## សេចក្តីបញ្ជាក់អំពីព្រះប្រារព្ធ

បណ្តាសេខិយវត្តទាំង ៧៥ នេះ, សិក្ខាបទ គឺ សុរុសុរុសិក្ខាបទមួយនេះ ព្រះភគវ័តទ្រង់ព្រះប្រារព្ធចំពោះពួកភិក្ខុ នាក្រុងកោសម្ពី; សាមិសហត្ថបានីយសិក្ខាបទ និង សសិត្ថកបត្តធោវនសិក្ខា ។ ទាំងពីរនេះ

ទ្រង់ព្រះបញ្ញត្តចំពោះពួកភិក្ខុច្រើនរូប នាភគ្គនគរ; ឯ ៧២ សិក្ខាបទក្រៅពីនោះ ទ្រង់ព្រះបញ្ញត្តចំពោះឆព្វគ្គិយភិក្ខុ នាក្រុងសាវត្ថី ។ ភិក្ខុប្រព្រឹត្តល្មើសកន្លងសេខិយសិក្ខាបទទាំង ៧៥ នេះ ត្រង់សិក្ខាបទណាមួយ សុទ្ធតែត្រូវអាបត្តិទុក្កដដូចគ្នា ហៅថា អនាទរទុក្កដ គឺទុក្កដាបត្តិដែលភិក្ខុត្រូវ ព្រោះការមិនអើពើ, បើសាមណេរប្រព្រឹត្តកន្លង ត្រូវទណ្ឌកម្ម ហៅថា ទណ្ឌកម្មនាសនា ជាអនាទរទណ្ឌកម្ម ។

(កង្ខាវិតរណី អដ្ឋកថាបាតិមោក្ខ)

ចប់

ថ្ងៃព្រហស្បតិ៍ ទី ៣ សីហា ២៥១០/១៩៦៧

សម្តេចព្រះសង្ឃរាជ ជ.ណ. ជោតញ្ញាណោ

បានដកស្រង់វិន័យនេះ ពីកង្ខាវិតរណី អដ្ឋកថាបាតិមោក្ខ ។

# រឿងសង្កិច្ចសាមណេរ

## អដ្ឋកថាធម្មបទ សហស្សវគ្គទី ៨ ភាគទី ៤

លោក ប៊ិ-ប៊ូ ប្រែរៀបរៀង

---

កាលព្រះបរមសាស្តាជាម្ចាស់ គង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនឹងសង្កិច្ចសាមណេរ (ឲ្យជាហេតុ) ទ្រង់សម្តែងធម៌ដោយបទគាថាថា ៖ យោ ច វស្សសតំ ជីវេ ដូច្នេះជាដើម ។

កិរ បានឮមកថា មានកុលបុត្រក្នុងក្រុងសាវត្ថីប្រមាណ ៣០ នាក់ បានស្តាប់ធម្មកថា ហើយ លះបង់ជីវិតក្នុងព្រះពុទ្ធសាសនា ទៅបួសព្រមគ្នាទាំងអស់ លុះឧបសម្បទបាន ៥ វស្សា ក៏ចូលទៅគាល់ព្រះសាស្តា បានស្តាប់ធុរៈ ២ យ៉ាង គឺ គន្ថធុរៈ និងវិបស្សនាធុរៈ មិនធ្វើឧស្សាហ៍ក្នុង គន្ថធុរៈ ទេ ព្រោះខ្លួនបួសក្នុងពេលដែលវ័យចាស់ ហើយប្រាថ្នានឹងបំពេញវិបស្សនាធុរៈប៉ុណ្ណោះ ទើបក្រាបទូលព្រះសាស្តា ឲ្យទ្រង់ត្រាស់ប្រាប់កម្មដ្ឋាន រហូតដល់ព្រះអរហត្តហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ! ពួកខ្ញុំព្រះអង្គ នឹងទៅកាន់ព្រៃជាទីនៅមួយកន្លែង ។ ព្រះសាស្តាទ្រង់ត្រាស់សួរថា នឹងទៅទីណា កាលភិក្ខុពួកនោះក្រាបទូលសេចក្តីហើយ ទ្រង់ជ្រាបថា ក្នុងព្រៃនោះភ័យនឹងកើតមានដល់ភិក្ខុពួកនេះ ព្រោះអាស្រ័យអ្នកអ្នកវិឃាសាទម្នាក់ ប៉ុន្តែបើ សង្កិច្ចសាមណេរ ទៅជាមួយផង ភ័យនោះនឹងស្ងប់បាត់ទៅបាន, កាលបើដូច្នោះ

កិច្ចបព្វជិតរបស់ពួកគិត្ខុនេះ ទើបបានសម្រេចពេញទី ។

សាមណេររបស់ព្រះ-សារីបុត្តត្ថេរ ពប់តាំងអំពីកើតមកអាយុបាន ៧ ខួប ឈ្មោះថា សង្កិច្ចសាមណេរ ។ បានឮថា មាតារបស់លោក ជាធីតានៃត្រកូលសុកសម្បូរ នៅក្នុងក្រុងសាវត្ថី ។ កាលលោកនៅក្នុងផ្ទៃ មាតាបានធ្វើមរណកាល ព្រោះកេតម្យ៉ាងក្នុងកាលមួយរំពេច ។

កាលដែលគេយកទៅបូជា សរីរៈរបស់ដទៃឆេះអស់ នៅសល់តែត្រង់ផ្ទៃមិនព្រមឆេះសោះ ។

លំដាប់នោះ ជនទាំងឡាយ ទើបយកសាច់ផ្ទៃចុះចេញពីជើងថ្ករមក ហើយចាក់ទិងដែកស្រួចពីរបីកន្លែង ។ ចុងដែកស្រួច បានទៅប៉ះត្រូវកន្ទុយភ្នែកក្មេង ។

លុះចាក់សាច់ផ្ទៃយ៉ាងនេះរួចហើយ គេបោះចូលទៅក្នុងគំនររងើកភ្លើង យករងើកភ្លើងនោះឯងគ្របទុកជិត ហើយនាំគ្នាត្រឡប់ទៅផ្ទះវិញ ។ សាច់ត្រង់ផ្ទៃឆេះសុះអស់ហើយ ។ ចំណែកក្មេង ដូចរូបពុម្ពមាស បានប្រាកដនៅលើរងើកភ្លើង ដូចជាដេកក្នុងគ្របកផ្កាឈូក ។ ព្រោះជាសត្វដែលកើតមកក្នុងភពជាទីបំផុត សូម្បីត្រូវភ្នំសិនេរុសង្កត់ បើមិនទាន់បានសម្រេចព្រះអរហត្តទេ ទើងមិនអស់ជីវិតឡើយ ។ ដល់ព្រឹកឡើង ជនទាំងឡាយនាំគ្នាមកដោយប្រាថ្នានឹងលត់ភ្លើង ស្រាប់តែបានឃើញកូនក្មេង

ដេកនៅស្តូកដូច្នោះ កើតអស្ចារ្យក្នុងចិត្តថា កាលបើសរីរៈទាំងអស់នេះក្នុងឧសប៉ុណ្ណោះ ចុះព្រោះហេតុអ្វី បានជាកូនក្មេងមិនឆេះ នឹងមានហេតុអ្វីអេះ ទើបបីក្មេងនាំយកទៅក្នុងស្រុក ហើយសួរគ្រូហោរាអ្នកទាយ ៗ គ្រូហោរទាយថា បើក្មេងនេះ នៅគ្រប់គ្រងផ្ទះ ពួកញាតិនឹងមិនទាល់ក្រលំបាករហូតដល់ ៧ ជួរត្រកូល, បើបួស នឹងមានសមណៈប្រាំរយចោមរោមទៅ ៗ ព្រោះតែចុងដែកស្រួច ប៉ះត្រូវកន្ទុយភ្នែកក្មេងនោះបែក បានជាគេសន្មតនាមថា "សង្កិច្ចៈ" ដោយសម័យដទៃទៀត គេនឹងស្គាល់គ្រប់គ្នាថា សង្កិច្ចកុមារ ៗ ពួកញាតិចិញ្ចឹមទុកដោយតាំងចិត្តថា ភ្នែកបែកក៏បែកចុះ ក្នុងវេលាចម្រើនវ័យធំឡើង នឹងឱ្យបួសក្នុងសម្នាក់ព្រះសារីបុត្ត ជាម្ចាស់របស់ពួកយើង ៗ សង្កិច្ចកុមារនោះ ក្នុងវេលាមានអាយុ ៧ ខួប បានឮពាក្យសម្តីរបស់ពួកក្មេងៗប្រាប់ថា "ម៉ែរបស់ឯង ស្លាប់ពេលបាត់ក្នុងវេលាឯងនៅក្នុងផ្ទៃនៅឡើយ សូម្បីកាលគេដុតកំសពរបស់មាតាឯងមិនឆេះទេ", ឮដូច្នេះហើយ ក៏ប្រាប់ដល់ពួកញាតិថា គេថាខ្ញុំផុតពីភ័យបែបយ៉ាងនេះ ខ្ញុំមិនត្រូវការនឹងផ្ទះទេ មុខជានឹងបួសមិនខានឡើយ ៗ ពួកញាតិឆ្លើយថា ប្រពៃណាស់កូន! ទើបនាំទៅកាន់សម្នាក់ព្រះសារីបុត្តត្ថេរ ប្រគល់ថ្វាយដោយពាក្យថា សូមលោកម្ចាស់ឱ្យក្មេងនេះបួសចុះព្រះករុណា ៗ ព្រះថេរៈប្រាប់តចបញ្ចកា-

កម្មដ្ឋាន ហើយឲ្យបួស ។ សាមណេរនោះ បានសម្រេចព្រះអរហត្ត ព្រមទាំង បដិសម្ភិទា ក្នុងវេលាគ្រាន់តែកោរសក់រួចស្រេច ។ នេះ ឈ្មោះ សង្កិច្ចសាមណេរ ។

ព្រះបរមសាស្តាទ្រង់ជ្រាបថា "កាលបើសង្កិច្ចសាមណេរនេះ ទៅជាមួយផង ភ័យនោះនឹងស្ងប់បាត់ ខាងក្រោយ កិច្ចបព្វជិតរបស់ភិក្ខុពួកនេះ នឹងបានសម្រេចពេញទី" ទ្រង់ជ្រាបដូច្នេះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ! ចូរទៅលាសារីបុត្ត បងប្រុសរបស់ពួកអ្នកផង ហើយសឹមទៅចុះ" ។ ភិក្ខុពួកនោះ ទូលទទួលព្រះពុទ្ធដីកាហើយ ក៏ទៅកាន់សម្នាក់ព្រះថេរៈ, កាលលោកសួរថា "មកមានកិច្ចធុរៈអ្វី ?", ភិក្ខុទាំងឡាយទូលថា "ពួកខ្ញុំរៀនកម្មដ្ឋាន ក្នុងសម្នាក់ព្រះសាស្តា ហើយប្រាថ្នាថានឹងចូលទៅនៅក្នុងព្រៃ ក៏នាំគ្នាចូលមកលាដើម្បីទៅ, ខណៈនោះ ព្រះសាស្តាទ្រង់ត្រាស់នឹងពួកខ្ញុំយ៉ាងនេះថា ចូរលាបងប្រុសរបស់ពួកអ្នកហើយសឹមទៅចុះ ព្រោះដូច្នោះ បានជាពួកខ្ញុំមកក្នុងទីនេះ ។ ព្រះថេរៈនឹកថា "ប្រហែលជាព្រះសាស្តានឹងទ្រង់ឃើញហេតុម្យ៉ាង បានជាបញ្ជូនភិក្ខុពួកនេះមកទីនេះ, នេះមានរឿងអ្វីអេះ !" ជ្រាបសេចក្តីនោះហើយទើបប្រាប់ថា "ចុះសាមណេររបស់ពួកអ្នក មានដែរឬទេ ?" ។

គ្មានទេ ព្រះករុណា ។ បើគ្មាន ចូរយក សង្កិច្ចសាមណេរ នេះទៅ ។ ណ្ហើយមិនបាច់ទេភន្តេប្រោស ! សេចក្តីចាប់ជំពាក់ចិត្តនឹង

មានដល់ពួកខ្ញុំ ព្រោះតែអាស្រ័យសាមណេរ, ពួកខ្ញុំនៅព្រៃ ទើងត្រូវការសាមណេរធ្វើអ្វី ៗ សេចក្ដីជាប់ជំពាក់ចិត្តទឹងមានដល់អ្នកទាំង· ឡាយ ព្រោះតែអាស្រ័យសាមណេរ គ្មានទេ, មួយទៀត សេចក្ដីជាប់ជំពាក់ចិត្តទឹងមានដល់សាមណេរ ព្រោះអាស្រ័យពួកអ្នកទៅវិញទេ, សូម្បីព្រះសាស្ដា ទ្រង់បញ្ជូនពួកអ្នកមកកាន់សម្នាក់ខ្ញុំ ក៏ទ្រង់ប្រាថ្នាឲ្យសាមណេរទៅជាមួយនឹងពួកអ្នក, ចូរយកសាមណេរនេះទៅចុះ ៗ ភិក្ខុទាំងនោះទទួលពាក្យហើយ រួមជា ៣១ រូបទាំងសាមណេរ ក៏លាព្រះថេរៈ ចេញអំពីវត្តត្រាច់ចារិកទៅកាន់ផ្លូវឆ្ងាយ បានចម្ងាយ ១២០ យោជន៍ ដល់ស្រុកមួយប្រកបដោយត្រកូលមួយពាន់ ៗ មនុស្សទាំងឡាយឃើញភិក្ខុពួកនោះហើយ មានចិត្តជ្រះថ្លា ក៏នាំគ្នាអង្គាសដោយគោរព ហើយសួរថា " និមន្តទៅទីណា ព្រះករុណា? ", កាលលោកប្រាប់ថា " នឹងទៅកាន់ទីតាមសេចក្ដីសប្បាយ ", គេក៏នាំគ្នាក្រាបជិតព្រះបាទាហើយអាពធនាថា " លោកម្ចាស់! កាលបើព្រះគុណម្ចាស់ទាំងឡាយនៅចាំវស្សាអាស្រ័យនឹងស្រុកនេះ, ពួកខ្ញុំនឹងបានសមាទានសីល ៥ រក្សាឧបោសថ ៗ ព្រះថេរៈទាំងឡាយ ទទួលនិមន្តហើយ ៗ ពួកមនុស្ស ក៏នាំគ្នាចាត់ចែងទីគង់នៅពេលយប់ ទីគង់នៅពេលថ្ងៃ ទីចង្ក្រម នឹងបណ្ណសាលា ប្រគេនភិក្ខុពួកនោះហើយ មានចិត្តប្រាថ្នាថា " ថ្ងៃនេះ នឹងបាន ឬតិបត្តិ ព្រឹកស្អែកនឹងបានប្រតិបត្តិទៀត " ដូច្នេះ

កំខំធ្វើឧបដ្ឋាកបម្រើ ៗ ក្នុងថ្ងៃចូលវស្សា ព្រះថេរៈទាំងឡាយ ក៏ធ្វើកតិកានឹងគ្នាថា ពួកយើងរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះពុទ្ធជាម្ចាស់ ដែលទ្រង់មានព្រះជន្មនៅឡើយ, ក្រៅពីប្រតិបត្តិទៀងត្រង់ ក៏មិនអាចឲ្យព្រះពុទ្ធជាម្ចាស់ទ្រង់ត្រេកអរផងបានទេ, ឯទ្វារអបាយ (ទាំងបួន) បើកចាំពួកយើងជានិច្ច, ព្រោះហេតុនោះ ក្រៅពីវេលាភិក្ខាចារព្រឹក ៗ និងវេលាឧបដ្ឋាកបម្រើព្រះថេរៈពេលរសៀល ៗ, ពួកយើង នឹងមិនទៅរួមទីកន្លែងមួយជាមួយគ្នាពីររូបឡើយ, ក្នុងវេលាក្រៅពីនោះ, កាលបើភិក្ខុដែលមិនមានសេចក្ដីសប្បាយគោះគោំងឡើង, ពួកយើងនឹងទៅកាន់សម្នាក់ភិក្ខុនោះហើយធ្វើថ្នាំឲ្យ, ក្នុងវេលាដទៃក្រៅពីនេះ នឹងតាំងសតិចម្រើនកម្មដ្ឋានទាំងយប់ទាំងថ្ងៃ ៗ

កាលលោកធ្វើកតិកានឹងគ្នាយ៉ាងនេះហើយ មានបុរសកម្សត់ទុគ៌តម្នាក់អាស្រ័យពឹងពាក់ធីតាចិញ្ចឹមជីវិត គឺផ្ញើជីវិតលើកូនស្រី កាលកើតអំណត់អត់បាយក្នុងទីនោះ ប្រាថ្នានឹងទៅអាស្រ័យពឹងពាក់ធីតាម្នាក់ទៀតចិញ្ចឹមជីវិត ទើបដើរតាមផ្លូវទៅ ៗ ចំណែកព្រះថេរៈទាំងឡាយ ត្រាច់ទៅបិណ្ឌបាតក្នុងស្រុកហើយ និមន្តត្រឡប់មកកាន់លំនៅវិញ ឈប់ស្រង់ទឹកក្នុងស្ទឹងមួយត្រង់កណ្ដាលផ្លូវ ហើយគង់ធ្វើភត្តកិច្ចលើផ្ទុកខ្សាច់ ៗ ខណៈនោះបុរសកម្សត់ទុគ៌តម្នាក់នោះ ទៅដល់ទីកន្លែងនោះ ហើយបានឈរនៅក្នុងទីម្ខាង ៗ ព្រះថេរៈសួរគេថា “ នឹងទៅណា? ” ៗ គេទូល

សេចក្ដីនោះហើយ ។ ព្រះថេរៈទាំងឡាយ កើតសេចក្ដីករុណាដល់គេ ហើយក៏ប្រាប់ថា "ឧបាសក! អ្នកឯងឃ្លានខ្លាំងណាស់, ចូរទៅយកស្មឹកឈើមក, នឹងឲ្យបាយអ្នកមួយដុំ ៗ មួយអង្គកាល" គេយកស្មឹកឈើមកហើយ បានឲ្យបាយមួយអង្គមួយដុំ ៗ លាយដោយសម្លនិងអន្លក់ ដូចយ៉ាងដែលខ្លួនបរិភោគនោះឯង ។

បានឮថា នេះឯង ជាទំនៀមក្នុងពេលឆាន់ចង្ហាន់, ភិក្ខុនឹងឲ្យបាយដល់មនុស្សដែលមក មិនឲ្យបាយយ៉ាងល្អ តិចឬច្រើនក៏បាន គួរឲ្យតាមបែបដែលខ្លួនបរិភោគនោះឯង ។ ព្រោះហេតុនោះ បានជាពួកព្រះថេរៈឲ្យយ៉ាងនោះ ។

បុរសនោះបរិភោគអាហាររួចស្រេចហើយ ក៏សំពះព្រះថេរៈសួរថា អ្នកណានិមន្តលោកម្ចាស់ឬ ? ។ គ្មានអ្នកណានិមន្តទេ ឧបាសក! មនុស្សទាំងឡាយឲ្យអាហារដូចេះរាល់ថ្ងៃ ។ បុរសនោះគិតថា "ពួកអញ សូម្បីតាំងមុខមាត់ធ្វើការងារគ្រប់ពេលវេលាជានិច្ច ក៏មិនអាចបានអាហារដូចេះដែរ, អញនឹងទៅទីដទៃត្រូវការអ្វីទៀត, នឹងចិញ្ចឹមជីវិតនៅក្នុងសម្នាក់លោកម្ចាស់នេះឯងចុះ" គិតស្រេចទូលថា "ខ្ញុំចង់នឹងធ្វើវត្តប្រតិបត្តិនៅក្នុងសម្នាក់ព្រះគុណម្ចាស់ បានដែរឬទេ ?" ។ នៅធ្វើបាន ឧបាសក! ។គេទៅឯលំនៅរបស់ព្រះថេរៈទាំងនោះ ជាមួយណេក ហើយធ្វើវត្តប្រតិបត្តិយ៉ាងល្អ ឲ្យពួកភិក្ខុពេញចិត្តណាស់, កន្លង

ទៅបានពីរខែ គេប្រាប់ថានឹងទៅសួរសុខទុក្ខកូនស្រី ក៏គិតថា " បើអញនឹងចូលលាលោកម្ចាស់ មុខជាលោកមិនយល់ព្រមបើកឲ្យអញទៅទេ, អញនឹងទៅមិនបាច់លា " គិតហើយក៏ចេញទៅ មិនបានប្រាប់លាព្រះថេរៈតាំងនោះសោះ ។

បានឮថា ការដែលគេទៅមិនបានប្រាប់លាពួកភិក្ខុនេះឯង ជាកំហុសយ៉ាងធ្ងន់ ។ ឯកណ្ដាលផ្លូវដែលគេទៅ មានដងព្រៃមួយកន្លែង កណ្ដាលដងព្រៃនោះ មានចោរប្រាំនាក់បន់ស្រន់ទេព្តាថា អ្នកណាចូលកណ្ដាលដងព្រៃនេះ, ពួកខ្ញុំនឹងសម្លាប់អ្នកនោះ ហើយនឹងធ្វើពលិកម្មដល់លោក ដោយសាច់និងឈាមរបស់វា ។ ថ្ងៃនោះជាថ្ងៃគម្រប់ ៧ ព្រោះដូច្នេះ កណ្ដាលថ្ងៃគម្រប់ ៧ មេចោរទើបឡើងដើមឈើគយមើលពួកមនុស្ស បានឃើញបុរសដើរមក ទើបឲ្យសញ្ញាដល់ពួកចោរ ។ ពួកចោរដឹងថា បុរសនោះចូលកណ្ដាលដងព្រៃហើយ ក៏ចោមព័ទ្ធចាប់ខ្លួនចងទុកយ៉ាងមាំ បង្កាត់ភ្លើងដោយដែកភ្លើង ទាញប្រមូលអុសគរជាគំនរធំ ហើយសំលៀងលំពែងជាច្រើន ។ បុរសនោះ ឃើញពួកចោរធ្វើដូច្នោះ ក៏សួរថា លោក! កណ្ដាលទីនេះជ្រូកនិងម្រឹគ មិនឃើញមានទេ, ចុះព្រោះហេតុអ្វីបានជាលោកធ្វើកិច្ចនេះ ។ អញនឹងសម្លាប់មឹងឯងយកសាច់និងឈាមធ្វើពលិកម្មដល់ទេព្តា ។ បុរសនេះខ្លាចស្លាប់ ភ្លេចគិតដល់ឧបការៈរបស់ពួកភិក្ខុ គិតតែនឹងរក្សាជីវិតរបស់ខ្លួនប៉ុណ្ណោះ, ទើបនិយាយថា លោកម្ចាស់! ខ្ញុំជាមនុស្ស

ស៊ីបាយដែលគេទេ, បានបម្រើព្រោះតែស៊ីបាយសល់ពីគេ, ធម្មតាអ្នកស៊ីបាយដែលគេ ជាមនុស្សកាឡកណ្ណី, ចំណែកលោកជាម្ចាស់ សូម្បីចេញបួសពីត្រកូលណាមួយ ក៏សុទ្ធតែជាក្សត្រ, ភិក្ខុ ៧១ រូប នៅក្នុងទីឯណោះ, លោកម្ចាស់ចូរសម្លាប់ព្រះសង្ឃនោះធ្វើកិច្ចចុះ ទើបទេវតាទីង ត្រេកអរដល់លោកជាយ៉ាងខ្លាំង ៗ ពួកចោរបានឮពាក្យនោះហើយក៏គិតថា ចៅនេះនិយាយត្រូវ នឹងត្រូវការធ្វើជាយមនុស្សកាឡកណ្ណី, នឹងសម្លាប់ភិក្ខុជាក្សត្រ ធ្វើពលិកម្មវិញ គិតរួចហើយក៏ធ្វើបុរសនោះឲ្យជាអ្នកនាំផ្លូវដោយពាក្យថា "ឯងចូរបង្ហាញលំនៅរបស់ភិក្ខុទាំងនោះ" លុះទៅដល់ទីនោះហើយ មិនឃើញពួកភិក្ខុនៅកណ្ដាលវត្តក៏សួរថា ចុះពួកភិក្ខុនៅទីណា ? ។ បុរសនោះ ដឹងកតិការបស់ភិក្ខុទាំងនោះ ព្រោះខ្លួនធ្លាប់បាននៅជាមួយដល់ពីរខែ ទើបប្រាប់ថា លោកគង់ក្នុងទីគង់យប់និងទីគង់ថ្ងៃរបស់ខ្លួន, លោកម្ចាស់ចូរគោះគងនេះ លោកនឹងនិមន្តមកប្រជុំគ្នាដោយសារសម្លេងគង ៗ មេចោរក៏គោះគង ៗ ពួកភិក្ខុបានឮសម្លេងគងក៏គិតថា "អ្នកណាគោះគងខុសពេលវេលា ប្រហែលជាសេចក្ដីមិនសប្បាយនឹងកើតមានដល់ភិក្ខុប្រុសហើយ" ទើបនិមន្តមកគង់លើផែនថ្មដែលក្រាលក្នុងកណ្ដាលវត្តតាមលំដាប់ ។ ព្រះសង្ឃត្ថេរ ក្រឡេកឃើញពួកចោរក៏សួរថា ម្នាលពួកឧបាសក ! អ្នកណាគោះគង ៗ

មេចោរឆ្លើយថា ខ្ញុំគោរព ៗ ប៉ុន្តែនោះព្រោះមានហេតុអ្វី ? ។ ព្រោះពួកខ្ញុំ ចង់ស្រង់ទេវតាក្នុងដងព្រៃ នឹងយកភិក្ខុមួយរូបទៅធ្វើពលិកម្ម ដល់ទេវតា នោះ ៗ ព្រះមហាថេរស្ដាប់ពាក្យនោះ ហើយពោលនឹងភិក្ខុទាំងឡាយថា ម្នាលអាវុសោ ធម្មតាភិក្ខុដែលកើតជាប្រុស គប្បីជួយធ្វើ ខ្ញុំ នឹងលះបង់ជីវិតរបស់ខ្លួនជំនួសពួកលោក ទៅជាមួយនឹងពួកចោរ, អន្តរាយ ចូរកុំមានដល់ពួកលោកទាំងអស់ ៗ ចូរតាំងចិត្តធ្វើសមណធម៌ទៅចុះ ៗ ព្រះអនុត្ថេរឆ្លើយថា ទានៈប្រុស ! ធម្មតាកិច្ចរបស់បងប្រុស គឺជានាទី របស់ប្អូនប្រុស, ខ្ញុំនឹងទៅ លោកទាំងឡាយគួរនៅដោយសតិចុះ ៗ លោក និយាយគ្នាថា " ខ្ញុំនឹងទៅ ខ្ញុំនឹងទៅ " ហើយក្រោកឡើងតាមលំដាប់ ដោយឧបាយនេះទាំង ៣០០ រូប, ភិក្ខុគ្រប់រូប មិនមែនរួមមាតាបិតាជាមួយ គ្នាទេ នឹងជាអ្នកប្រួសជាគណៈ ក៏មិនមែនដែរ ប៉ុន្តែជាហ៊ានលះបង់ ជីវិតដើម្បីជាប្រយោជន៍ដល់ភិក្ខុដែលក្រៅពីខ្លួន ដោយលំដាប់យ៉ាងនេះ, បណ្ដាភិក្ខុទាំងនោះ ភិក្ខុដែលនឹងអាចពោលថា " លោកប្អូនទៅចុះ " ដូច្នេះ សូម្បីតែមួយរូបក៏មិនមាន ៗ សត្តវស្សិកសាមណេរ ពួកភិក្ខុទាំង នោះនិយាយគ្នាហើយ ពោលថា លោកម្ចាស់ឈប់សិន ខ្ញុំនឹងលះ បង់ជីវិតដល់ពួកលោកម្ចាស់ សូមទៅខ្លួនឯង ៗ ពួកយើង ទោះបីនឹង ត្រូវគេសម្លាប់ជាមួយគ្នាទាំងអស់ ក៏នឹងមិនបោះបង់លោកម្ចាស់ដែរ ៗ

ព្រោះហេតុអ្វី? ព្រះករុណា ៗ ព្រោះអ្នក ជាសាមណេររបស់ព្រះធម្ម-សេនាបតីសារីបុត្ត បើពួកយើងបោះបង់ចោលអ្នក ព្រះថេរៈគង់នឹងតិះដៀលថា « នាំយកសាមណេររបស់អាញ ទៅប្រគល់ឲ្យពួកចោរ » ពួកយើងមិនអាចនឹងដោះសាខ្លួនរួចទេ; ព្រោះហេតុនោះ ពួកយើងនឹងមិនព្រមឲ្យអ្នកទៅឡើយ ៗ បានប្រាប់ ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បញ្ជូនពួកលោកមកកាន់សម្នាក់របស់ព្រះឧបជ្ឈាយ៍ខ្ញុំក្តី ព្រះឧបជ្ឈាយ៍របស់ខ្ញុំបញ្ជូនខ្ញុំមកជាមួយនឹងពួកលោកក្តី បញ្ជូនមកព្រោះតែឃើញហេតុនេះឯង, ឈប់ទៅចុះ ព្រះករុណា ។ ខ្ញុំនឹងទៅខ្លួនឯង ៗ សាមណេរថាដូច្នេះរួចក៏សំពះភិក្ខុទាំង ៣០ រូបទូលថា « ព្រះគុណម្ចាស់ បើទោសរបស់ខ្ញុំមាន សូមលោកទាំងឡាយ អត់ទោស » ថាដូច្នេះហើយក៏ចេញទៅ ៗ ភិក្ខុទាំងឡាយកើតសេចក្តីសង្វេគជាខ្លាំង, ភ្នែកទាំងពីរខាងពោរពេញទៅដោយទឹកភ្នែក, ហឫទ័យញាប់ញ័រ ។

ព្រះមហាថេរ ប្រាប់ពួកចោរថា ឧបាសក ។ សាមណេរនេះនៅក្មេងណាស់ ឃើញពួកអ្នកកំពុងបង្កាត់ភ្លើង សម្រេចលំពែង ក្រាលស្លឹកឈើហើយ នឹងខ្លាច, ពួកអ្នកគប្បីយកសាមណេរទៅលាក់ទុកម្ខាងសិន ហើយចាំធ្វើកិច្ចទាំងនោះ ៗ ពួកចោរនាំយកសាមណេរចេញទៅ យកទៅលាក់ទុកម្ខាង ហើយធ្វើកិច្ចទាំងពួង ។

ក្នុងវេលាស្រេចកិច្ច មេចោរ ហូតដាវចូលទៅជិតសាមណេរ ៗ សាមណេរ គង់ចូលឈានស្ងៀមឈឹង ៗ មេចោរ ក៏កាត់ដាវកាត់ក សាមណេរ ៗ ដាវខ្ទះមុខខ្ទប់គ្នា ៗ មេចោរសម្គាល់ថាកាត់មិនស្រួល ទើបពត់ដាវឲ្យត្រង់ ហើយក៏កាប់ម្តងទៀត ៗ ដាវរមូរដល់គល់អន្ទា ដូចជាស្លឹកត្នោត ៗ មែនពិត ក្នុងវេលានោះ បើទុកជាយកភ្នំសិនេរុ-រាជមកសង្កត់ ក៏មិនអាចឲ្យសាមណេរស្លាប់បានដែរ ទំងបាច់និយាយទៅថ្វី ដល់ការកាប់នឹងដាវ ៗ មេចោរឃើញបាដិហារ្យនោះហើយគិតថា “ កាលពីមុន ដាវរបស់អញ កាត់សសរថ្ម ឬក្រាក់គគីរដូចទៅបណ្តូលចេក, វេលានេះលើកដំបូងវៀច លើកទីពីរទៀត រមូរដូចស្លឹកត្នោត, ឯដាវនេះ សូម្បីពុំមានចិត្តគប់គ្រង ក៏នៅតែដឹងគុណរបស់សាមណេរដែរ ចុះបើអញជាមនុស្សមានចិត្តគប់គ្រងត្រឹមត្រូវ ម៉េចក៏មិនដឹងគុណសោះ” គិតយ៉ាងនេះហើយ ក៏បោះចោលដាវលើផែនដី ក្រាបចុះជិតបាទាសាម-ណេរ រួចនិយាយថា “ទានប្រោស! ពួកខ្ញុំចូលមកនៅក្នុងដងព្រៃនេះ ក៏ព្រោះតែចង់បានទ្រព្យ, ពួកបុរសរាប់ពាន់នាក់ ឃើញពួកខ្ញុំអំពីចម្ងាយលឹម ៗ ក៏ញាប់ញ័ររន្ធត់ស្លុតស្មារតី, ចំណែកលោក សូម្បីតែចិត្តតក់-ស្លុតក៏គ្មាន មុខរបស់លោក ល្អស្រស់ដូចមាសឆ្អិនមាត់បារ ទំងដូចផ្កាកណ្ណិការដែលរីកពេញទី តើហេតុអ្វីហ្ន៎?” កាលសួរ បានពោលគា-ថានេះថា ៖

តាសោ តេ ឆត្តំ ច ភយំ
ភិយ្យោ វណ្ណោ បសីទតិ
កាស្មា ច បរិវេទសិ
ឯវរូបេ មហាភយេ ។

សេចក្តីតក់ស្លុត សេចក្តីខ្លាច មិនមានដល់លោក ពណ៌សម្បុររបស់លោកថ្លៃផង់ណាស់ ហេតុម្តេចបានជាលោកមិនទួញយំ ព្រោះភ័យដ៏ធំពន្លឹកយ៉ាងនេះ ។

សាខាឈើពុញចាកឈើហើយ, កាលនឹងសម្តែងធម៌ដល់មេចោរ, ក៏ពោលថា "ម្នាលមេចោរ ! អត្តភាពរបស់ព្រះវិញ្ញណស្រព ដូចជារបស់ជន ដែលគេតម្កល់ទុកលើក្បាល, កាលបើអត្តភាពនោះ បែកធ្លាយទៅ លោកត្រឡប់ជាត្រេកអរវិញ ព្រោះហេតុនោះ ទើបលោកឥតខ្លាចសោះ" ពោលដូច្នេះហើយ បានភាសិតគាថាទាំងនេះថា ៖

ឆន្ទំ ទេតសិតំ ទុត្តំ អចេបត្តស្ស តាមណិ
អតិក្កាន្តា ភយំ សព្វំ ខីណសំយោជនោ ឥសិ
ខីណា អស្ស ភវនេត្តិ និដ្ឋា ធម្មា យថា តថា
និក្ខិយំ មរណំ ហោតិ ភារភេទេបជំ យថា ។

ម្នាលមេចោរ ! ទុក្ខផ្លូវចិត្ត រមែងមិនមានដល់លោកដែលមិនសម្លឹង

ប្រាថ្នាចង់បានឡើយ, លោកដែលស្វែងរកប្រយោជន៍ អស់សំយោគហើយ បានកន្លងនូវភ័យទាំងពួងហើយ, តណ្ហាដែលនឹងនាំទៅកាន់ភពរបស់លោកអស់ទៅហើយ ព្រោះឃើញធម៌តាមកើតពិត, សេចក្តីស្លាប់ដូចជាការដាក់របស់ដែលធ្ងន់ចុះ, ទើបលោកឥតខ្លាចសោះ ។

មេចោរស្តាប់ពាក្យរបស់សាមណេរហើយ សម្លឹងមើលមុខចោរទាំងប្រាំរយនាក់និយាយថា ពួកឯងនឹងធ្វើយ៉ាងម៉េច ៗ ចុះលោកនាយ ៗ ព្រោះឃើញបាបដហាប្រូះចេះជាគ្រោតម្បូង កិច្ចការផ្ទះរបស់ខ្ញុំក៏គ្មាន, ខ្ញុំនឹងបួសក្នុងសម្នាក់លោកម្ចាស់ ៗ សូមព្រះគុណខ្ញុំ ក៏នឹងធ្វើតាមលោកដូច្នោះដែរ ៗ ជាសេចក្តីប្រមើលហើយរួច ។ លំដាប់នោះ ពួកចោរប្រាំរយ សំពះសាមណេរហើយសូមបព្វជ្ជា ៗ សាមណេរកោរសក់និងកាត់សំពត់របស់ពួកចោរដោយមុខដាវនោះឯង, ជ្រលក់សំពត់ដោយដីក្រហមឲ្យចោរស្លៀកដណ្តប់គ្រងសំពត់កាសាយៈនោះ រៀនប្រដៅឲ្យតាំងនៅក្នុងសីលដប់ ហើយនាំដើរតាមផ្លូវទៅ គិតបណ្តើរថា "បើអញនឹងទៅបង្ហួសតែម្តង មិនធៀបចូលទៅឲ្យឃើញព្រះថេរៈទាំងឡាយជាមុនសិនទេលោកក៏មិនអាចធ្វើសមណធម៌បានឡើយ ព្រោះតាំងពីវេលាពួកចោរនាំអញចេញទៅហើយ លោកមិនអាចទប់ទឹកក្តៅបានសូម្បីតែត្រឹមមួយអន្តឡើយ, កាលបើលោកគិតគ្នាថា សាមណេររបស់ពួកយើងចោរសម្លាប់

ចាត់ទៅ ហើយដាក់ប្រាកដផ្លូវច្នេះ គម្ពជាងខឹងមិនធ្លាប់ដំណើរទៅមុខទេ ព្រោះផ្លូវច្នោះ នឹងតៀងចូលទៅឲ្យឃើញលោកជាមុនសិន រួចហើយ ។ សាមណេរគិតផ្លូវច្នោះហើយ មានគិតប្រាំយោរូបដាប់វិក់ទៅដល់គន្ធទីនោះ ។ ព្រះថេរៈទាំងឡាយឃើញ ក៏រីករាយសប្បាយចិត្តពោលថា កូនសប្បុរស សង្ឃិក្ខ! អ្នកបានរួចជីវិតហើយឬ? ។ ព្រះករុណា! ពួកចោរនេះ ប៉ុនប៉ងនឹងសម្លាប់ខ្ញុំ, កាលបើសម្លាប់មិនស្លាប់ ក៏វាជាព្រះថ្វាយក៏គុណរបស់ខ្ញុំ, ស្តាប់ធម៌ហើយនាំគ្នាបួស, ខ្ញុំមកនេះ ដោយបំណងថា នឹងឲ្យឃើញព្រះករុណាម្ចាស់ទាំងឡាយហើយសិនទៅ, ឬនាំជិតត្រឡប់វិញលោកមួយចុះ, ខ្ញុំនឹងទៅគាល់ព្រះសាស្តា" ថាដូច្នេះហើយ សំពះលាភិក្ខុពួកនោះ នាំបរិវាររបស់ខ្លួនទៅដល់សម្នាក់ព្រះឧបជ្ឈាយ៍, កាលឧបជ្ឈាយ៍សួរថា សង្ឃិក្ខ! អ្នកបានអន្តរាយសិកហើយឬ?, ទូលថា "បាទ អាចារ្យ !" រួចតំណាលប្រវត្តិនោះប្រាប់គេស្ដាប់ កាលព្រះថេរៈប្រាប់ថា សង្ឃិក្ខ! អ្នកចូរទៅគាល់ព្រះបរមសាស្តា", ទទួលពាក្យហើយ សំពះលាព្រះថេរៈនាំភិក្ខុពួកនោះទៅដល់សម្នាក់ព្រះសាស្តា ។ ត្រាស់សួរថា "សង្ឃិក្ខ អ្នកបានអន្តរាយសិកហើយឬ? ។ សាមណេរ ក្រាបទូលនូវដំណាលប្រវត្តិនោះសព្វគ្រប់ថ្វាយ ។ ព្រះបរមសាស្តាត្រាស់សួរថា "បានឮថា ហើយនោះមែនឬទេ? ភិក្ខុទាំងឡាយ!", ភិក្ខុទាំង នោះក្រាបបង្គំទូលថា "មែន

ហើយ ព្រះអង្គ!», ព្រះបរមគ្រូទ្រង់ត្រាស់ថា « ឥឡូវនេះ ពួកអ្នកកាន់ទៅក្នុងសីល មានជីវិតរស់នៅសូម្បីតែមួយថ្ងៃប៉ុណ្ណោះ ក៏ប្រសើរជាងគ្រាធ្វើភាពជាអ្នកចោរកម្មដែលកាន់ទៅក្នុងទ្រុស្តសីល មានជីវិតរាប់រយឆ្នាំ», កាលទ្រង់សម្តែងធម៌តអនុសន្ធិ ទ្រង់ត្រាស់ព្រះគាថានេះថា ៖

យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ តែជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់ , ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានសីល មានការពិចារណាជាប្រក្រតី ប្រសើរជាង ។

កាលចប់ទេសនា ភិក្ខុទាំង៥០០រូបនោះ បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទា ។ ព្រះធម៌ទេសនាបានជាប្រយោជន៍ដល់មហាជនដែលប្រជុំគ្នានោះ ។

ដោយសម័យដទៃទៀត សង្កិច្ចសាមណេរ [illegible] ល្មមគ្រប់ដប់វស្សា ក៏ទទួលសាមណេរតូចមួយរូប ឈ្មោះ អធិមុត្តក-សាមណេរ ត្រូវជាក្មួយរបស់លោក ។ កាលវេលា អធិមុត្តក-សាមណេរ មានឆ្នាំគ្រប់ ព្រះសង្កិច្ចត្ថេរ ទើបហៅមកហើយ បញ្ជូនទៅដោយថា យើងនឹងឲ្យឧបសម្បទដល់អ្នក ចូរទៅសួរប្រមាណឆ្នាំ ក្នុងសម្នាក់ពួកញាតិរួចត្រឡប់មកវិញ ។ កាលសាមណេរដើរទៅតាម

សម្នាក់មាតាបិតាក្នុងបន្ទោះផ្លូវ  ពួកចោរប្រាំរយនាក់នឹងសម្លាប់ធ្វើពល-កម្ម បានសម្តែងធម៌ឲ្យស្តាប់ ពួកចោរមានចិត្តជ្រះថ្លាក៏លែងទៅ រួចផ្តាំថា "លោកកុំប្រាប់ថា ពួកខ្ញុំនៅក្នុងទីនេះឲ្យអ្នកណាដឹងសោះ" លោកទៅជួបនឹងមាតាបិតា ដើរតាមផ្លូវមកជួបគ្នា រក្សាពាក្យសច្ចជាប់ មិនបានប្រាប់លោកទាំងពីរនាក់ដែលនឹងដើរទៅផ្លូវនោះសោះ ៗ កាលមាតាបិតារបស់សាមណេរត្រូវពួកចោរបៀតបៀន ថ្ងូញយំបណ្តើរ និយាយបណ្តើរថា "សូម្បីកូននេន ក៏ប្រហែលជារួមចិត្តគំនិតចូលនឹងពួកចោរដែរ បានជាមិនប្រាប់ដល់ញោមឡើយ," ពួកចោរបានឮសម្លេងដូច្នោះ ដឹងសេចក្តីថា "សាមណេរមិនប្រាប់ដល់មាតាបិតាទេ" ក៏មានចិត្តជ្រះថ្លា តាមទៅសូមបព្វជ្ជា ៗ ឯ អធិមុត្តកសាមណេរ ក៏ឲ្យគេបួសទាំងអស់គ្នាដូចជា សទ្ធិង្ហសក្ខមណេរដែរ  ហើយនាំមកកាន់សម្នាក់ព្រះឧប-ជ្ឈាយ៍ ៗ បញ្ជូនឲ្យទៅគាល់ព្រះសាស្តា, លោកនាំភិក្ខុពួកនោះទៅដល់ហើយ ទូលតំណាលប្រវត្តិនោះថ្វាយចំពោះព្រះសាស្តា ៗ ត្រាស់សួរថា "ដំណឹងថាយ៉ាងនោះមែនឬទេ ភិក្ខុទាំងឡាយ!" កាលភិក្ខុពួកនោះទូលទទួលថា "មែនហើយ" កាលទ្រង់សម្តែងធម៌តអនុសន្ធិ តាមន័យដែលមានក្នុងខាងដើម ត្រាស់ព្រះគាថានេះដូចគ្នាថា៖

យោ ច វស្សសតំ ជីវេ  ទុស្សីលោ  អសមាហិតោ

ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់, ការរស់នៅតែមួយថ្ងៃរបស់លោកដែលមានសីល មានការពិនិត្យពិចារណាជាប្រក្រតី ប្រសើរជាង ។

សូម្បីរឿង អធិមុត្តកសាមណេរ នេះ ក៏ព្រះអង្គទ្រង់ត្រាស់គាថានេះដូចរឿង សង្កិច្ចសាមណេរ ដែរ ។

## សេចក្ដីសង្ខេបក្នុងរឿងសង្កិច្ចសាមណេរ

សាមណេរមានអាយុ ៧ ខួប ជាព្រះអរហន្ត តាមទៅជាមួយពួកភិក្ខុអ្នកបំពេញសមណធម៌ក្នុងព្រៃ ត្រូវពួកចោរចាប់យកទៅ ដើម្បីនឹងសម្លាប់សែនពលិកម្ម ប៉ុន្តែពួកចោរមិនអាចធ្វើឱ្យស្លាប់បាន ត្រឡប់ជាមានចិត្តជ្រះថ្លា ចេញបួសតាមទាំងអស់គ្នាទៅវិញ ។

រឿងសង្កិច្ចសាមណេរ ចប់ ។

អាយុមិនទាន់អស់ មិនស្លាប់
បើជាគូព្រេងហើយ កុំគេច

ប៊ូ-ប៊ូ

# ផ្នែកអក្សរសាស្ត្រ

## វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចាន់-ទាត់ រៀបរៀង*

អភ្យុគាសិ ធាតុ ចាក់ភាំង ។

អភ្យក្ត គុ. ដែលបញ្ជាក់ដោយខ្សែក ។

អភ្យន្តរ គុ. ខាងក្នុង ដែលនៅក្នុង ។ ដែលស្គាល់ ។ បុំ. ញាតិជិត ។ នបុំ. ខាងក្នុង ។ — កិលា ស្ត្រី. ការរបនាដើតឆាយ ។ អភ្យន្តរីករណ នបុំ. កិរិយាបង្រៀន ។

អភ្យុបាគ៑ (អគ) ធាតុ ដកដង្ហើម ។

អភ្យមិត្រម៑ ក្រិ.វិ. ចំពោះសត្រូវ ។

អភ្យមិត្រីណ៑ គុ. ដែលវាយសត្រូវដោយក្លាហាន ។

អភ្យក៌ពិម្ពម៑ ក្រិ.វិ. ចំពោះមណ្ឌលព្រះអាទិត្យ ។

អភ្យច៌ ធាតុ គោរព ។

អភ្យច៌ន នបុំ. កិរិយាគោរព ។

អភ្យណ៌ គុ. ដែលជិត ។ នបុំ. ទីជិត ។

អភ្យថ៌ន នបុំ. ពាក្យសុំ បណ្ដឹង ។

អភ្យថិ៌ត គុ. ដែលសុំ ដែលអង្វរ ។

អភ្យទ៌ ធាតុ រឹលរល់ ធ្វើទារុណកម្ម ។

អភ្យហ៌ ធាតុ នមស្ការ ។

អភ្យហ៌ន នបុំ. កិរិយានមស្ការ ។

អភ្យហិ៌ត គុ. ដែលបានទទួលការគោរព ។

អភ្យលង្ការ បុំ. អភ្យលង្ការ គ្រឿងអលង្ការ ។

អភ្យលំក្ឫត គុ. ដែលតែងលំអហើយ ។

អភ្យវក្ឫ ធាតុ ជាច, សាចលើ ។

អភ្យវគាឍ គុ. ដែលផុតហើយ (ជីវិត) ។

អភ្យវបរ៑ ធាតុ បញ្ជូន ។

អភ្យវទាស្យ គុ. ដែលដកហូត ។

អភ្យវនម៑ ធាតុ បង្អោន ។

អភ្យវបទ៑ ធាតុ ទៅស្រោចស្រង់ ។ — បន្ន គុ. ដែលដួប ។

អភ្យវមន៑ ធាតុ មើលងាយ, បដិសេធ ។

អភ្យវសឫ ធាតុ ឃ្លាតចេញ ។

អភ្យវសឫជ៑ ធាតុ បោះបង់, លែងចោល ។

អភ្យវស្កន្ទ៑ ធាតុ លោតរំលង, ធ្លាក់លើ ។

អភ្យវស្ថិត គុ. ដែលតទល់ ។

(នៅមានត)

# រឿងសាមកុក

## ឧកញ៉ាវិបុលរាជសេនា

## នូ - កាន

## ប្រែ - រៀបរៀង

## (៣)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ　　អ្នកភាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន　　ទាំងមានសន្តានស្នេហាជាតិ

យូរ-អ៊ុន

## សាមកុកទី ៧២

តាំងពីម៉ាដ៊ុនចៅហ្វាយស្រុកតៀនស៊ុយ ដឹងថាខុងបេងពីទូស្រុកលាំអ័ន, ម៉ាដ៊ុនគិតនឹងលើកទ័ពទៅជួយហៃហ្វូលិម ទទួលបម្រើខុងបេងកាន់សំបុត្រជាឧបាយកលទៅដល់ម៉ាដ៊ុន, កៀងអ៊ុយ ដឹងដល់ ឃាត់ម៉ាដ៊ុនកុំឲ្យលើកទ័ព, រហូតដល់ចូផិន ចៅហ្វាយស្រុកសេកៀង បាញ់ទ័ពខុងបេង ស្លាប់ចូដ៊ុន និង ចូបាន, នាយទាហាន បានធ្វើសំបុត្រទៅសុំកងទ័ពព្រះចៅចូយ៉យ ឲ្យលើកមកជួយ ។

---

*ខណៈកាលខុងបេងពីទូស្រុកលាំអ័ននោះ, ម៉ាដ៊ុន ចៅហ្វាយស្រុកតៀនស៊ុយ ពួងំណាំងកំពោក្រមការភ្នាក់ងារទៅជំនុំប្រឹក្សាថា ជ្យិតហៃហ្វូលិមនោះ ជាត្រកូលអ្នកមានផ្សែខ្ពស់មកពីដើម ហើយជាបុត្រប្រសាព្រះចៅវុយអង់ផង ប្រៀបដូចដើមឈើមាសស៊ីកកៃ មានតម្លៃណាស់ មិនធ្លាប់ប្រទះធ្វើការធំ ស់ឡូវមករស់នៅកណ្តាលបំណាមគេ គឺខុងបេងពីទូ*

ជាប់ដូច្នេះ តើយើងនឹងត្រូវរិះគិតដូចម្ដេច ? អស់មុខមន្ត្រីក្រមការឆ្លើយថា ហៃហ្វូលិម ជាព្រះញាតិរបស់ព្រះចៅចូយ៉យពិត បើប្រសិនបច្ចាមិត្រ គឺខុងបេងធ្វើឲ្យថ្វស់ការហើយ ខ្លួនលោកជាធំនៅទីនេះក៏គង់នឹងខុសដោយព្រះរាជអាជ្ញាមិនខាន, វេលានេះ គួរតែលោកលើកទាហានទៅជួយចុះ ដើម្បីនឹងដោះយកខ្លួនហៃហ្វូលិម នាំចូលទៅស្រុកក្រុងឲ្យបាន ទើបត្រូវ, ម៉ាជុនបានឮដូច្នោះ ក៏ឃើញត្រូវណាស់ ទទួលទាហានដែលខុងបេងប្រើបន្តឲ្យនាំសំបុត្រនោះចូលទៅដល់; អ្នកចាំទ្វារ ក៏ចូលទៅជម្រាបម៉ាជុន អធិប្បាយសេចក្ដីដូចកាលទៅប្រាប់ស៊ុយលៀង ហើយហុចសំបុត្រជូនទៅទៀត, លុះព្រឹកឡើង បម្រើខុងបេងក៏ចូលទៅជម្រាបម៉ាជុនថា ឥឡូវនេះ ចៅហ្វាយស្រុកហាន់តុងលើកទៅហើយ ឲ្យលោកប្រញាប់លើកទ័ពតាមទៅចុះ, នោះម៉ាជុន ក៏លះលោំងនឹងលើកទ័ពចេញពីស្រុកទៅ ។

ខណៈនោះ មានឈ្មោះគៀងអ៊ុយ ដែលជានាយទាហាននៅស្រុកនោះ មានសតិបញ្ញាស្រៀវស្រួច ពីតូចមក បានរៀនវិជ្ជាដំរាញស្ទាត់ក្នុងកលសង្គ្រាម ហើយមានកតញ្ញូនឹងបិតាមាតា, បណ្ដាអ្នកស្រុកទាំងពួងក៏កោតញញើតកប់អាន, លុះឃើញម៉ាជុននឹងលើកទាហានទៅដូច្នោះ ក៏និយាយហាមឃាត់ថា ដ្បិតខុងបេងនោះមានសតិបញ្ញាណាស់, ដែលថាទាហានហៃហ្វូលិមកាន់សំបុត្រមកនោះ, ខ្ញុំបាទ មិនយល់ឃើញផងនោះ

ព្រោះខុនបេនព័ទ្ធស្រុកលាំអ័នយ៉ាងមាំមួន, ឯទាហាននេះសោត ពីដើមមក ក៏មិនប្រាកដជាឈ្មោះអ្វី ដែលមកប្រាប់ថា ខ្លួនគេបានពារទម្លាយចំណោមទ័ពកាន់សំបុត្រចេញមកបាននោះ ឃើញដូចមិនសមប្រកបសោះ, ក្រោយនោះ មានទាហានម្នាក់មកប្រាប់ទៀតថា ចៅហ្វាយស្រុកហ័នតេនលើកទ័ពចេញទៅហើយនោះ ក៏គ្មានអ្វីជាលក្ខសំខាន់សោះ, ខ្ញុំបាទយល់ឃើញថា ប្រហែលជាឧបាយខុនបេន ក្លែងបញ្ឆោតឲ្យយើងលើកទ័ពទៅ ដើម្បីនឹងបន្លំទាហានឲ្យទៅចាំដណ្ដើមស្រុកយើងជាក្រោយទេដឹង ។

ម៉ាដុនបានស្ដាប់ដូច្នោះ យល់ឃើញត្រូវនឹងគំនិតខ្លួន ក៏ដកដង្ហើមធំថា ដែលអ្នកមករំលឹកស្មារតីយើងនេះ ត្រូវណាស់, បើពុំបានអ្នកមកនិយាយដូច្នេះ ក៏នឹងខូចការទទេទៅ ដោយត្រូវឧបាយខុនបេន ។ គៀនអ៊ុយអស់សំណើចហើយថា ដែលខុនបេនក្លែងធ្វើកលដូច្នេះ មុខជាមានទាហានមកតួនបន្លំជាប្រាកដណាស់, ខ្ញុំបាទនឹងសុំទាហាន ៣.០០០ លើកព័ទ្ធវាំងទៅតាមផ្លូវតូច ដើម្បីនឹងស្ទាក់ពាំងទ័ពខុនបេនឲ្យបាន រួចសឹមលោកលើកទាហានចេញទៅតាមក្រោយ បណ្ដោយចម្ងាយ ១៥០ សិន (៦ គី.) ត្រូវបញ្ឈប់កងទ័ពរង់នៅទីនោះ, បើឃើញខ្ញុំបាទដុតភ្លើងឡើងជាសម្គាល់ ហើយឃើញកងទ័ពធំលើកមកដល់ ក៏ឲ្យបពេលចូលច្បាំង ហោមចាប់ខ្លួនខុនបេនឲ្យបាន ។ ម៉ាដុនបានស្ដាប់ ក៏យល់ត្រូវដូចគំនិត ទើបចាត់ឲ្យកេណ្ឌទាហាន ៣.០០០ ប្រគល់ឲ្យគៀនអ៊ុយលើកចេញទៅ ហើយម៉ាដុន

ក៏លើកទ័ពធំចេញទៅតាមជាប់ជាប់គ្នា ៗ ឯជូឡុង ដែលខុងបេងឲ្យនាំទាហានទៅពួនបង្កប់នៅក្បែរជើងភ្នំ ក្រៅស្រុកគៀនស៊ុយនោះ លុះដឹងថា ម៉ាជុនលើកទ័ពចេញចាកស្រុកមកហើយ ក៏មានអំណរណាស់ ប្រើបម្រើយ៉ាងរហ័សឲ្យទៅប្រាប់គៀវអេកនិងចោអ៊ុ ដែលលើកតាមជាក្រោយឲ្យចេញស្កាត់ផ្លូវចាំទទួលម៉ាជុន ព័ទ្ធចាប់យកខ្លួនឲ្យបាន, ហើយឯជូឡុងក៏លើកទាហាន ៥.០០០ ចូលទៅដល់ជើងកំពែងស្រុកគៀនស៊ុយ ហើយស្រែកថា យើងឈ្មោះជូឡុង ជាពួកស្រុកសៀងសាន់ លើកទ័ពមក, ឯងចាញ់ឧបាយកលយើងហើយ ឯងដឹងខ្លួន ឲ្យប្រញាប់បើកទ្វារទទួលយើងដោយស្រួលបួលទៅចុះ កុំឲ្យទាហានទាំងអស់បានសេចក្តីលំបាក, នោះទាហានដែលនៅកំពែងស្រុកបានឮសម្តីដូច្នោះ ក៏អស់សំណើចហើយថា អ្នកឯង កុំមកបរពាប្រមាថមើលងាយយើងឡើយ, អ្នកឯង ចាញ់កម្រិះគិតគៀងអ៊ុយហើយ ម្តេចក៏នៅមិនទាន់ដឹងខ្លួនសោះដូច្នេះ ៗ

ជូឡុង ឮដូច្នោះក៏ខឹងណាស់ បរពលចូលប៉ននឹងរំលាយយកស្រុកនោះឲ្យបាន ទទួលឃើញពន្លឺភ្លើងឆេះសន្ធោឡើង, ទាហានក៏ស្រែកហ៊ោព័ទ្ធចូលមកគ្រប់ទាំង ៤ ទិស, គៀងអ៊ុយ ក៏ឡើងសេះកាន់លំពែងបំដាយចូលត្រង់មក ហើយស្រែកប្រកាសថា យើងឈ្មោះគៀងអ៊ុយ កើតនៅស្រុកគៀនស៊ុយ, ជូឡុងឃើញដូច្នោះ ក៏បំដាយសេះ ចូលទៅប្រយុទ្ធនឹងគៀងអ៊ុយបាន ៩ ក្បួន, ជូឡុង ឃើញគៀងអ៊ុយមានកម្លាំងខ្លាំងពូកែ

ក៏គិតថា ក្នុងស្រុកគៀនស៊ុយនេះ ពីដើមមក មិនដែលបានសង្កេត ថា មានទាហានឯកដល់ម៉្លេះសោះ, នោះស្រាប់តែម៉ាជុនដេញទាហានពន្ធ ចូលមកទៀត, ជូឡុងអស់កម្លាំងណាស់ ក៏បំផាយសេះពុះទម្លាយចេញ ពីក្នុងចំណោមបាន, គៀងអ៊ុយ ក៏បំផាយសេះដេញជិតដោយពីក្រោយ ទៅ, លុះទៅដល់ផ្លូវដែលគៀវអេកទិងហោអ៊ី ១ ក៏ចេញមកស្កាត់ពីមុខ, គៀវអេកទិងហោអ៊ី ក៏បំបោលសេះចូលជួយជូឡុង, គៀងអ៊ុយក៏ញាក់ សេះត្រឡប់ក្រោយ, ទទួលខុងបេងមកដល់, ជូឡុង ក៏ចូលទៅជួបនឹង ខុងបេងហើយថ្លែងការណ៍តាមរឿងឲ្យខុងបេងស្តាប់គ្រប់ប្រការ ។

ខុងបេងបានដឹងសេចក្តី ក៏ឲ្យភ័យស្លុតចិត្តគិតថា នាយទាហាននេះ ឈ្មោះអ្វីហ្ន៎ បានជាមានគម្រិះប្រាជ្ញាក្លាហានដឹងដល់គំនិតយើងបាន? នោះ មានពួកស្រុកណាំអ័ន ដែលមកចុះចូលនឹងខុងបេងឆ្លើយជម្រាបថា នាយ ទាហាននោះឈ្មោះគៀងអ៊ុយ គឺសែគៀង ឈ្មោះអ៊ុយ មានប្រាជ្ញាស្រៀវ ស្រួចណាស់ ឈ្លាសវៃក្នុងការរណរង្គសង្គ្រាម ។ ជូឡុងថា គៀងអ៊ុយ នេះជំនាញក្រែនស្ទាត់ក្នុងការចម្បាំង ប្លែកជាងគេច្រើនណាស់, រួចជូឡុង ក៏កាត់ក្បួនការរុកតាមលំនាំគៀងអ៊ុយ ជូនខុងបេងមើល, ខុងបេងឃើញហើយ ថា យើងមិនបានសម្គាល់ថាក្នុងស្រុកគៀនស៊ុយនេះ នឹងមានទាហានឯក ដល់ប៉ុណ្ណេះសោះ, ហើយខុងបេងក៏ឲ្យលើកទ័ពទៅស្រុកគៀនស៊ុយ ។

ឯកៀនអ៊ុយ លុះត្រឡប់វិញ ក៏និយាយនឹងម៉ាជុនថា ជួឡុងចាញ់ ប្រៀបនឹងយើងក្នុងគ្រានេះ មុខជានឹងប្រាប់រឿងហេតុដល់ខុងបេង ៗ គង់នឹងយល់ឃើញថា ក្នុងស្រុកយើងមិនសូវមានទាហាន ក៏នឹងត្រឡប់ស្រូតលើកទ័ពលបមកវាយយកស្រុកយើងវិញហើយ, បើដូច្នេះហើយ យើងត្រូវញែកទាហានចេញជាពួនបង្កប់នៅក្រៅស្រុក, ខ្ញុំបាទនឹងលើកទ័ពមុខទៅនៅទិសឯកើត, ឲ្យលៀងខៀននិងអ៊ុនសុង នាំទាហានទៅបង្កប់នៅទិសឯលិច, ឲ្យលៀងស៊ុនាំទាហានទៅនៅក្បាស្រុក, ឯខ្លួនលោកត្រូវលើកទ័ពទៅនៅទិសឯត្បូង, បើខុងបេងលើកទ័ពចូលមក, ឃើញភ្លើងសញ្ញាខាងខ្ញុំបាទហើយ ក៏ឲ្យវាយទ័ពព័ទ្ធ ប្រជិតគ្នាចូលមកចាប់យកខ្លួនខុងបេងឲ្យបាន, ម៉ាជុនបានស្ដាប់ពត៌មានគ្រប់សព្វ ក៏យល់ត្រូវនឹងគំនិតខ្លួន ទើបចាត់ចែងរៀបជាក្បួនទ័ពទុកព្រម តាមពាក្យកៀនអ៊ុយ គ្រប់ប្រការ ។

ឯខុងបេង កាលលើកទៅដល់ស្រុកតៀនស៊ុយកាលណា ជាពេលាកណ្ដាលយប់ ក៏ដេញទាហានឲ្យចូលខ្ទប់ប្រសព្វវាយទ័ពសត្រូវ, នោះទាហានទាំងពួង នឹងចូលទៅក្នុងស្រុក ឃើញទង់ជ័យដោតរៀងរាយជាច្រើន ក៏មិនអាចនឹងហែកទម្លាយចូលទៅបាន លុះដល់ពេលយាម ២ ទើបឃើញពន្លឺភ្លើងឆេះរន្ទាលក្ដៅឡើងខាងទិសឯកើត, ទាហានស្រែកហ៊ោ

កក្រើកព័ទ្ធចូលមក, ទាហានក្នុងស្រុក ក៏ភ័យឃ្លោះគោះគងទូងស្គរច្បាំង គ្នាជាកោលាហលអឺងកង ។

ខុនបេង ឃើញដូច្នោះ ក៏ភ័យស្លុតស្មារតី នាំគួនហ៊ុន តៀវជៀ នូវអស់ទាហានបំផាយសេះរត់ពារទម្លាយ រាយកាប់កងទ័ព ចេញពីក្នុងបំណោមទៅទិសឯកើត ឃើញកៀងអ៊ុយនាំទាហានចេញមកស្ទាក់ពីមុខ ហើយផុតកៀងនេះឡើងច្រើនអន្លើ ក៏រឹតតែភ័យណាស់ នាំទាហានពានប៉ះរត់គេចចូលទៅជន្លាយ, ហើយខុនបេងក៏ឲ្យហៅទាហានស្រុកហ៊ានតេងទាំងឡាយមកសួរពិចារណាថា កៀងអ៊ុយនេះ មានសតិបញ្ញាស្រៀវស្រួចណាស់ បិតាមាតានៅទីដំបន់ឯណា ធ្វើម្តេចយើងនឹងបានខ្លួនមកធ្វើការជាមួយ ។ ទាហានទាំងនោះឆ្លើយឲ្យការថា បិតាកៀងអ៊ុយស្លាប់ហើយ នៅតែមាតា នៅស្រុកអេកកួន ។ ខុនបេងបានស្តាប់ ទើបហៅអ៊ុយអៀនមកបង្គាប់ថា អ្នកឯងត្រូវលើកទាហានទៅបោះទ័ពក្បាប់ទឹងកំពែងស្រុក អេកកួនទុកឲ្យមួនមាំចុះ, បើឃើញកៀងអ៊ុយលើកទ័ពទៅ ត្រូវឲ្យធ្វើជាចាញ់ចេញទៅពួនបង្កប់ បណ្តោយឲ្យកៀងអ៊ុយចូលទៅក្នុងស្រុកនោះចុះ, បើកៀងអ៊ុយត្រឡប់ចេញពីក្នុងស្រុកនោះមកវិញ សឹមលើកទាហានពានយកស្រុកនោះឲ្យបាន ហើយត្រូវប្រើកលឧបាយឲ្យទាហានបន្លំជាពួកអ្នកស្រុកមកតាមផ្លូវពីស្រុកតៀនស៊ុយ ។ អ៊ុយអៀនក៏លាខុនបេងចេញទៅ ។

ខុនបេនក៏សាកសួរទាហានស្រុកហ៊ានគេនថា ក្នុងទីដែននេះ តំបន់·ណាជាទីសំខាន់ខ្លះ? ពួកទាហាននោះឆ្លើយថា ស្រុកសៀងឆេង មានស្បៀងអាហារក្រាស់ក្រួនមួនមាំជាងគេ, ស្រុកគៀនស៊ុយ ក៏ប្រាស្រ័យស្រុកនោះជាកម្លាំង, បើប្រសិនមហាឧបរាជបានស្រុកសៀងឆេងហើយ ស្រុកគៀនស៊ុយ ក៏នឹងដាច់ស្បៀងអាហារជាមិនខាន ។

ខុនបេនឮដូច្នោះ ក៏សប្បាយចិត្តណាស់ ប្រើជួឡុងឲ្យលើកទ័ពទៅវាយយកស្រុកសៀងឆេង ហើយក៏រំកិលទ័ពហ្លួងទៅតាំងបន្ទាយយ៉ាងមាំមួន ឆ្ងាយពីស្រុកគៀនស៊ុយប្រហែល ១.៥០០ សិន (៦០គី.) ។ ពួកទាហានអ្នកស្រុកក៏ចូលទៅប្រាប់ម៉ាជុនថា ខុនបេនវាយរំកិលកងទ័ពចេញទៅហើយ ។ ញែកទាហានជា ៣ កង ឲ្យទៅវាយយកស្រុកអេកគួន ១ កង ឲ្យទៅវាយយកស្រុកសៀងឆេង ១ កង ។

គៀងស៊ុយឮដូច្នោះ ក៏ភ័យស្លុតស្មារតី និយាយជម្រាបម៉ាជុនថា ឥឡូវខុនបេនលើកទ័ពទៅវាយយកស្រុកអេកគួនហើយ, មាតាខ្ញុំបាទ នៅក្នុងស្រុកនោះ មុខជានឹងដល់នូវសេចក្ដីអន្តរាយពុំខាន, បើដូច្នេះ ខ្ញុំបាទនឹងសុំលាលោក សុំទាហានលោក ១ កង លើកទៅជួយការពារមាតាក្នុងស្រុកអេកគួនផង, ម៉ាជុនបានឮដូច្នោះ ក៏ចាត់ទាហាន ៣.០០០ ឲ្យគៀងស៊ុយលើកចេញទៅ ហើយឲ្យលៀងទៀននាំទាហាន ៣.០០០ លើកតម្រង់ទៅស្រុកសៀងឆេង ។

ឯគៀនអ៊ុយនោះ លុះលើកពលទៅដល់ស្រុកអេកគួនហើយ ឃើញអ៊ុយអៀននាំទាហានស្ទាក់ពីមុខជាប់, អ៊ុយអៀនក៏បរសេះសន្ទាប់ចូលទៅប្រយុទ្ធនឹងគៀនអ៊ុយបាន ៩ ក្បួន, អ៊ុយអៀនធ្វើជាចាញ់ ញាក់សេះរត់, គៀនអ៊ុយក៏ដេញប្រផិតផិតដោយតាម, លុះមិនទាន់ហើយ ក៏ត្រឡប់ចូលស្រុកអេកគួនបាន ហើយចាត់ទាហានឲ្យរក្សាសើនបន្ទាយជុំវិញ យ៉ាំងមាំមួន ។

ឯលៀងខៀន កាលលើកទាហានទៅដល់ស្រុកសៀងចេង ឃើញជូឡុងតាំងបន្ទាយភ្ជាប់នឹងកំពែងស្រុក ហើយជូឡុងបើកផ្លូវឲ្យលៀងខៀនលើកទាហានចូលទៅក្នុងស្រុកបាន ។

ខណៈកាលអ៊ុយអៀននិងទាហានជូឡុង លើកទ័ពចេញទៅនោះ ក្រោយនោះ ខុងបេងគិតឧបាយកលឲ្យទាហានទៅយកខ្លួនហៃហួ-លិមមកនិយាយថា ខ្លួនអ្នកឯងត្រូវដល់ទីស្លាប់ហើយ, យើងក៏នៅអែអង់វង់ឲ្យបានយូរដល់ថ្ងៃនេះ មិនទាន់សម្លាប់ តើអ្នកឯងនឹងរិះគិតរកចំណាប់ប្រការម្ដេច ? ហៃហួលិមបានឮដូច្នោះ ក៏ភ័យខ្លាំងណាស់ ក្រាបសំពះចុះហើយក៏អង្វរករសុំអាយុជីវិត, ។ ខុងបេងថា គៀនអ៊ុយ ទាហានម៉ាជុនដែលទៅនៅរក្សាស្រុកអេកគួន, ឥឡូវឲ្យសំបុត្រមកថា ឲ្យយើងចិញ្ចឹមអ្នកឯងទុកធ្វើការផង, ហើយគៀនអ៊ុយ ក៏ស្ម័គ្រមកនៅនឹងយើងដែរ, អ្នកឯងនឹងយកអាសាយើងទៅនាំគៀនអ៊ុយមកបានឬទេ ។

ហៃហ្វូលិមឆ្លើយថា មហាឧបកដ្ឋកុំវិតក្កឡើយ, ការនេះទុកមុខងារខ្ញុំបាទ ខ្ញុំនឹងទៅបបួលកៀងអ៊ុយនាំមកឲ្យបាន ។ ខុងបេងក៏ចាត់រើសយកសេះព្រៃយ៉ាងល្អហើយនិងសេះជំនិះមួយ ឲ្យហៃហ្វូលិម ។ ក៏លាប្រញាប់ចេញទៅស្រុកអេកកួន, កាលចេញផុតទៅហើយ ហៃហ្វូលិមនឹកត្រេកអរណាស់ ព្រោះឃើញថា រួចពីកណ្ដាប់ដៃខុងបេងហើយ ក៏ចំស្រូតបរសេះទៅ, ដល់ពាក់កណ្ដាលផ្លូវ ប្រទះនឹងទាហាន ១០ នាក់ ដែលអ៊ុយអៀនប្រើជាឧបាយកលជាអ្នកស្រុកអេកកួនរត់មក ។ ទាហានទាំងនោះប្រាប់ហៃហ្វូលិមថា កៀងអ៊ុយស្ម័គ្រចូលទៅនៅខាងខុងបេងហើយ ។ បើកទ្វារស្រុកទទួលអ៊ុយអៀន ចូលទៅតាំងទ័ពក្នុងស្រុកអេកកួនហើយ, ឥឡូវ អ៊ុយអៀនក៏ហែងកំហោកក្រ្ត ។ បាទៈសេចក្ដីក្ដៅក្រហាយខ្លាំងណាស់, យើងខ្ញុំទាំងឡាយទ្រាំពុំបាន ។ ជានាំគ្នាគេចរត់មក ប្រាថ្នានឹងទៅនៅស្រុកសៀងចេង ។

ហៃហ្វូលិមសួរថា ឥឡូវនេះណានៅរក្សាស្រុកគៀនស៊ុយនោះ ? ពួកនោះឆ្លើយថា ម៉ាជុនទៅហ្វាយស្រុកចាស់នៅរក្សាស្រុកដដែល ។ ហៃហ្វូលិមឮដូច្នោះ ក៏ស្រូតបរសេះតម្រង់ទៅស្រុកគៀនស៊ុយ ទទួលប្រទះនឹងពួកទាហានបន្ទំរបស់អ៊ុយអៀន ១ កងទៀត ធ្វើឫកពារដូចជាទើបរត់មកថ្មីទៀត ខ្លះពុនរែករបស់ទ្រព្យ ខ្លះពុនរែកស្រូវអង្ករ ខ្លះពកូនចៅ ហើយនិយាយប្រាប់មកហៃហ្វូលិម ដូចជាសម្ដីពួក ១០ នាក់មុន គ្រប់ប្រការ ។ ហៃហ្វូលិមឮហើយ ក៏រឹតតែភ័យណាស់ ចំបំផាយសេះទៅដល់ស្រុក

តៀនស៊ុយ ។ ទាហានកងស្រុកឃើញហៃហ្វូលិះទៅដល់ គឺបើកទ្វារ អញ្ជើញឲ្យចូលទៅកងស្រុក ។ ម៉ាជុនក៏គំនាប់ហៃហ្វូលិម នាំទៅកាន់ទីប៉ាន ។ ហៃហ្វូលិម ក៏ពណ៌នារឿងរ៉ាវ ដែលតៀនស៊ុយប្រែចិត្តក្បត់ ស្មគ្រចិត្តចូលទៅនៅខាងខុងបេង និងសេចក្តីដែលពួកទាហាននិយាយប្រាប់កណ្តាលផ្លូវនោះ ឲ្យម៉ាជុនស្តាប់គ្រប់ប្រការ ។

ម៉ាជុនឮដូច្នោះ ក៏ដកដង្ហើមធំហើយថា ឯតៀនស៊ុយនេះ ពីមុនមក ក៏ឃើញថាជាមនុស្សទៀងត្រង់ល្អណាស់ មិនឃើញច្បាស់ថា នឹងប្រែចិត្តជាក្បត់ គិតប្រែទៅចូលនឹងសត្រូវនោះឡើយ ។ ហៀនស៊ុនាយទាហានឮហើយ ក៏ជម្រាបម៉ាជុនថា ដែលតៀនស៊ុយប្រែចិត្តគិតក្បត់ទៅចូលគំនិតនឹងខុងបេង ដោយពិតនោះខ្ញុំបាទមិនយល់ឃើញផងសោះ ខ្លួនជាមុខជាតៀន-ស៊ុយនឹងគិតកលឧបាយបញ្ឆោតខុងបេងទេ ។ ម៉ាជុនឮដូច្នោះឆ្លើយថា ដែលឯងនិយាយនេះ យើងមិនទាន់ឃើញផងសោះ ព្រោះតៀនស៊ុយប្រាកដជាក្បត់ទៅចូលនឹងខុងបេងពិតហើយ បានជាទទួលស៊ុយហៀនឲ្យចូលទៅកងស្រុក ទាល់តែរាស្ត្របានកើតសេចក្តីទុក្ខក្តៅក្រហាយពេញខេត្រខណ្ឌ រត់បោលផ្ទះសំបែងប្រពាក់ប្រពួនចេញមក យកតែអាយុជីវិត ។ ខណៈនោះ ទទួលពេលក៏ព្រលប់ ខុងបេងលើកទ័ពចូលមកដល់ជើងកំពែងស្រុកតៀនស៊ុយ ទើបបាត់ទាហានម្នាក់មានរូបនឹងមុខមាត់ប្រហែលតៀនស៊ុយ ឲ្យឡើងជិះសេះចូលទៅស្រែកថា ឲ្យអញ្ជើញហៃហ្វូលិមចេញមកជួបនឹង

យើងជាប្រញាប់ ទើងបានសន្ទនាគ្នាបន្តិច ។ ហៃហ្គូលិមនិងម៉ាជុនឡើងឈរមើលពីលើសើនបន្ទាយ ឃើញច្បាស់ជាកៀនអ៊ុយ បំបោលសេះពាំលំពែងចូលមក ក៏ទឹកភ័យណាស់ ។ កៀនអ៊ុយបន្ទំក្លួងនោះ ស្រែកឡើងថា ដែលយើងទៅចូលខាងខុងបេងនោះ ក៏ពីព្រោះហៃហ្គូលិមនាំគិតជាមុន ហេតុម្តេច អ្នកឯងមកត្រឡប់ពាក្យសម្តីវិញដូច្នោះ ។

ហៃហ្គូលិមឆ្លើយថា អ្នកឯង ជាខាយទាហានៈនៅក្នុងផែនដីព្រះចៅចូយយ ហេតុម្តេចមកក្បួយក្លេចព្រះតេជព្រះគុណម្ចាស់វិញដូច្នេះ ថែមទៅចូលខាងបច្ចាមិត្តគិតទ្រុស្តម្ចាស់ឯង វេន្ទ័នយកខុងបេងជាគ្នា ហ៊ានមកចោទប្រឡោងខាមតាមអំពើចិត្តឥតអៀនខ្មាស ។ កៀនអ៊ុយក្លួងស្រែកឡើងថា អ្នកឯង បានសរសេរសំបុត្រប្រាក់ដផ្ញើទៅដល់យើង ថាឲ្យយើងស្ម័គ្រចិត្ត គិតចូលទៅខាងមហាឧបរាជ (ខុងបេង) ចុះ, យើងពិគ្រោះឃើញពិតបានជាតាំងចិត្តចូលទៅខាងណោះ, យើងមិនដឹងសោះ ថាអ្នកឯងក្លួងបញ្ឆោតយើងឡើយ, អ្នកឯងនេះហើយ ពេញជាមនុស្សអាក្រក់បេះកុហកឲ្យបានតែរួចខ្លួនពីស្លាប់ប៉ុណ្ណោះ, គ្រានេះ មហាឧបរាជ អាចតាំងបណ្តោះបណ្តាលឲ្យយើងបានឡើងជានាហ្មឺនធំ បានជាយើងខិតខំមកធ្វើការយកអាសាវាយបំបែកស្រុកនេះ ឲ្យបានជូនមហាឧបរាជ, ហើយកៀន-អ៊ុយ ក្លួងនោះ ក៏ស្ទុះបរពេលចូលប្រកាប់ប្រចាក់ ។ ហៃហ្គូលិមនិងម៉ាជុនក៏ស្ទុះស្ទាក់តដៃគ្នាជាពន្លឹកសន្ធឹកសន្ធាប់ ។ កៀនអ៊ុយក្លួង ក៏កបយទ័ព

ត្រឡប់ទៅរកខុនបេន ។ ក៏គាំងតែថយទ័ពបំគម្រង់ទៅស្រុកអេកកួន ។

ឯកៀនអ៊ុយមិនបានដឹងខ្លួន ឡើងឈរមើលលើសើនខ្ពស់ ឃើញខុនបេនឲ្យទាហានបរទេះ ផ្ទុកស្បៀងតម្រង់មកបន្ទាយអ៊ុយអៀនច្រើនណាស់ ក៏ចុះនាំទាហាន ៣.០០០ លើកចេញពីកំពែងស្រុក សម្រុកត្រង់ទៅដណ្ដើមយកស្បៀងខុនបេន ។ ពួកទាហាននាំស្បៀង ក៏ពួតដៃប្រឹងតាំងត ហើយធ្វើជាសុះឈ្លួនបោលទេះស្បៀងទាំងអស់ចេញ ។ កៀន-អ៊ុយ ក៏សម្រុកដេញដណ្ដើមយកទេះស្បៀងទាំងអស់បាន មានអំណរណាស់ លើកទាហានត្រឡប់វិលទិសចូលទៅស្រុក, ទទួលតៀវអេកនាំទាហានមកស្កាត់ពីមុខជាប់ ។ តៀវអេកក៏សុះសន្ធាប់ចូលទៅប្រយុទ្ធនឹងកៀនអ៊ុយបាន៩ក្បួន, ទទួលអងបេងលើកទ័ពល្បួនមកជួយពីក្រោយថែមទៀត ក៏ព្រួតគ្នាពារប្រយុទ្ធនឹងកៀនអ៊ុយ ដោយសន្ធឹកសន្ធាប់ណាស់ ។ កៀនអ៊ុយនឹងទល់ប៉ះដោយកម្លាំងពុំបាន ក៏បំពានបរសេះ ទម្លុះកងទ័ពរត់ទៅសំដៅទ្វារស្រុក ។

ខណៈកាលកៀនអ៊ុយ លើកពលចេញពីស្រុកមកនោះ, អ៊ុយអៀនក៏បរពលទម្លុះទម្លាយ វាយចូលទៅក្នុងស្រុកបាន, ហើយឲ្យទាហានឡើងរក្សាសើនបន្ទាយដោយមាំមួនណាស់, កៀនអ៊ុយត្រឡប់មកឃើញទង់សម្គាល់ដោតនៅវេរវាស ជាទង់របស់ខុនបេន ក៏ដូចជាស្លុតស្លុវិញ្ញាណគ្មានកម្លាំងសោះ បំផាយសេះនាំពលទាំងអស់ ១០ នាក់ ស្រូតទៅ

ស្រុកតៀនស៊ុយ, ប្រទះនឹងទៀវជ៉ៅលើកលុកលុយស្ទាក់ពីមុខ, ទៀវជ៉ៅក៏បរសេះគំហុកចូល, ទាំងពលទាហានក៏ទន្ទ្រាន តនឹងគៀងស៊ុយ ដោយអង់អាចឥតញញោបក្តឹក, គៀងស៊ុយក៏ ចូលតទល់យ៉ាងពន្លឹកមហិមា តែថាកម្លាំងនឹងប្រឹងតារតទៅពុំបាន, ក៏បរបោលសេះហោលទាហានទាំងអស់ ខំបន្ទ្រះរត់ទៅដល់ស្រុកតៀនស៊ុយ ហៅទាហានឲ្យបើកទ្វារ, នាយទ្វារកទៅប្រាប់ម៉ាជុន ៗ ថា: ដែលគៀងស៊ុយរត់មកនេះ, ដោយសំណោះនឹងបញ្ឆោតយើងទេ, ធ្វើឲ្យយើងបើកទ្វារទទួល, ម៉ាជុនក៏ឲ្យទាហានទៅខលបាញ់ធ្នូច្រែះពីកំពែងបញ្ចេញមកដូចគ្រាប់ភ្លៀង ៗ គៀងស៊ុយក៏ស្ទុះវាំងគេចត្រឡប់មកវិញ, ៗ ទ័ពខ្វុងបេងក៏លើកដេញតាមរោមព័ទ្ធខ្លួនគៀងស៊ុយនៅជាកណ្តាលរៀណរង្គ ៗ ឯគៀងស៊ុយ ក៏ស្ទុះស្ទុងតារទម្លាយសំដៅទៅរកលៀងទៀន ឯស្រុកសៀងយេង ៗ.

ឯលៀងទៀន នៅលើសើទកំពែងខ្ពស់ ក្រឡេកឃើញគៀងស៊ុយបរសេះបន្ទ្រះរួចពីកងចំណោម ទៅដិតមាត់ទ្វារ ក៏ខឹងណាស់, ស្រែកដៀលត្មះជេរថា: អាចោរក្បត់, អាឯងគេចរត់ទៅចូលខ្មាំងហើយ នឹងត្រឡប់ក្បាលវិលមក បញ្ឆោតឲ្យយើងបើកទ្វារទទួលម្តេចបាន, អាឯងកុំស្មានថា យើងឆោតនឹងបើកទ្វារឲ្យខ្ទបស្រុកយើងឬ ? ថាហើយ ក៏ឲ្យទាហានបាញ់ធ្នូច្រែះចុះទៅ, គៀងស៊ុយក័យណាស់ ស្រែកយំខំបរបោលសេះកាត់សំដៅទៅស្រុកឡេងអាន ដល់ទៅព្រៃញាតស្លាតមួយអន្ទើ.

បានឮសម្រែកទាហានស្រែកហៅគឹកកង, គួនហ៊ិនក៏ស្ទុះចេញត្រសងមករងពីមុខ, គៀនអ៊ុយក៏យស្លុតស្មើរបាត់វិញ្ញាណ, គិតនឹងស្ទុះបំពានចូលទៅតដៃនឹងគួនហ៊ិន, ឃើញថាកម្លាំងក៏កាន់តែទន់ថយណាស់ ក្រឡាស់ញាក់សេះឲ្យគេចមកវិញ, ស្រាប់តែឃើញកងទ័ពខុនបែនស្ទុះដេញស្រូចូលមក, ខុនបែន ក៏ជិះសេះតួចក្កាត់តាមច្រកក្តិតម្រង់មកដល់ ៗ គៀន-អ៊ុយ ក៏ទាល់ផ្លូវបញ្ឈរសេះនៅទីនោះ ។

ខុនបែនស្រែកថា នែគៀនអ៊ុយ ! អ្នកឯងអស់កម្លាំងទិងគប្រិះរិះគិតហើយ, អ្នកអើយ ! អ្នកឯងកុំខំប្រឹងទៅដល់ណា ខ្ញុំអ្នកធ្លាប់មានតម្រិះប្រាជ្ញា តទ្បូរមកអស់ច្បំដៃ បានសេចក្តីលំបាកដល់ទីនេះហើយ ម្តេចទៀយមិនមកទទួលបំណុះចូលយើងតែម្តងទៅ តើនឹងខំនៅធ្វើអ្វីទៀត ? គៀនអ៊ុយឮសព្ទហើយ ក៏ឲ្យតឹងចង្អៀតក្នុងឧរា គិតថា: ខ្ញុំអញ វេលានេះ នៅក្នុងកណ្តាប់ដៃគេ មិនដឹងជានឹងរដោះខ្លួនទៅខាងណា នឹងថយក្រោយដោយភាលាការ, គួនហ៊ិននៅស្លាក់ជាប់មាំមួនណាស់, ឃើញថាកម្លាំងអញនឹងប៉ះ ក៏អស់ណាស់ទៅហើយ, បើនឹងចូលទៅជាឈ្លើយខុនបែនក្នុងវេលានេះ ក៏នឹងរួចអាយុជីវិតប្រាកដ, តែនឹងមានទិន្នាថា ខ្ញុំអញជាអ្នកក្បត់និងម្ចាស់របស់ឯង, ខ្ញុំអញពេញជាជាតិទាហាន គួរធ្វើឲ្យមានកេរ្តិ៍ឈ្មោះជាក់ស្តែងតទៅមុខចុះ, លុះគិតដូច្នោះហើយ គៀនអ៊ុយ

កំលោតចុះពីលើខ្នងសេះ ប្រញាប់ដៃចាប់គ្រឹបហូតឡើង នឹងអារ-កខ្លួនឯងសម្លាប់ ។

ខ្ញុំបេនក៏ស្ទុះទៅប្រញាប់ដោយកម្លាំងភ័យ ព្រោះអាល័យស្តាយតម្រិះប្រាជ្ញា និងវិជ្ជាថ្វីដៃខៀនអ៊ីយណាស់, ក៏លើកដៃទះដណ្តើមយកគ្រឹបពីខៀនអ៊ីយបាន ហើយមានវាចាលួងលោមថ្នមចិត្តទៅខៀនអ៊ីយថា ខ្លួនយើងនេះ តាំងពីព្រះចៅឡៅពីមិនទាន់យកមកទំនុកបម្រុងនៅឡើយ, អ្នកអើយ យើងក៏នៅជាមនុស្ស កម្សត់ទុគ៌តណាស់, តែចិត្តរបស់យើងគិតស្វែងស្វះរកមិត្រសម្លាញ់ ដែលមានសិល្បវិជ្ជា ក៏មិនបានជួបប្រទះនឹងអ្នកឯណា ដែលមានសតិបញ្ញាមុតមាំ, ទើបតែថ្ងៃនេះ ជាបុណ្យព្រេងមកដឹកនាំឲ្យជួបប្រទះនឹងអ្នក, យើងក៏ពេញចិត្តស្ម័គ្រ ស្រឡាញ់ហាក់ជាតិលោហិតនឹងគ្នា, គួរតែអ្នកនឹងមានមេត្រីស្នេហាដល់យើងវិញ នឹងបានរួមចិត្តស្រឡាញ់ជួយធ្វើការទំនុកបម្រុងផែនដី ឲ្យបានសេចក្តីសុខតទៅ, កុំឲ្យមានកេរ្តិ៍អាស្រូវថា មានតម្រិះវិជ្ជា ជាសេនាទាហានហើយ មិនសម្តែងនូវគុណវិជ្ជានោះឲ្យសមតាមប្រាជ្ញា ។

(នៅមានត)

# រឿង

# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

## របស់លោក រ៉ាប៊ិន្ទ្រណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សរល់

(តមកពីឆ្នាំ ១៩៦៩)

## វគ្គទី ៣៨

នៅក្នុងពេលកន្ទុយរូមកហើយនេះ តើនាងកញ្ញា ហិមណាលិនី ធ្វើអ្វីខ្លះទៅ ?

នៅពេលរសៀលមួយនោះ លោកតាអាណាដាបាប៊ូឡើងទៅរកកូន តែមិនឃើញ គាត់សួរអ្នកបម្រើថា នាងទៅណា ? - វាឆ្លើយថា - នាងឥតចេញទៅណាទេ ។ បារម្ភណាស់លោកតាយើងខំឡើងហួតទៅលើដំបូលផ្ទះ ។ ដំនៅខែសិសិរផ្លូវហើយគ្រះសៀក បក់មកពីទិសនេះម្ដង ពីទិសនោះម្ដង ។ នាងហិមណាលិនីនៅអង្គុយតែម្នាក់ឯង នៅត្រង់មុំនៃដំបូលដែលគ្របពីលើជណ្ដើរ ។ លោកតាអាណាដាបាប៊ូទៅឈរពីក្រោយខ្នងនាង តែនាងមិនបានដឹងទេ ។ យូរបន្តិចមក លោកយកដៃទៅដាក់លើស្មានាង នាងភ្ញាក់ព្រឺត ហើយអៀនឡើងមុខក្រហម ។ លោកតាក៏ទម្លាក់ខ្លួនអង្គុយនៅក្បែរនាងមួយសន្ទុះ ទើបផ្ទុះវាចាថា :

–ហ៊ឺ ! កូនអើយ បើម្តាយកូនឯងនៅទៅ ក៏គ្រាន់ ឪពុកនេះបានការអ្វីទៅ . . . ។

ឮសម្តីឪពុកនិយាយត្អូញត្អែរបែបនេះ នាងហិមណាលិទីភ្ញាក់សតិអារម្មណ៍ហើយងាកមកសម្លឹងមុខលោកតាដែលពេញទៅដោយស្បែកជ្រីវជ្រួញ ។ ឱ ! មែនហើយ ឪពុកនាងមានទឹកមុខព្រួយណាស់ ដោយសារតែព្យុះសង្គ្រាម ដែលបានបណ្តាលឡើងនៅក្នុងទ្រូងនាងហិមណាលិទីនេះតែម្តង ។ លោកតាចេញចាស់សម្បើមណាស់ ក្នុងរយៈពេលដ៏ខ្លីនេះ ។

ក្នុងពេលដែលកូនស្រីគាត់មានទុក្ខព្រួយ លោកតាចំប្រឹងជួយរកមធ្យោបាយនឹងសម្រាលទុក្ខនាងខ្លាំងណាស់ តែលុះដល់គាត់ឃើញការព្យាយាមរបស់គាត់ គ្មានប្រសិទ្ធិភាពទៅវិញ គាត់ក៏ត្រឡប់ជាទឹកស្តាយខ្លោចប្រពន្ធគាត់ ។ នាងហិមណាលិទីក៏ដឹងដែរ ហើយនាងតែងតែបន្ទោសខ្លួននាងថា មិនគួរអ្វីនឹងនាំឲ្យគិតតែពីរឿងវេទនារបស់នាងនេះសោះ ។ ពិភពលោកដែលពីមុនមកបានបិទភ្នែក ឲ្យនាងឃើញខុស ឥឡូវនេះប្រែជាបញ្ចេញភាពពិតច្បាស់នៅចំពោះភ្នែកនាងហើយ នាងនឹកខ្មាសអើយសែនខ្មាស . . . . គួរអ្វីទៅយកស្បៃនៃអនុស្សាវរីយ៍បែបនេះមករុំខ្លួនឲ្យជាប់ ! អស់រយៈពេលយ៉ាងយូរ នាងចំយកមានៈចិត្តហែកចំលាយចេញអំពីស្រោមទុក្ខ ហើយគ្រវាត់ចោលទៅឲ្យឆ្ងាយអំពីខ្លួន ។

— ពុក ! ម៉ែចៅទៅកន្លែងទុកពុក សុខសប្បាយទេឬ ? (នាងនឹកសួរសុខទុក្ខឪពុក) ។

— របស់ពុក បើពីខាងរូបកាយ ពុកគ្មានឈឺអ្វីទាំងអស់ កូន តែពុកមិនសប្បាយចិត្ត នឹងឃើញកូនឯងចេះតែព្រួយ មនុស្សប្រែបពុក ដាក់អីមកក៏ចេះតែទ្រាំបានដែរ តែពុកបារម្ភក្រែងកូននៅក្មេងធន់នឹងទុក្ខមិនបានណា ។

— ពុក កាលដែលម៉ែខ្ញុំស្លាប់នោះ តើខ្ញុំអាយុប៉ុន្មាន ?

— មិនទាន់ទាំងពេញបីឆ្នាំល្អផង កាលនោះកូនឯងទើបតែនឹងរៀននិយាយ ពុកចាំបានថា កាលនោះ ដោយបាត់ម្តាយយូរពេក កូនឯងសួរពុកថា ម៉ែទៅណា ? ពុកបានប្រាប់កូនថា "ម៉ែកូនទៅផ្ទះលោកតាកូនទៅហើយ ប៉ុន្តែតាមពិតគឺម្តាយកូនជាកូនកំព្រាឪពុកតាំងតែពីតូចម្ល៉េះ តែកូនមិនយល់ពាក្យដែលឪពុកនិយាយទេ កូនអូសដៃពុកឲ្យដើររកម៉ែឲ្យកូន ។

ឱ ! កូនអើយ ព្រះជាម្ចាស់លោកបានទុកឪពុកឲ្យនៅជាមួយកូន តែឪពុកចេះត្រឹមតែស្រឡាញ់កូនប៉ុណ្ណោះ តែជួយអ្វីកូនមិនបានសោះ ឥឡូវនេះដែលកូនមានវ័យល្មមដឹងការពក់ជ្រៅ កូនយល់ទេថា កាលបើមានទុក្ខព្រួយដល់ស្លាប់ឬរស់ បុរសជាឪពុកអ្នកជាមនុស្សខ្មៅ ហើយទាល់មធ្យោបាយ ដូចជាកូនក្មេងយ៉ាងនោះដែរណា ។

លោកតាលើកដៃញ័រ ៗ ទៅអង្អែលក្បាលកូន ។ នាងហិមណា

លិទីចាប់ដៃឪពុកមកផ្ដាប់នឹងដៃខ្លួន ហើយពោលថា :

—ខ្ញុំមិនស្ដាយទេឪពុក តែខ្ញុំនៅនឹកឃើញ កាលដែលម៉ែខ្ញុំនៅរស់នៅឡើយនោះ នៅពេលថ្ងៃត្រង់ គាត់ចូលចិត្តសម្រាន្តមើលសៀវភៅ ខ្ញុំមិនចង់ឲ្យគាត់អាន ខ្ញុំចេះតែទៅទាញសៀវភៅចេញពីដៃគាត់ ។

ឪពុកនឹងកូននាំគ្នារំលឹករឿងអតីតកាល នៅលើលានជំបូលផ្ទះតែពីរនាក់យ៉ាងស្ងាត់ បង្ហាញឲ្យឃើញនូវសេចក្ដីស្នេហារវាងឪពុកនឹងកូនស្រីកំព្រានោះយ៉ាងណា ? ។ នៅពេលដែលអ្នកទាំងពីរនិយាយគ្នា ក្លួចភាពអ៊ូអរនៃទីក្រុងធំ ស្បៃរាត្រីកាលសន្សឹមចុះគ្របព្រះធរណីបន្តិចម្ដងៗ សន្សើមត្រជាក់ក៏មកដល់ព្រម បីដូចជាបានណាត់គ្នា ។

គេឮសូរជើងជោ ដេន្ទ្រាឡើងជណ្ដើរ ។

លោកតានឹងកូនឈប់និយាយគ្នាភ្លាម ។

—ឥឡូវហ្នឹង ហ៊ិមណា លិទីគេយកលានជំបូលផ្ទះធ្វើជាកន្លែងទទួលភ្ញៀវវិញទៅហើយ !

ជោ ដេន្ទ្រានិយាយបណ្ដើរ ដើរតម្រង់ទៅនាងបណ្ដើរ ។

ជោ ដេន្ទ្រា មិនសប្បាយចិត្តនឹងឧប្បត្តិហេតុ ដែលបានកើតឡើងក្នុងផ្ទះរបស់អ្នក អ្នកហាក់ដូចជាធ្លាក់ទឹកចិត្តសម្បើមណាស់ ស្ទើរតែទ្រាំរស់នៅក្រោមដំបូលផ្ទះនេះតទៅទៀតមិនបាន ក៏ប៉ុន្តែ អ្នកក៏មិនចង់ចេញទៅជួបមិត្តឯក្រៅនោះដែរ ព្រោះថា តែលេចមុខអ្នកទៅកន្លែងណាមុខ

ជាមានមនុស្សសួរអំពីរឿងហេតុ ដែលបណ្ដាលឲ្យខានរៀបមង្គលការនាង ហិមណាលិនីនោះមិនខាន ហើយបើប្រសិនជាអ្នកត្រូវទៅផ្ទះញាតិមិត្តខាន មិនបាននោះ អ្នកច្រើនតែនិយាយថា :

— ប្អូនខ្ញុំវាធ្វើអ្វីចេះតែជ្រុល ហើយតែបណ្ដោយឲ្យស្រីក្រមុំអានរឿង ប្រលោមលោកអង់គ្លេសច្រើនពេកហើយ មុខជាបែកប្រាជ្ញ . . . . ។

លោកតាអាណាដាបាប៊ូ ឃើញទឹកមុខជេដ្រានាមិនស្រួល ក៏ ប្រញាប់យកខ្លួនពាំងក្លាម ។

— ពុកទេតើ ដែលនាំហិមណាលិនីមកកេកទីស្នាក់ និយាយគ្នាពេះង នៅកន្លែងនេះ ។

តែកាលណាជេដ្រានានិយាយបន្ទុះបុកពញ្ញចិត្តនាង លោកតា អាណាដាបាប៊ូ យកខ្លួនពាំងពារជានិច្ច ។

- បើពុកនិយាយគ្នានៅឯក្រោមមិនបានឬ ? បានជានាំគ្នាមកជជុំ ឯលើដំបូល ជេដ្រាក្ដៅទឹងឪពុកចេះតែយកខ្លួនរង ក៏ស្រែកឲ្យខ្ទះ ទៅ បើឃើញវាឆ្កួតហើយមិនគិតមើលវាឲ្យជា ទៅជារឹតតែនាំឲ្យវា ឆ្កួតថែម បើពុកធ្វើបែបហ្នឹង មានតែពុកចង់ដេញខ្ញុំចេញពីផ្ទះ ទឹកតែគេ លើកមកអស់ហើយ ត្រៀមចាំឯក្រោមឯនោះ តើវាចាំឲ្យទឹកតែហួរចូល ពែងខ្លួនវាឬ ? បានជាជ្រះហ្នឹងហើយ នៅអង្គុយមើលមេឃមើលផ្កាយធ្វើ ព្រងើយយ៉ាងហ្នឹង ?

លោកតាអាណាជាប៉ាប៉ូឃើញកូនស្រីអៀនឡើងមុខក្រហម គាត់ខំបកខ្លួនពាំងពារម្ដងទៀត ។

- ទេ នៃវ៉ាថ្ងៃនេះ ពុកដូចជាមិនឃ្លានអីទេណា ។

- ចឹងហើយនាំគ្នាធ្វើស៊ីទាំងអស់ទៅ ។

- ចុះខ្ញុំបានអីទទួលទាន ខ្ញុំលេបស្រលៈមិនឆ្អែតទេពុក ។

- មិនមែនអញចង់ធ្វើស៊ីទេ តែពីយប់មិញ អញដេកមិនបាន បានជាថ្ងៃនេះ អញមិនសូវឃ្លានអីសោះ ម្យ៉ាងទៀត បើដេកមិនបានទៅហើយ អត់អាហារបន្តិចទៅ ក៏វាមានទៅស្លាប់ឯណាក្លាម ?

តាមការពិត គឺមិនមែនលោកតាមិនឃ្លានទេ តែគាត់រវល់តែនឹកអំពីអនុស្សាវរីយ៍ផ្សេងៗក៏ធ្វេសជ្រុលទៅ ។

ពេលលោកតាចុះតាមកូនប្រុសលោកមក អាក់ស្នាយត្រៀមខ្លួនចាំនៅតុទឹកតែជាស្រេចទៅហើយ លុះក្រឡេកឃើញលោកតាទិនទាំងហាម-ណាលីទ គេស្ទុះក្រោកគោរពគាត់ ថៃបទាំងនិយាយទៅកាន់ជាជន្រ្ទា :

- មិត្ត ខ្ញុំចង់លាឯងសិនហើយរី ។

- កុំអាលសិន ប្រញាប់អ្វីម៉្លេះ អាក់ស្នាយ ។

- ញ៉ាំទឹកតែមួយពែងសិន (នាងយាត់) ។

ពុទ្ធានបាំងណាលីទយាត់អាក់ស្នាយ អ្នកទាំងអស់គ្នាទទួល ។ គ្រាន់តែពួកនាងយាត់ អាក់ស្នាយទម្លាក់ពែងភ្លាម ហើយតបថា:

- ខ្ញុំទទួលទានអស់ពីរពែងរួចហើយ តែបើនាងឃាត់ មានអី . . ?

កញ្ញាឮហើយ ញញឹម ។

– លើកនេះជាលើកដំបូង ដែលខ្ញុំសុំឃាត់អាក់ស្ហាយឯង ។

– ពិតហើយ ( អាក់ស្ហាយឡើយ ) ហើយខ្ញុំនេះជាមនុស្សប្រកបដោយសុភនិច្ច័យល្អណាស់ បានជាមិនប្រកែកនឹងឱកាសល្អ ដែលហុចមកឲ្យខ្ញុំនៅពេលនេះ ។

- អើបើឯងចេះត្រៀមខ្លួនចាំទទួលឱកាសល្អយ៉ាងនេះ តើឯងត្រូវរកលោកគ្រូណាឲ្យសូត្រជយន្តោឲ្យឯង ?

ថ្ងៃនោះ ការជជែកគ្នាលេងមានដំណើររអឹករពាយ សប្បាយរីករាយដូចដើម នាងហិមណាលិនីដែលគេខានឮសើចសប្បាយពីប៉ុន្មានខែមកហើយ ក៏ស្រាប់តែសើចសប្បាយដូចធម្មតាវិញ ។ លោកតាក៏រីករាយហាក់ដូចដកដង់ចេញពីដើមទ្រូង ដោយឃើញកូនចៅគាត់ចំអន់គ្នាលេងសើចលាន់ ៗ គេនិយាយចំអន់គាត់អំពីរឿងថ្នាំគុលិកា ពីរឿងអ្វីផ្សេង ៗ ដែលគាត់ធ្លាប់តែទិក គាត់ចង់នៅសើចសប្បាយជាមួយនឹងគេឲ្យបានយូរបន្តិច តែនាងហិមណាលិនី មានការរវល់ក៏សុំចេញទៅ ។ អាក់ស្ហាយនឹកឃើញរឿងដែលខ្លួនបានសន្យាថា ទៅជួបនឹងគេ ក៏សុំលាចេញជាបន្ទាន់ទៅដែរ ។

–ពុក (ៈជាជេរ្ទ្រាចាប់និយាយ ពេលដែលនៅតែពីរនាក់និងឪពុក)

គួរតែយើងប្រញាប់ ឲ្យហ៊ាមណាលិនី រៀបការទៅកុំបង្អង់ ។

លោកតាងើបមើលមុខកូនប្រុសគាត់ធ្វើមុខថែបស្រឡាំងកាំង តែជោរជេន្ត្រាមិនញញើតសោះ គេចាប់និយាយបន្ត ។

- ពុកអើយ គេនាំគ្នានិយាយសំអុយពីយើងច្រើនណាស់ ខ្ញុំម្នាក់ឯងមិនអាចទប់ទល់នឹងសម្ដីអ្នកផងទាំងអស់បានទេ ដើម្បីឲ្យគេយល់ច្បាស់នោះ ខ្ញុំមិនខ្លាចនឹងពុះពារទេ ប៉ុន្តែដឹងជារឿងពិតនោះ វាយ៉ាងម៉េចខ្លះ បើខ្ញុំបាទមិនដឹងដែរ តែខ្ញុំពិបាកនឹងទ្រាំបិទមាត់គេណាស់ ហើយបើប្រសិនជាយើងចាប់វារៀបការឲ្យរហ័សទៅ ពាក្យមនុស្សក៏ស្ងប់ឯងទៅដែរ បានជាខ្ញុំចង់ឲ្យវាការឆាប់ ៗ ទៅ នៅចាំដល់ណាទៀត ។

– ចុះឯងចង់ឲ្យវារៀបការជាមួយនឹងអ្នកណា ?

– នៅក្រោមមេឃលើដីនេះ មិនមែនមានប្រុសតែម្នាក់នេះទេ បើរកបន្ទាស់មួយទៀតភ្លាម ៗ គឺជាវាមិនងាយពិតហើយ តែបើរើសយកអាក់ស្ហាយតែម្ដងទៅ វាចង្រៃអ្វី ? អាក់ស្ហាយជះមនុស្សងាយពត់សោះ បើតាមខ្ញុំធ្លាប់ស្គាល់ យើងប្រើឲ្យវាធ្វើអ្វី វាមុះជាមិនប្រកែកឡើយ ពុកមើលតែរឿងចាំគុលិកាដឹងហើយ ពុកឲ្យវាលេប វាលេបភ្លាម បើពុកប្រើឲ្យវារៀបការ មុខជាវាទទួលភ្លាមមិនខានឡើយ ។

– ឯងឆ្កួតក្បាលហើយឬ? ជោរជេន្ត្រាឯងមិនដឹងថាហ៊ាមណាលិនីមិនត្រូវការវាទេឬ ?

- ឥឡូវពុកនៅឲ្យតែស្ងៀមទៅបានទេ ទុកឲ្យខ្ញុំទៅនិយាយនឹងវា ។

- ទេ ! ជោជេន្ទ្រា ពុកមិនពេញចិត្តនឹងឲ្យឯងទៅនិយាយនឹងវាបែបហ្នឹងទេ ឯងមុខជាទៅធ្វើឲ្យវាតែក្ដៅក្រហាយទៀតហើយ ទុកឲ្យវានៅស៊ីចិនសិនទៅចុះ កូននិងវាបានជួបនឹងការពិសោធមួយយ៉ាងវេទនាទៅហើយក្នុងរឿងស្នេហា តើបង្ខំឲ្យវារៀបការភ្លាមម្ដេចបាន ?

- ខ្ញុំក៏ឥតចង់បង្ខំវាដែរ ណ្ហើយមិនអីទេពុក ខ្ញុំចាំប្រាប់បន្ដិចទៅទៀតចុះ ។

ជោជេន្ទ្រាមានសន្ដានចិត្តរហ័សហើយក្ដៅណាស់ តែធ្វើការអ្វីចង់តែឲ្យឃើញភ្លាមៗ ដូច្នោះហើយ បានជាគ្រាន់តែចេញផុតពីឪពុកភ្លាម អ្នកឡើងទៅជួបនឹងនាងភ្លាម ហើយប្រាប់នាងថា អ្នកមានការចង់និយាយនឹងនាងបន្ដិច ។

ឮបងនិយាយដូច្នោះ នាងនឹកភ័យបុកពោះក្ដុក មិនដឹងជាបងមានការអ្វីនិយាយហ្នឹង នាងដើរចូលទៅក្នុងសាឡុង ហើយត្រៀមខ្លួនចាំស្ដាប់បង ។

- អូនឯងមានសង្កេតឃើញពុកបែបដូចជាមានសុខភាពមិនធម្មតាឬទេ ( បងផ្ដើមនិយាយ ) បើស្ដាប់តាមសម្ដីនេះទៅ គឺថាជោជេន្ទ្រាចង់ទម្លាក់កំហុសទៅលើនាង ព្រោះថាមកពីនាងហ្នឹងហើយ បានជាលោកតាព្រួយពាល់តែចង់ទៅជាឈឺ នាងដឹងខ្លួនទុនមុខចុះ យកដៃច្បិតជាយ

គាវមិនធ្វើយសោះ :

ជោរដន្ត្រានិយាយថែមទៀត :

— ការដែលហួសទៅហើយឈប់នឹកនាវាទៀតទៅ តែបបេសតែគិតនាំឲ្យខូចប្រយោជន៍តែតែង បើអូនឯងចង់ឲ្យពុកឈប់ព្រួយចិត្ត ទាល់តែអូនឯងដកចិត្តឲ្យផុតពីរឿងមុន កុំឲ្យសល់មួយសរសៃណាសោះទើបបាន ថាហើយអ្នកបង្អង់ចាំស្តាប់ចម្លើយពីនាង ហើយសម្លឹងមុខនាងមិនដាក់ភ្នែកសោះ នាងធ្វើយទាំងអៀនអន់ថា :

— ខ្ញុំមិនត្រឡប់ទៅក្រោយវិញទេ ពុកកុំព្រួយបារម្ភនឹងខ្ញុំអី ប៉ុន្តែមានរឿងផ្សេងទៀត ដែលមិនអាចធ្វើឲ្យពុកភ្លេចបាន ។

— ចុះឲ្យខ្ញុំធ្វើម្តេច ?

— មានមធ្យោបាយមួយល្អ ដែលយើងគួរយកមកអនុវត្តន៍ ។

នាងយល់ថា បងចង់និយាយមកពីអ្វីណាស់ទៅហើយ តែនាងធ្វើពើ។

—បើអីចឹងមានតែនាំគាត់ធ្វើដំណើរទៅលេងឯណា បានបីបួនខែទៅ កាលណាយើងត្រឡប់មកវិញ យើងក៏ភ្លេចរឿងរ៉ាវទាំងប៉ុន្មាន អស់ទៅដែរ ។

— អូនឯងមើលជម្ងឺហើយហ្នឹង ជាមិនជាប់ទេ ពេតគាត់នឹងជាជាច់លុះត្រាតែគាត់ដឹងច្បាស់ថា ខួរក្បាលអូនឯងឈប់ខ្វល់ ។ តាំងពីនោះរហូតមកដល់ថ្ងៃនេះ គាត់នៅគិតតែពីរឿងនេះសោះទៅហើយបានជា

គាត់បេះតែមួយថ្ងៃ គាត់មួយថ្ងៃ គោរយ៉ាងហ្នឹង ។

នាងហិមណាលីទី ហូរទឹកភ្នែកក្រោក នាងយកដៃជូតយ៉ាងរហ័ស ហើយសួរទៅវិញ ៖

- ចុះបងឲ្យខ្ញុំធ្វើម្ដេចទៅ ?

- បងដឹងថាអូនឯងពិបាកចិត្តខ្លាំងណាស់ហើយ ប៉ុន្តែ បើអូនឯងចង់ឲ្យយើងទាំងអស់គ្នាសប្បាយចិត្តផង ត្រូវអូនសុខចិត្តរៀបការឲ្យឆាប់ទៅ ។

ឮពាក្យថារៀបការ នាងវែបនឿង រកពាក្យឆ្លើយមិនរួច ជេដ្ឋាខ្ជិលចាំស្ដាប់យូរ ក៏និយាយបន្តទៅទៀត ។

- គ្រាន់តែរឿងប៉ុណ្ណឹង អូនធ្វើឫកដូចជាធ្លាក់កំមួយសន្ធឹកលើខ្លួន ខ្លះអ្នកស្រីដែលគេជួបប្រទះនឹងរឿងដូចអូនឯង មុនអូនឯងទៅទៀត តែគេមានចិត្តក្លាហាន បេះកាត់ចិត្ត ទៅយកប្ដីមួយទៀតយ៉ាងករន្ទើយ ។ តើវាបានប្រយោជន៍អ្វីខ្លះទៅ នឹងដាក់ខ្លួនជាក្អកអង្រួញ ហើយមើលទៅលើផែនដីហាក់ដូចជាគ្មានមនុស្សដទៃរស់នៅ ទៅនៅ អង្គុយ បម្រុំសំឡឹងផ្កាយលើមេឃតែម្នាក់ឯងលើដំបូលផ្ទះនោះ តើបានប្រយោជន៍អ្វីទៅទៀត នឹងយកអនុស្សាវរីយ៍អាចម៍ជ្រៃនោះ ទៅតម្កល់ទុកថ្វាយបង្គំ ដូចព្រះពុទ្ធនោះ រឿងអាម៉ាសមុខ វានឹងផ្ដល់ឲ្យយើងទាំងអស់គ្នាណា៎ អូនឯងយល់ទេ បើមានអាក្មេងណាល្អគួរសម ព្រមការនឹងវាទៅ កុំបណ្ដោយខ្លួនឲ្យធ្លាក់ជា

ពាសីទុក្ខនោះ ។

នាងហិមណាលិនីមិនមែនល្ងង់ ដល់ទៅមិនដឹងថា កើតទុក្ខជាការឥតប្រយោជន៍នោះទេ ហើយការដែលបងស្ដីបន្ទោសទាំងប៉ុន្មាន គឺដូចចិត្តនាងគិតទាំងអស់ ទើបនាងឆ្លើយថា :

– តើខ្ញុំមានដែលនិយាយថា ខ្ញុំមិនត្រូវការអ្វី ៗ លើផែនដីនេះក្រៅពីរូបកមេស្ហ ពីកាលណា ហើយពីថ្ងៃណាដែលបងបានឮខ្ញុំនិយាយថា ខ្ញុំឈប់យកប្ដី ?

– អើ បើឯងមិនមានបំណងពីចឹងទេ ឆាប់ទទួលព្រមរៀបការទៅ រឿងហ្នឹងស្រេចនូវចិត្តឯងទេ បើឯងចង់បានព្រះឥន្ទ្រធ្វើប្ដីនោះ ឯងមុខជានៅក្រៅហើយ ព្រោះធម្មតាមនុស្សក្នុងលោក កម្រណាស់ដែលចង់បានអ្វីបានហ្នឹងដូចចិត្តនោះ ម៉្លោះហើយត្រូវតែដើរតាមព្រេងសំណាងទៅ បើព្រហ្មលិខិតលោកទម្លាក់អ្វីមកឲ្យ ត្រូវតែទទួលហ្នឹងទៅណា៎ ធ្វើម្ដេច ?

–បងឯងមិនត្រូវព្រមានខ្ញុំដល់ម្ល៉េះទេ (នាងខឹងណាស់ទាំស្រែកឲ្យបងវិញ) ខ្ញុំមិនដែលប្រាថ្នាអ្វីក្រៅអំពីវាសនារបស់ខ្ញុំទេ ហើយក្នុងរឿងជីវិតរបស់ខ្ញុំទៀត ក៏ខ្ញុំមិនដែលបញ្ចេញយោបល់ខ្ញុំប្រាប់បងថាយ៉ាងម៉េច ៗ ដែរ ។

– ឯងមិននិយាយចេញមែន តែបងចេះមើលណា៎ បើគ្រាន់តែគេនិយាយលេងពីរឿងកំប៉ុកកំប៉ុក ដោយស្មោះត្រង់សោះ ឯងតាំងចិត្តស្អប់

ធ្វើមិត្តភក្តិយកតែមែនទែន ហើយអូនឯងហ៊ានបញ្ចេញសេចក្តីទោមនស្ស គ្មានញញើតចិត្តមិត្តភក្តិបន្តិចសោះ  តែអូនឯងត្រូវដឹងច្បាស់ថា  ក្នុងបណ្តាមិត្រទាំងប៉ុន្មានដែលធ្លាប់ចុះឡើងស្និទ្ធស្នាលនឹងយើងនោះ  មានមិត្រម្នាក់ដែលមានចិត្តស្មោះនឹងយើងគ្រប់កាលវេលា  ទោះនៅពេលសប្បាយក្តី  នៅពេលយើងមានទុក្ខក្តី  ព្រោះហេតុនេះហើយ បានជាបងស្រឡាញ់រាប់អានគេ ហើយបើប្រសិនណាត្រូវរកប្តី ដែលចេះធ្វើឲ្យប្អូនរស់នៅក្នុងសុភមង្គលគ្រប់ពេលវេលានោះ  ប្អូនរកឃើញភ្លាមទៅហើយ មិនបាច់បងចង្អុលប្រាប់ទេ  តែបើអូនចង់យកតួឯកក្នុងរឿងប្រលោមលោក . . . ។

ធាងស្ទុះក្រោកឈរភ្លាម ហើយតបថា :

– ខ្ញុំសុំចិត្តទៅបង កុំនិយាយឲ្យខ្ញុំបែបនេះទៀត តែពុកឲ្យខ្ញុំរៀបការនឹងអ្នកណា ខ្ញុំបំពេញចិត្តគាត់ភ្លាមឥឡូវ គ្មានបង្អង់ទេ ។

ឮប្អូនឆ្លើយដូច្នេះ ដោះដន្ត្រាបែបអន់ទឹង ហើយនិយាយស្រួលទៅរកប្អូនវិញ ។

– ណ្ហើយកុំខឹងនឹងបងអីអូនអើយ  បងដឹងហើយថាតែកាលណាមានរឿងអ្វីមួយ ធ្វើឲ្យបងចង្អៀតខួរក្បាល បងចេះតែរាក់ហើយ នឹកឃើញអ្វីថាហ្នឹងហើយ ។ យើងធ្លាប់រស់នៅជាមួយគ្នាតាំងពីតូច បងដឹងចិត្តអូនហើយគឺអូនពាចតែមាត់  តែសន្តានចិត្តអូនជាមនុស្សចេះ

ស្គាល់រាក់ជ្រៅ ដឹងខុសដឹងត្រូវដកប ហើយបងដឹងថាកូនស្រឡាញ់ ហើយថ្នមលោកប៉ាណាស់ ។

ថាហើយភ្លាមអ្នកចេញទៅរកឪពុកភ្លាម ឃើញលោកអង្គុយសំកុកក្នុងបន្ទប់ ទឹកស្ដាយក្នុងចិត្តតែម្នាក់ឯង ដែលមិនបានឃាត់ជាដេទ្រា ហើយបណ្ដោយវាឲ្យទៅស្រដីផ្ដេសផ្ដាសឲ្យទាន លោករៀបចំនឹងចេញទៅឃាត់ ស្រាប់តែឃើញគេដើរចូលមក និយាយបណ្ដើរថា :

– ពុក ហាមណាលីនសុខចិត្តរៀបការហើយ ពុកច្បាស់ជាយល់ថាខ្ញុំទៅបង្ខំវាហើយហ្នឹងថែ ប៉ុន្តែគ្មានសោះទេពុក បើប្រសិនជាពុកប្រាប់វាថាពុកចង់ឲ្យវារៀបការជាមួយនឹងអាកស្មាយតែម្ដងទៅ ប្រាកដជាវាមិនប្រកែកទេ ។

– ចុះហេតុម្ដេចបានជាត្រូវឲ្យពុកប្រាប់ថាពុកចង់ ។

– ព្រោះវាមុខជានឹងមកសួរយោបល់ពុកឥឡូវនឹងហើយ បើពុកមិនហ៊ានថាទេ ពុកអនុញ្ញាតឲ្យខ្ញុំនាំពាក្យពុកទៅប្រាប់វាភ្លាមឥឡូវទៅថា. . . ។

– កុំអី អញចេះនិយាយខ្លួនអញដែរ ប៉ុន្តែហេតុអ្វីក៏បង្ខំវាខ្លាំងម្ល៉េះ បើពន្យារពេលពីរបីថ្ងៃទៅមិនបានទេឬ ?

– តែពុកយល់ មុខជាខកការទៀតហើយ ។

តាមធម្មតារៀងមក តែជាដេគ្រាថាយ៉ាងដូចម្ដេច គ្មានអ្នកណាទទឹងតាស់ឡើយ សូម្បីតែលោកតា ក៏ទ្រង់ញញើតគេដែរ គាត់យល់ស្របតាមណាស់ទៅហើយ តែគាត់ធ្វើជាថាឲ្យពនព្យារពេលបន្តិចទៅ ។

– អើមិនថ្វីទេ ! ចាំពុកនិយាយនឹងវា ។

– ទេ ចាំដល់ណាទៀត . ពុកត្រូវទៅនិយាយនឹងវាឥឡូវនេះទើបបាន វានៅចាំពុកក្នុងសាឡុងឯណោះ ។

– បើអីចឹង ឯងនៅចាំពុកនៅទីនេះ ទុកឲ្យពុកទៅនិយាយនឹងវា តែឯងបានហើយ ។

ពេលដែលលោកតាដើរចូលទៅ បន្ទប់សាឡុងដ៏ងងឹតស្លូវ ប៉ុន្តែលោកតាអាចមើលឃើញភង់មនុស្ស ធ្វើកាយវិការព្រិល ។ ហើយព្រួសម្លេងបែបដូចជាថ្ងូរ ។ និយាយមករកគាត់ ។

– ចង្កៀងរលត់អស្ចារ្យញុំមិញពុក តើត្រូវហៅក្មេងឲ្យមកអុជឡើងវិញឬ ទុកអ៊ីចឹងចុះពុក ? លោកយល់ច្បាស់ថា ចង្កៀងមិនមែនរលត់ខ្លួនវាទេ ហើយក៏ឆ្លើយតប ៖

– មិនបាច់ទេកូន យើងគ្មានត្រូវការមើលអ្វីទេ ?

នាងក៏ក្រោកឡើង ជួយនាំឪពុកអោកខ្នង ហើយនិយាយទាំងបួហ្ន ។

–ពុក ! ពុកធ្លាប់ដឹងចិត្តខ្ញុំស្រាប់ហើយ ពុកតែងតែថាកូនជាក្មេង

បេះដូងការខុសត្រូវ តែកាលណាពុកពេញចិត្តឲ្យកូនធ្វើអ្វី តើកូនដែលមិនស្តាប់បង្គាប់ពុកម្តងណាទេ ? និយាយបានតែប៉ុណ្ណោះ នាងអួលដើមកចង់យំ លោកចង់បណ្តោយតាមចិត្តកូនទៅទៀត កុំឲ្យតែនាងយំ ។

— ទេកូន ! ទេសោះ ពុកមិនដែលបង្ខំឲ្យកូនធ្វើអ្វីទេ ? ព្រោះកូនដឹងចិត្តពុកណាស់ ពុកមិនដែលហាមាត់ប្រើកូនទាន់ទេ . . . នុកូនហើយបើប្រសិនជាពុកមាត់ទិញ ពុកឲ្យតែឲ្យកូនជួបតែនឹងសេចក្តីសុខសប្បាយអស់មួយជីវិតកូនណា ព្រោះកូនមិនដែលធ្វើឲ្យពុកអាក់ចិត្តបន្តិចណាទេ ។

— ពុកមិនចង់ឲ្យខ្ញុំទៅជាមួយពុកតទៅទៀតទេឬពុក ? បើមិនបានអីកំពុកខ្ញុំឲ្យនៅជាមួយពុកចាំផៅជេត្រា គេរៀបការប្រពន្ធទៅចុះ បើខ្ញុំចេញទៅហើយ មានអ្នកណានៅបម្រើពុក ។

— ពិតហើយកូន ពុកចង់ឲ្យឯងនៅជាមួយពុកណាស់ អ្នកណាចង់ឲ្យកូនបែក ។

— ងងឹតពេកណាស់ពុក ចាំខ្ញុំទៅកេះគ្រឿងឲ្យអុជចង្កៀង . . . នាងដើរចេញទៅយកបានចង្កៀងមួយ មកដាក់ក្នុងបន្ទប់ ហើយយកសារ-ពត៌មានមកអានជូនឪពុកស្តាប់ ប៉ុន្តែលោកតាចេញទៅជួបនឹងផៅជេត្រាទៅហើយ ព្រោះគាត់ចង់ទៅប្រាប់កូនប្រុសគាត់ថា គាត់កើតឱកាសមិនបាននឹងនិយាយទេ ចាំស្អែកទៅចុះ ប៉ុន្តែដោយគេខ្លាចផៅជេត្រាខឹងហើយចូលទៅនិយាយដោយខ្លួនគេតាំងកម្រោល ដូចមុនទៀតគាត់ក៏

ចេះតែនិយាយបណ្ដោយតាមសំនួរជោដេគ្រាទៅ ។ គេសួរគាត់ថា "ពុកនិយាយរួចហើយឬនៅ ?..." ។ គាត់ថា និយាយហើយ គេសួរទៀតថា វាព្រមឬទេ? គាត់ឆ្លើយវាមិនថាអីដែរទេ វាងស្ងើរ ៗ ។ ប៉ុន្តែមួយរំពេចនោះ ជោដេគ្រាស្ដីគាត់ភ្លាមឡើងថា :

— ខ្ញុំទៅប្រាប់អាក់ស្លាយសិន ឲ្យវាដឹងផង ។

— ទេកូន កុំអាលសិន កុំអាន់អាលទៅប្រាប់វាឲ្យដឹង ឯងដឹងទេ ប៉ុន្មានដងហើយដែលឯងចេះតែប្រញាប់ ៗ នោះវានាំឲ្យស្កុនការអស់យើង ទៅលេងកុំសិន ចាំត្រឡប់មកវិញសឹមប្រាប់វា ។

ជោដេគ្រាមិនស្ដាប់លោកតាទេ ស្ទុះដើរចេញទៅផ្ទះអាក់ស្លាយ ភ្លាមឃើញអាក់ស្លាយកំពុងមើលសៀវភៅ ជោដេគ្រាចូលទៅដល់កន្ត្រាក់សៀវភៅពីដៃអាក់ស្លាយបោះចោល ៖

— នែ! ទុកអាសៀវភៅនេះទៅ ត្រូវតែថ្ងៃកំណត់ការសិន ។

— ពុកធ្លាអើយ! អាក់ស្លាយ ។

(នៅមានត)

# ល្បើកសីលប្រាំ

## របស់ ឧកញ៉ាព្រះឃ្លាំង នង

សហ. លី - ណាមតេជ ចម្លងផ្ទៀងផ្ទាត់

អត្ថបទ "ល្បើកសីលប្រាំ" នេះ ជាស្នាដៃរបស់ឧកញ៉ាព្រះឃ្លាំង នង លោករៀបរៀងឡើង តាំងពីក្នុងរជ្ជកាលព្រះករុណាព្រះបាទសម្តេចព្រះអង្គ ឌួង ។ ដោយមានបំណងចង់រក្សា និងផ្សាយនូវស្នាដៃកវីឯករបស់ខ្មែររូបនេះ យើងក៏បានចម្លងចេញពីសាស្ត្រាស្លឹករឹត ហើយផ្ទៀងផ្ទាត់តម្រូវអក្ខរាវិរុទ្ធ ចុះផ្សាយជូនសាធារណជន ។

ថ្ងៃទី ១២ ធ្នូ ១៩៦៩

| | | |
|---|---|---|
| បាណាតិបាត | នាអ្នកទេសាទ | ចិត្តពោរពើកចង់ |
| ពិឃាដម្រឹគា | មច្ឆាទ្វិបទ | មនុស្សសត្វឲ្យបង់ |
| | ឲ្យបាត់ជន្មា | ។ |
| អ្នកនោះនឹងទៅ | រងបាបក្តាត់ក្តៅ | លំបាកទៅនា |
| សញ្ជីពនរក | ចល់ទុក្ខឈឺផ្សា | ទុរនទុរា |
| | រូបរងយូរក្រៃ | ។ |
| យម្ពបាលពោះ | ទៅកន្ទើនស្ទោះ | ធុរពេះក្បៀណក្បយ |
| ហើយរស់រូបវិង | កំដឹងកិតភ័យ | ជាវិលមកញ |
| | ដល់មាត់រណ្តៅ | ។ |

យម្ពបាលបរ ដោមដាក់ទឹងស្នរ មួលបួកដែកក្តៅ
ដាក់ទឹងលំពែង ស៊កសែងដោលទៅ ក្នុងទីរណ្តៅ
ភ្លើងភ្លឺពុំក្សាន្ត ។

កំណត់ជន្មា នរកនោះហា រយឆ្នាំប្រមាណ
គិតគណនាឆ្នាំ ត្រូវប្រាំបួនលាន មនុស្សនេះទើបបាន
មួយថ្ងៃនរក ។

លង់លុះរដោះ ពីនរកនោះ មកមិនដែលសុខ
កើតជាមច្ឆា មានទាជ្រូកស្រុក គេកាប់សាច់លក់
ប្រាំរយជាតិជាក់ ។

ទៀតទើបកើតជា មនុស្សមានទោសា គេបាញ់គេចាក់
គេដោតគេកាប់ សម្លាប់ឥតអាក់ ប្រាំរយជាតិជាក់
ពិតពុំសុខអង្គ ។

ទើបយកជាតិជា មនុស្សមានរោគា ដំបៅពកយួង
ជាមនុស្សគមគាក់ កែកខ្វាក់ខ្វិនខ្វង់ ក្ងែងក្ងង់
គួរអប្រិយ ។

បើបានសក្តិបុណ្យ ត្បិតផលជាតិមុន បានសាងមកក្តី
ពៀរកម្មកត្តា ឲ្យអាយុខ្លី ពុំយឺនជីវី
ជីវិតដល់ចាស់ ។

ទោះទុក្ខធ្វេសធ្វើ កាយកម្មបាបបើ បោះបង់ក្រឡាស់
ក្រឡាប់លែងលះ ប្រែប្រះរហ័ស ដឹងដោយធម៌ច្បាស់
គន់គិតយង់យល់ ។

ខ្លាចបាបខ្មាសបាប វៀសវាកជកប ជីវិតសត្វសល់
ពិតពុំពណ៌នា រក្សាតម្កល់ ចិត្តចាំសីលផល
បាណាតិបាត ។

បានទៅកើតនា សួគ៌ាតុមហា- រាជិកាជាតិ
ជាអគ្គទេវបុត្រ បរិសុទ្ធស្អាត ស្ថិតលើប្រាសាទ
ប្រាំពីរយោជន៍គត់ ។

ស្រីទេពកញ្ញា ប្រាំរយអគ្គា បម្រើបាទបត់
ចូលបង្គំគាល់ រៀងរាល់ប្រាកដ ប្រកបកំណត់
កំណាន់សព្វថ្ងៃ ។

ប្រាំរយឆ្នាំគត់ ទើបទេពច្យុត មកកើតនៅញ
ត្រកូលក្សត្រិយក្សាន្ត សន្តានថ្លាថ្លៃ រូបពងល្អក្រៃ
មានលក្ខណាក្តាត់ ។

មានកម្លាំងលន់ មានចិត្តទោរទន់ ប្រណីទុក្ខសត្វ
មានគូនមានចៅ ញាតិផៅពុំព្រាត់ ពុំប្រាសខ្វាយខ្វាត់
ជាសុខដល់ចាស់ ។

ពុំផលក្សិណក្ស័យ　ជីវិតប្រល័យ　ដោយគ្រឿងសហាស
បានពិពារពេក　អនេកច្រើនណាស់　ឥតទុក្ខទោសទាស់
　ឥតព្យាធិរោគា ។
ឥតមានសត្រូវ　កំណាចព្យាចព្យូវ　បៀតបៀនបំណ្ហា
អាយុយឺនយូរ　បរិបូណ៌ជន្មា　នេះផលបាណា-
　តិបាតប្រហាន ។
អទិន្នាទានា　មនុស្សលួចទ្រព្យ　គេគិតចង់បាន
បំបាត់បញ្ឆោត　បំភោតបំពាន　បំពារកាន់មាន
　យសសក្តិខូចខំ ។
លុះលែងជាតិទៅ　នរកនាមហៅ　កាឡសូត្រអស់យម-
ក្បាលចាប់ចង　ផាក់ផងដាល់ដំ　ឈើផ្សាពេកពុំ
　សុខសោយទុក្ខា ។
ទើបយកបន្ទាត់　ដែកដុតមកផ្ទាត់　សុខសព្វកាហោ
ខ្ទះយករណារ　មកអារអង្គារ　ពុះពីសិរសា
　ទល់ទុក្ខទោរទន់ ។
ឈាមហូរស្រស្រាក់　ស្រែកយំឥតអាក់　កិតភ័យភាំងកាន់
នៅនានរក　រងទុក្ខកំណាន់　កំណត់មួយពាន់
　ឆ្នាំទើបរដោះ ។

មួយពាន់ឆ្នាំត្រែ- ត្រឹង្សរើបមួយថ្ងៃ មានកេនោះ
យូរពាន់ប្រមាណ លុះបានរួចហ្នោះ ពីនរកនោះ
មកជាប្រែតបាន ៗ

កម្ពស់ត្នោតលៃ រូបអាក្រក់ក្រៃ រកស៊ីស៊ីគ្មាន
ស៊ីសឹងតែលាមក ជាទុក្ខអត់ឃ្លាន ប្រាំរយជាតិបាន
មកកើតជាមនុស្ស ៗ

កំសត់ពិបាក អត់ឃ្លានតោកយ៉ាក ទុគ៌តទុភិស
ដើរសូមទានស៊ី ឥតគេសប្បុរស ក្សិណខ្សត់របស់
ប្រាំរយជាតិទៀត ៗ

មានទ្រព្យតិចតួច ចោរចាំលបលួច បានបាត់បង់ស្បៀត
កើតជាខ្ញុំគេ ម្ចាស់ជេរវាយទៀត បាបគ្បិតបៀនបៀត
ទ្រព្យអ្នកដទៃ ៗ

បើអ្នកឯណា មួយមានប្រាជ្ញា ជវៃពន់ងវៃ
វៀរចាកអទិន្នា- ទានជាបច្ច័យ មគ្គផលអាស្រ័យ
សមានបរិភោគ ៗ

វៀរជំនួញប្រាំ ប្រការចង់ចាំ ចិត្តបេះអពោគ
អត្យាស្រ័យយល់ ទៅដល់បរលោក ខ្លាចកម្មទុក្ខសោក
ជិតដល់អាត្មា ៗ

អ្នកនោះនឹងបាន ទៅកើតនៅស្ថាន សួគ៌ត្រៃត្រិង្ស
មានទេពអប្សរ បរិវារកញ្ញា មួយពាន់ហោមជា
បរិវារគង់គាល់ ។

ឋិតវិមានខ្ពស់ ប្រមាណទ្វាទស យោជន៍យល់ឆើតឆាយ
ត្រផែតត្រដួច គន្ធូបរៀងកល់ សឹងមានពិព័រណ៌
ពិពិធរចនា ។

សោយសុខប្រមាណ មួយពាន់ឆ្នាំបាន ទើបយកជាតិជា
ត្រកូលក្សត្រិយ៍ក្សាន្ត មែនមានប្រាជ្ញ ធនធានសក្តា
ច្រើនពាន់ពេកក្រៃ ។

ទើបយកជាតិជា ត្រកូលនៃមហា សេដ្ឋីប្រពៃ
មានទ្រព្យរបស់ សក្តិយសថ្លាថ្លៃ ឥតអ្នកដទៃ
ណានឹងបៀតបាន ។

ទោះបោះខ្ជីខ្ជាំង សត្រូវបៀតចាំង លាយលោកធនធាន
ចិត្តចង់វាទ ប្រមាទពុំបាន ហេតុនោះអ្នកមាន
ផលលះលោកលែង ។

កាមេសុមិច្ឆា ទោះអ្នកឯណា ចិត្តនោះវង្វេង
លួចភរិយាគេ ឥតឯមានក្រែង ស្រីផិតប្តីឯង
អំពើឆោតឆ្គុត ។

អ្នកនោះទឹងទៅ ទល់ទុក្ខនិត្យនៅ សំឃាជនរក
ទាំងប្រុសទាំងស្រី ឥតបីមានសុខ រូបរឹងទោសទុក្ខ
លំបាកមហិមា ៗ

យមបាលបាន ដាវដេញឲ្យពាន ឡើងដើមរកា
ដែកដាលដាក្តឹង ខ្ពស់ឡើងកណ្តា មួយយោជន៍បន្ទា
ច្រើនប្រុះប្រាងប្រូង ៗ

ស្រីពានឡើងមុន មុតខ្លួនទូរទ់ ស្រែកយំលូង
ប្រុសឡើងតាមទៅ មុតដៅដើមទ្រូង ធ្លុះថ្មើមបេះដូង
ឈាមហូរសស្រាក់ ៗ

មានក្អែកសព្រាល ប៉ុនដំរីសារ ចឹងខាំក្តោក់
ជើងដែងហួរហែក ត្មាក់ក្អែកធុកធាក់ ចឹកពោះធ្លុះធ្លាក់
ខ្លួនដល់ដេកដាល ៗ

ធុរនេះជាភ្លើង ភ្លឺផ្លេកឡប់ឡើង ក្រោងក្រាយរង្គាល
នេះខ្លួនក្រៀមក្រំ ទើបយមបាល បរបណ្តេញដាល
ឲ្យឡើងទៀតទៅ ៗ

ស្លាប់មួយថ្ងៃពីរពាន់ ដងដោយកំណាន់ គិនិតអសៅ
អសារអសោច លះទ្វោចក្តាត់ក្តៅ ពីរពាន់ឆ្នាំទៅ
រសៅរិះទោសទុក្ខ ៗ

អាយុពីរពាន់ ឆ្នាំទិព្វទ្វជាន់ យាមាសួគ៌សុខ
ទើបបានមួយថ្ងៃ មួយយប់នរក រងទុក្ខទោសទុក្ខ
យោនយកជាតិជា ។

សត្វតិរច្ឆានធុក គេគ្រៀវធ្វើទុក្ខ ទោសតាមវេរ
កាយកម្មអគ្គឯង វង្វេងមោហា ប្រាំរយជាតិជា
ទុក្ខទៀងអប្រិយ ។

កើតជាខ្ទួខ្ទួយ ប្រាំរយជាតិហើយ កំព្រាឥតប្តី
ដោយទូវវៀវវី- បាកពីបុរី បុរមជាតី
បាបជាទម្ងន់ ។

ទើបកើតជាប្រុស អាក្រក់ទូវយស មកមានប្រពន្ធ
ចោរចិត្តជាផិត ពុំគិតបាបបុណ្យ ហេតុពៀរពីមុន
បរទារកម្មគេ ។

បើអ្នកណាមាន វិញ្ញាណញេយ្យញាណ ប្រុងប្រាជ្ញប្រុះថ្ងៃ
ចិត្តចេះចាំចៀស វៀសបានបែរ វៀរបាបកាមេ
សុមិច្ឆាចារ ។

អ្នកនោះនឹងទៅ សោយសម្បត្តិនៅ សុខសួគ៌យាមា
ស្ថិតលើប្រាសាទ ក្បាច់ស្អាតសោភា កម្ពស់គង្គា
យោគោណទ័យប៉ុយន៍ ។

ក្ដីផ្ដុកចិញ្ចាច ចិញ្ចែនត្រដាច ត្រដួចដោមដុង

មានទេពអប្សរ បវរគាល់គង់ ពីរពាន់សឹងទ្រង់

ឆោមឆាយវិសុទ្ធ ។

អាយុពីរពាន់ ឆ្នាំទើបគ្រប់គ្រាន់ ចាកចរច្យុត

យោនយកកំណើត មកកើតជាបុត្រ ក្សត្រិយ៍ថ្លៃវិសុទ្ធ

វិសេសប្រសើរ ។

ប្រកបក្រិយា ត្រឹមត្រូវលក្ខណា គាប់គួរមៀងមើល

ជាស្រីគ្រប់លក្ខណ៍ ឯកអគ្គប្រសើរ ទោះដេកទោះដើរ

សឹងជាសុខសល់ ។

មុសាវាទា ទោះអ្នកឯណា កុហកកាចកល

មានពាក្យរឹងរូស ប្រទូស្តកំហល់ កំហឹងកែរកល

កែកាចកិច្ចគេ ។

បញ្ឆុកបញ្ឆោត បញ្ឆៀងបំពោត បំពានវៀចវេរ

ពោលពាក្យកូតករ បង្ករស្រាលស្រែ ឲ្យបង់ទ្រព្យគេ

ឲ្យគេកើតទុក្ខ ។

អ្នកនេះនឹងទៅ ទល់ទុក្ខនិរ្យនៅ ពោរពនរក

បានបួនពាន់ឆ្នាំ រងកម្មពុំសុខ ព្រោះមាត់អាក្រក់

ពោលពាក្យមុសា ។

យមបាលយក ផង្កាប់ដៃកមក ដុតដកដីហ្គ
ឈាមហូរស្រោក កន្ត្រាក់អង្គា បោលចុះក្នុងមា
រណ្ដាធំក្រៃ ។

ប្រាំពាន់ឆ្នាំណា សូគិតុសំតា ទើបបានមួយថ្ងៃ
កោពេនរក រងទុក្ខរងភ័យ យំនយូរកម្រៃ
កម្ររដោះ ។

លុះរួចមកបាន កើតជាប្រេតប្រាណ អសោចស្អុយសោះ
កម្មកើតអគ្គី ដេះពីមាត់នោះ ស៊ីសឹងឈាមខ្ទុះ
ជាតិជាអាហារ ។

ទើបកើតជាមនុស្ស អាក្រក់ទុរយស មាត់វៀចថៃបធា
កើតជាមនុស្សល្ងង់ គថ្លង់ឥតការ ឥតកេរ្តិ៍អសារ
អាសោចពីមាត់ ។

បើអ្នកឯណា វៀរពាក្យមុសា រងវៀរគិតកាត់
កាន់សច្ចវាទី ស្រដីពាក្យសត្យ ទឹងបានសម្បត្តិ
សួនសោយសុខា ។

ពិភពតុសិត អាយុយឺនក្តាត់ បួនពាន់វស្សា
មានទេពអប្សរ បវរជីតា បួនពាន់ជាតិជា
បរិវារសព្វថ្ងៃ ។

ឋិតលើប្រាសាទ ប្រសើរស្អាងស្អាត សឹងកែវប្រពៃ
ខ្ពស់ម្ភៃប្រាំយោជន៍ ស្រោងស្រោចត្រៃលេប សុខសប្បាយក្រៃ
ឥតឯឧបមា ។

បានបួនពាន់ឆ្នាំ ទើបផុតសោតឋាំ ចុះមកកើតនា
ត្រកូលក្សត្រិយ៍ក្សាន្ត មែនមានប្រាជ្ញា ទើបទៅកើតជា
អ្នកប្រាជ្ញចេះធម៌ ។

មែនមានពាក្យសត្យ ពាក្យពិរោះក្លាត់ ចេះចាំអស់អាថ៌
ចំណោទប្រស្នា បញ្ញាសព្វសារ- ពើពុំទើសទាល់
ដល់ប៉ុនគេសើ ។

ស្រុកាមេរយា រមនុស្សផឹកស្រា ភ្លេចភ្លាំងស្មារតី
ក្រសាលជាល្បែង ពុំក្រែងពៀរពី- បាកបាបស្រដី
ពុំជឿធម្មា ។

ទើងធ្លាក់ទៅនៅ នរកជ្រាលជ្រៅ រូបរងវេទនា
ដល់ជាបនរក ទល់ទុក្ខមហិមា យីនយូរគណនា
ប្រាំបីពាន់ឆ្នាំ ។

ហេតុចិត្តរវើង ផឹកទឹកទន់ដែង ក្តៅក្តាត់ជាកជាំ
រលាករលុះ ពន់ពុះដោយកម្ម ប្រាំបីពាន់ឆ្នាំ
ខ្មានរើ ។

ទើបបានមួយថ្ងៃ　នរកយូរក្រៃ　លន់លុះឡើងពី
បាបបានកើតជា　យក្ខតិរ្យ　ជាមនុស្សអប្រិយ
សឹងឆ្កួតពុធ្យា　។

មានពាក្យអាសុរស　ពាក្យរឹងត្រគោះ　លលើលលា
អ្នកផងតិះដៀល　ជំទៀលនិន្ទា　ជាមនុស្សមោហា
ដួជាតិខ្ទួនខ្ទៅ　។

បើអ្នកឯណា　វៀរសេពសុព　នោះនឹងបានទៅ
សោយសុខស្ថិតស្ថាន　ពិមានសន្ទៅ　សឹងកែវទិព្យនៅ
និម្មានរតី　។

ឋិតឋានប្រាសាទ　សាមសិបយោជន៍ស្អាត　ប្រកបនឹងស្រី
ទេពអប្សរសួគ៌　គាប់គួរប្រាំបី　ពាន់ឆ្នាំទិព្វពីរ
នោះមកកើតជា　។

ត្រកូលមហាក្សត្រិយ៍　សេពសោយសម្បត្តិ　សម្បត្តិទេព
ស្ដេចស្ដែងចើនស្ថាន　មែនមានចេស្ដា　ប្រកបប្រាជ្ញា
ចេះចាំធម៌គាប់　។

មានចិត្តខ្លាចបាប　ខ្លាចពៀរជេរភប　មានស្មារតីខ្ជាប់
ជនប្រាជ្ញប្រុះ　ធ្លាស់ធ្មុះវៃឆាប់　ពាក្យពោលគំនាប់
គំនិតសោតជួន　។

អំពើចាំងប្រាំ ប្រការបួចាំ ចិត្តបេះគិតគន់
បង់បញ្ចវេក កម្មជាទម្ងន់ មិនមានមោះម-
ន្ទិលទាស់ទោសទុក្ខ ។

រក្សាសីលប្រាំ នេះនៃនឹងនាំ រួបរួមបានសុខ
ទៀងទាល់និព្វាន មិនមានគោតទុក ផុតពីនរក
សោយសួគ៌សម្បត្តិ ។

សម្បូណ៌បច្ចុប្បន្ន បុណ្យបានទ្រព្យធន់ ជួនទាំងមនុស្សស្រក
សិទ្ធិទីស្ថាន ស្ថិតប្រាណដុះខាត់ ខឹងខំកំចាត់
កំចាយបាបកម្ម ។

កម្មពៀរវៀរចេញ ចិញ្ចឹមបំណេញ បំណះបេះបាំ
បំណាចពោទស្សួរ សមគួរបរិកម្ម កម្មដ្ឋានចំណាំ
វិបស្សនាហោង ។

# រឿងខ្លី ៗ មានន័យវែង

## ដកស្រង់ពីអដ្ឋកថាជាតក

អ្នកនិពន្ធតែងសេចក្តី **ផល-ឌិត** នៅក្រុមជំនុំព្រះត្រៃបិដក

## ១- ព្រះទេពីពេជ្រ ភ្លេចផ្លែពុទ្រា

តែនាងរូបល្អដ៏មានភ័ព្វ    នាងធ្លាប់ក្រខ្សត់ដែរឬអ្វី ?
ឥឡូវសោយទ្រព្យភ័ព្វបុណ្យថ្មី    គួរអ្វីស្រីភ្លេចផ្លែពុទ្រា ។

មានស្ត្រីអ្នកផ្សារម្នាក់ ឈ្មោះនាងសុជាតា ជាស្ត្រីទើបនឹងពេញ-វ័យក្រមុំ មានរូបស្អាត តែងទូលកញ្ច្រែងផ្លែពុទ្រាដើរពាយនាយលក់តាមផ្លូវក្បែរព្រះរាជវាំង ។ ពេលមួយ ព្រះរាជាទ្រង់បើកបង្អួចដំណាក់ទតទៅឃើញ ក៏គាប់ព្រះរាជហឫទ័យ ទើបឲ្យរាជបុរសទៅស៊ើបដំណឹង, លុះដឹងថានាងនៅក្រមុំ ក៏ទ្រង់ឲ្យនាំនាងនោះមកអភិសេកជាឯកអគ្គមហេ-សី ប្រទានយសស័ក្តិយ៉ាងធំលើសព្រះស្នំទាំងពួង ។ នាងជាស្ត្រីដែលព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យណាស់ ទុកស្មើនឹងដុំពេជ្រដែលមនុស្សទូទៅពេញចិត្ត ។

សម័យមួយ ព្រះរាជាទ្រង់ទទួលដង្វាយផ្លែពុទ្រា ហើយនាយពិសេសក៏រៀបដាក់នឹងភាជន៍មាសថ្វាយទ្រង់សោយ ។ ពេលនោះ ព្រះនាង

សុជាតាអគ្គទេពី ស្ដេចឃើញផ្លែពុទ្រា ក៏សួរព្រះកជាថា ព្រះទេវៈ ! នេះជាផ្លែអ្វី មូលរលីង ពណ៌ក្រហមដូចជាដុំឈាម ដាក់ក្នុងភាជន៍មាសនេះ ? ។ ព្រះកជាទ្រង់ព្រះពិរោធ មានបន្ទូលថា នែនាងទេវី ! កាលពីមុន នាងមានក្បាលឥតម្កុដ, ស្លៀកកំណាត់សំពត់ចាស់, ដៃកាន់ទម្ពក់បេះផ្លែពុទ្រានេះដើរលក់, ភ្លេចហើយឬ ? នែស្ដ្រីថោកទាប នាងក្ដៅក្រហាយណាស់ មិនព្រមបេះរើកយកទឹងសម្បត្តិក្នុងរាជត្រកូលទេឬ ? អ៊ុយ! ពួកអាមាត្យ ចូរនាំស្ដ្រីនេះ ទៅទីកន្លែងដែលវាធ្លាប់បេះផ្លែពុទ្រាលក់វិញទៅ ! ។

កាលិង្គវគ្គ

## ២- សួនច្បារដែលស្វាស្រោចទឹក

ការធ្វើប្រយោជន៍នៃអ្នកល្ងង់ ពុំឈ្លាសក្នុងអត្ថនៃប្រយោជន៍
រមែងតែផ្ដល់ផលហិនហោច ដូចស្វាដែលស្រោចទឹកសួនច្បារ ។

មានស្វាជាច្រើន អាស្រ័យនៅក្នុងឧទ្យានមួយ ។ ថ្ងៃមួយ ជាថ្ងៃបើកឲ្យលេងមហោស្រព, នាយសួនច្បារ ចង់ទៅលេងកម្សាន្តមហោស្រពនឹងគេ តែរកអ្នកជំនួសពុំបាន ទើបទៅនិយាយនឹងស្វាជាមេហ្វូងថា នែ

សំឡាញ់ ! ឧទ្យាននេះ មានឧបការៈច្រើនណាស់ដល់ពួកអ្នក ព្រោះពួកអ្នក បានអាស្រ័យផ្លែឈើតូចធំ ទុំខ្ចី ក្នុងឧទ្យាននេះ ជារៀងរាល់ថ្ងៃ, ឥឡូវមានមហោស្រព, ខ្ញុំចង់ទៅលេងមហោស្រពនឹងគេ, ដូច្នេះ អ្នកអាចជួយធានាស្រោចទឹកកូនឈើក្នុងសួនឧទ្យាននេះ ទម្រាំតែខ្ញុំវិលមកវិញ បានឬទេ ? ៗ ស្វាមេហ្វូងក៏ទទួលព្រម ៗ ឧយ្យានបាល ក៏យកខ្សែយោង និងធុងរែក មកប្រគល់ឲ្យស្វា ហើយរៀបខ្លួនចេញទៅបាត់ ៗ ពួកស្វា ក៏នាំគ្នាដងទឹកស្រោចកូនឈើទាំងឡាយ ៗ រីឯស្វាធំ ឃើញដូច្នោះ ក៏ស្រែកប្រាប់ថា នែពួកស្វាទាំងឡាយ ! ឯងដឹងឬទេ ! ធម្មតាទឹក ជារបស់ដែលគេត្រូវតែចេះប្រើប្រាស់ដោយសំច័យ, ដូច្នេះ អ្នករាល់គ្នាកាលនឹងស្រោច ត្រូវដកពិនិត្យមើលឫសកូនឈើទាំងហ្នឹងជាមុន , បើឃើញកូនឈើណាមានឫសវែង ត្រូវស្រោចទឹកកូនឈើនោះឲ្យច្រើន , តែបើកូនឈើណាមានឫសខ្លីៗ , កូនឈើនោះត្រូវស្រោចទឹកបន្តិចៗបានហើយ កុំឲ្យប្រើទឹកខ្ជះខ្ជាយពេក ៗ ពួកពានរដោយបរិវារទាំងអស់ ក៏នាំគ្នាធ្វើតាមឱវាទនោះ ទាល់តែហិនហោចអស់កូនឈើមួយឧទ្យាន ៗ

អត្ថកាមវគ្គ

# ៣- ព្រៃពឹងខ្លា ខ្លាពឹងព្រៃ

រាជសីហ៍-ខ្លា-អើយ! អ្នកចូរមក! ទៅជ្រកក្នុងព្រៃធំនុះវិញទៅ!
កុំអ្នកឃាតព្រៃជាលំនៅ ព្រៃនឹងសូន្យទៅព្រោះឥតអ្នក "

មានរុក្ខទេវតាជាច្រើនអង្គអាស្រ័យនៅក្នុងព្រៃធំមួយ ៗ ក្នុងព្រៃនោះឯង មានខ្លាធំមួយនិងរាជសីហ៍មួយអាស្រ័យនៅដែរ ។ ពួកទេវតា បាននៅជាសុខសាន្តណាស់ ព្រោះពុំមានមនុស្សម្នាណាម្នាក់ ហ៊ានចូលទៅកាប់គាស់រំលំដើមឈើក្នុងព្រៃនោះសោះឡើយ ដោយខ្លាចរាជសីហ៍និងខ្លាធំទាំ ២ ។ ចំណែកខាងខ្លាធំនិងរាជសីហ៍វិញ កាលបើចាប់បានម្រឹគហើយទាំស៊ីរួច តែងបោះសាកសពឆ្អឹងសាច់ដែលជាសំណល់ (ពីវា) នៅដេរដាសក្នុងព្រៃនោះ ជាហេតុនាំឲ្យមានក្លិនស្អុយអសោចិ៍សាយភាយ ៗ ដោយហេតុនេះ ទើបទេវតាមួយអង្គ ពុំពេញចិត្ត ក៏ចូលទៅប្រាប់រុក្ខទេវតាពោធិសត្វថា បង់បណ្ដេញរាជសីហ៍និងខ្លាធំឲ្យចេញពីព្រៃនោះ ។ រុក្ខទេវតាពោធិសត្វតទល់ថា អ្នកកុំបង់ចិត្តធ្វើដូច្នោះ ព្រោះគឺសត្វទាំងពីរនេះឯងហើយ ជាអ្នករក្សាដើមឈើទាំងឡាយដែលជាវិមានលំនៅរបស់ពួកយើង ឲ្យបានបិតបេរបេកោល ជាសុខសាន្តរៀងមក ៗ រុក្ខទេវតាពាលពុំជឿតាម ក៏ទៅសម្ដែងឫទ្ធិបន្លាចរាជសីហ៍និងខ្លាធំឲ្យភ័យរត់ចេញបាត់ពីព្រៃនោះអស់ ។

មិនយូរប៉ុន្មាន, ពួកមនុស្ស លុះលែងជួបប្រទះ លែងឃើញដានជើង នៃសត្វទាំងពីរ ក៏សន្និដ្ឋានថា “សត្វទាំងពីរ ប្រាកដជាចេញពីព្រៃនោះទៅនៅទីដទៃអស់ហើយ» ទើបនាំគ្នាទៅកាន់ទី បម្រុងនឹងកាប់ឆ្ការព្រៃធ្វើស្រែចម្ការ ។ ឃើញដូច្នោះ ទេវតាពាល ក៏ស្លុតចិត្តភិតភ័យតិតស្តាយក្រោយ ទើបប្រញាប់ប្រញាល់ទៅស្វះស្វែងរកខ្លាធំនិងរាជសីហ៍ ហើយសំពះលន់តួ អង្វរករសុំឲ្យវិលទៅនៅព្រៃធំនោះវិញ ប៉ុន្តែ ពុំបានសម្រេចដូចបំណង ក៏ត្រឡប់មកវិញតែម្នាក់ឯងយ៉ាងអាម៉ាសមុខ ។ ទីបំផុត, ព្រៃនោះ ក៏ក្លាយទៅជាទីស្រែចម្ការអស់ ពុំមានសល់ ។

ឧរបានវត្ត

## ៤- បុរោហិត គំនិតបូរណី

បើខ្សែធ្នូដាច់គួរផ្លាស់ទៅ ព្រោះមានព្រៅមានអ្នកវេញ
ខ្ញុំនឹងលះលែងបូរណីចេញ មិនត្រូវដាវិញផ្ដូរប្ដោះដែរ ។

មានបុរោហិតម្នាក់ ឈ្មោះរុហក: និងភរិយា ឈ្មោះនាងបូរណី ។ ព្រះរាជា ទ្រង់សព្វព្រះរាជហឫទ័យ ក៏ទ្រង់ព្រះរាជទានសេះមួយយ៉ាងល្អ ដែលមានគ្រឿងប្រដាប់តាក់តែងជាស្រេច ។ បុរោហិត តែងតែជិះ

សេះនោះទៅគាល់ស្ដេច រៀងរាល់ថ្ងៃ ៗ កាលឃើញបុរោហិតនោះ ជិះសេះទៅដល់ទីណា ៗ , ប្រជាជនដែលនៅតាមដងផ្លូវកែងទីនោះ ៗ នាំគ្នាសរសើរគ្រប់មាត់ថា សេះនុះសមណាស់ ល្អណាស់! ៗ ថ្ងៃមួយ បុរោហិតនិយាយប្រាប់ភរិយាថា ភទអើយ! សេះយើងនេះ ពិតជាល្អណាស់ ឬទេជាមនុស្សម្នាគ្រប់ទីកន្លែង ចេះតែនាំគ្នាអួតសរសើរមិនដាច់សោះ ៗ ចំណែកនាងបូរណី ជាស្ត្រីចូលចិត្តលេងសើច ក៏និយាយតបទៅស្វាមីវិញថា បងអើយ! សេះនេះ វាល្អដោយសារគ្រឿងតាក់តែងរបស់វាទេ, បើពុំជឿ ចូរបងយកគ្រឿងប្រដាប់សេះនោះមកបំពាក់តាក់តែងខ្លួនបង ហើយបងដើរជើងបួនដូចសេះ តាមផ្លូវទៅ, មុខជាគេសរសើរបងថា ល្អជាងសេះនេះទៅទៀតពុំខាន ៗ បុរោហិតចម្កួត ឮដូច្នោះ ក៏ចង់ពិសោធតាមសម្ដីប្រពន្ធ ៗ លុះដល់វេលាទៅគាល់ស្ដេច, លោកក៏យកគ្រឿងប្រដាប់តាក់តែងសេះមកពាក់តែងខ្លួន រួចដើរជើងបួនដូចសេះ ឆ្ពោះទៅព្រះបរមរាជវាំង ៗ មនុស្សម្នាតាមដងផ្លូវ ឃើញបុរោហិតធ្វើដូច្នោះ ក៏អស់សំណើចសរសើរចំអកឲ្យថា យី! លោកអាចារ្យយើង ល្អណាស់ទ្រី! ៗ បុរោហិតល្ងើ នៅតែពុំដឹងខ្លួន ក៏ចូលទៅគាល់ស្ដេច ៗ ព្រះរាជាទ្រង់ទតឃើញដូច្នោះ ទ្រង់មានព្រះបន្ទូលថា ម៉េចក៏ចឹងលោកអាចារ្យ? លោកគ្រឡកចិត្តឬអ្វី? ឆ្កួតទេឬ? ៗ បុរោហិតអក់ពូ ដ្រប់មុខខ្មាសគេ ប្រញាប់ប្រញាល់បង្គំលា ត្រឡប់ទៅផ្ទះវិញ ដោយគិតទាំងកំហឹងថា ប្រពន្ធឯង វាលេងស្តីវាឲ្យ

ខ្លាសអស់ពួកមុខមន្ត្រី ចំពោះព្រះភក្ត្រស្តេច, អញត្រូវតែទៅសំពះវា ឲ្យអស់ដៃ ហើយលែងវាចោលជាដាច់ខាត ។ ប៉ុន្តែគំនិតរបស់បុរោហិត ពុំបានសម្រេចដូចបំណងទេ បែរជាបានស្រុះស្រួលគ្នាវិញ ដោយសារព្រះរាជាទ្រង់ធ្វើអន្តរាគមន៍សម្រុះសម្រួល ។

រុហកវត្ត

## ៥– សំពងមូសឯក បែកក្បាលឪ

មិត្រមែន ប៉ុន្តែល្ងង់ពេកក្លៃ អន់ជាងសត្រូវមានប្រាជ្ញា
ដូចកូនសំពងក្បាលបិតា ព្រោះល្ងង់គិតថាប្រហារមូស ។

នៅនាបច្ចន្តគ្រាម មានជាងឈើទំពែកម្នាក់ កំពុងតែអង្គុយឈូសឈើ ស្រាប់តែមានមូសដែកគោលមួយហើរមកទំលើក្បាលទំពែក ដែលរលីងដូចជាបាតផ្តិលខាត់ ហើយដោតចំពុះបោះបុកក្បាលទំពែកនោះយ៉ាងជ្រៅ ហាក់ដូចជាគេប្រហារនឹងលំពែងចំពុះទុង ។ ដោយឈឺធៀបខ្លាំងពេក, ជាងឈើខឹងខ្លាំងណាស់ ស្រែកប្រាប់ទៅកូនកម្លោះដែលកំពុងចាំងឈើពីក្រោយខ្នងថា "កូនឯង មើលមូសវាបុកក្បាលឪពុកឯណេះ! ប្រដៅវាឲ្យពុកផង" ។ កូនជាងឈើក៏និយាយតាំងមួម៉ៅថា "អាមូស

ចង្រៃនេះ ចាំមើលខ្ញុំប្រហារវាឲ្យដឹងដៃម្ដង" ។ ថាហើយ កូនជាងឈើនោះ ក៏លើកប៉ូវថៅយ៉ាងមុតរបស់ខ្លួន លបសសៀរទៅអែបពីខាងក្រោយខ្នងឪពុក ដោយគំនិតថា "នឹងប្រហារមូសកុំឲ្យវាហើរគេចទាន់" រួចក៏ពឹតសំពងកូសពីលើ ៗ ជាងឈើអភ័ព្វ ត្រូវក្បាលមួយប៉ូវថៅ បែកលលាដ៍ជាពីរ ដួលស្លាប់រំពេច ដោយសារតែកូនល្ងង់ហួសពេក ។ កូនល្ងង់ ត្រូវបង់ឪពុក កើតទុក្ខសង្រេង យំស្ដាយស្រណោះព្រោះគំនិតយោបល់ខុស ជាខាងក្រោយ ។

អត្ថកាមវគ្គ

## ៦– រឿងចចក ខកខ្លួន

ព្រាហ្មណ៍អើយ! អ្នកជឿពាក្យចចក ដែលផឹកស្រាខកនេះម្ដេចបាន
សូម្បីសំបកខ្យងក៏គ្មាន តើវានឹងមានប្រាក់ពីណា ។

នៅពេលពាក់កណ្ដាលអធ្រាត្រ មានចចកមួយ ចូលទៅក្នុងទីក្រុង ដើម្បីរកស៊ីត្រីសាច់ជាដើម ដែលជាសំណល់ អំពីសំណែនសែនព្រេន របស់អ្នកស្រុក ៗ លុះស៊ីហើយ វាផឹកសុរាដែលគេដាក់សែនទីងអំបែង ទាល់តែស្រវឹងងេងងោងពុំអាចវិលទៅព្រៃវិញបាន ក៏ដើរចូលទៅនៅសម្ងំ

លាក់ខ្លួនដេកលក់ ក្នុងទំពាំងមួយ ៗ លុះភ្ញាក់ពីដេក , ស្រាប់តែឃើញពន្លឺថ្ងៃចាំង ទើបដឹងថាខ្លួនដេកខក , ពុំអាចចេញទៅព្រៃក្នុងវេលានោះបាន ក៏សរសៀរចេញពីទីនោះ ទៅនៅក្នុងគ្រង់ទីចង្អៀតមួយទៀតក្បែរផ្លូវដែលគេដើរទៅដើរមកមើលពុំឃើញ ៗ វាពុំហ៊ាននិយាយនឹងមនុស្សណាម្នាក់ទេ ប៉ុន្តែ ដល់ឃើញព្រាហ្មណ៍ម្នាក់ដែលទើបនឹងលុបមុខថ្មី ៗ ដើរមក, វាក៏ចេញបង្ហាញខ្លួន រួចនិយាយថា លោកព្រាហ្មណ៍អើយ ប្រសិនបើលោកអាចនាំយកខ្ញុំទៅព្រៃដោយលាក់លៀម កុំឲ្យជនណាម្នាក់ឃើញបាន ខ្ញុំនឹងជូនប្រាក់ ២ រយកហាបណៈដល់លោក ៗ ព្រាហ្មណ៍ល្មោភព្វដួប្លោះ នឹកថា "អ៊ឺ! លាភអញដល់ហើយតើ!" ក៏ត្រេកអរទទួលព្រម ហើយទាញសំពត់ពានាយករុំបិទចចកនោះ ពុំឲ្យមនុស្សដទៃឃើញរួចបីឱបក្រសោបយកទៅដាក់ក្នុងព្រៃជ្រៅ តាមបញ្ជារបស់ចចក ៗ កាលបើព្រាហ្មណ៍បើកសំពត់ឲ្យចេញមកក្រៅហើយ , ចចក ក៏បង្គាប់ឲ្យព្រាហ្មណ៍លាតសំពត់បង់កនោះ ក្រាលសន្ធឹងលើដី រួចប្រាប់ថា សូមលោកជីកកាយដីត្រង់គល់ឈើនេះចុះ, ប្រាក់ពីររយកហាបណៈ យើងកប់ទុកនៅទីហ្នឹងឯង ៗ ដោយចិត្តល្មោភចង់បានពេក , ព្រាហ្មណ៍ក៏ខំប្រឹងជីកកាយតាមពាក្យចចក ៗ រីចចកឯណោះវិញ គាត់ឡើងអង្គុយគ្គុបលើសំពត់ដែលក្រាល រួចបញ្ចេញអាចមដង ទឹកមូត្រផង ដាក់លើសំពត់នោះ ៥ អន្លើ គឺ ត្រង់កណ្ដាល និងជាយសំពត់ទាំង ៤ មុម រួចបោលប្រើចក្លូលព្រៃបាត់ ៗ ព្រាហ្មណ៍ក៏ងើបមើលមកក្រោយ ក៏លាន់មាត់ថា

"ពុះ! អញចាញ់បោកអាសត្វកំហូចទេតើ !" រួចក៏ទាញសំពត់រុំត្រឡប់ទៅផ្ទះវិញ ទាំងក្តៅក្រហាយស្តាយគំនិតគិតខុស ។

ហំសិរគ្គ

## ៧- អ្នកសេះស គសេះខ្មៅ

ស្ទុះចូលគាក់ព្រោយកកេរគ្នា    អំពើផងភិស្មើឥតគក់ :
អាក្រក់ស្មើគ្នានឹងអាក្រក់    កោងកាចតម្រក់ស្មើកោងកាច ។

ថ្ងៃមួយ ពួកឈ្មួញសេះ នាំសេះប្រមាណ ៥០០ ក្បាល ពីស្រុកឧត្តរាបថ មកលក់នៅរាជធានីពារាណសី ។ ព្រះរាជាពារាណសី ទ្រង់បញ្ជាអាមាត្យធំម្នាក់ឲ្យទៅចាំទិញសេះ តែមុននឹងឲ្យទិញ ទ្រង់ពន្យល់ឧបាយថា ចូរប្រស្នែង បើកក្រោលបញ្ចេញមហាសោណ ជាសេះកាចរបស់យើង ឲ្យទៅដេញខាំកកេរព្រោយ យាយីសេះទាំងឡាយរបស់ពួកពាណិជ ឲ្យមានរបួសដំបៅ ឲ្យអស់កម្លាំងសិន សឹមទិញ ដើម្បីឲ្យបានតម្លៃថោក ។ មន្ត្រីនោះ ក៏ទៅធ្វើតាមព្រះរាជបញ្ជា ។ ពួកពាណិជ ឃើញអាកប្បកិរិយាដូច្នោះ មានសេចក្តីតូចចិត្តពន់ពេកណាស់ ទើបនាំគ្នាចូលទៅជួបនឹងលោកបុរោហិតរបស់ព្រះរាជាអង្គនោះឯង ហើយ

ជម្រាបទូលព្រឹត្តិការណ៍ដ៏ថោកទាបនោះ ។ បុរោហិត សួរពាណិជទាំង
នោះថា តើនៅក្នុងស្រុករបស់ពួកអ្នក មានសេះកាចខ្លះដែរឬ? ។ ពួក
ពាណិជជម្រាបថា មានសេះកាចហើយខ្លាំងពូកែមួយដែរ ឈ្មោះសុហ-
នៈ ។ បុរោហិត ក៏ពន្យល់ថា បើដូច្នោះ, លើកក្រោយ, ត្រូវអ្នកឯង
យកសេះកាចនោះមកផង ។ ពួកពាណិជ ក៏លាវិលទៅកាន់ស្រុកវិញ
ប្រមូលយកសេះបានមកលក់ឯក្រុងពារាណសីទៀត ដោយយកទាំងសេះ
កំណាចឈ្មោះសុហនៈនោះមកផង ។ ព្រះរាជាពារាណសី ទ្រង់ចាត់
វិធានការណ៍ដូចលើកមុនទៀត ។ អាមាត្យ ក៏បើកលែងសេះមហា-
សោណឲ្យចេញទៅ ។ ឯពួកពាណិជ ឃើញដូច្នោះ ក៏ស្រាយខ្សែ
សុហនៈលែងទៅដែរ ។ គ្រាន់តែឃើញមុខគ្នា សេះកំណាចទាំងពីរ
ក៏ស្រែកស្អុះចូលទៅចំព្រាវ ធាក់ប្រំគ្នា យ៉ាងសាហាវអស្ចារ្យ ប៉ុន្តែមិន
យូរប៉ុន្មាន គូប្រយុទ្ធទាំងពីរ ក៏បែរជាឈរស្ងៀម លិទ្ធគ្នា យ៉ាងស្និទ្ធ-
ស្នាលទៅវិញ ។ ឃើញហេតុបម្លែកដូច្នេះ ព្រះរាជាទ្រង់សួរបុរោហិត
ថា លោកអាចារ្យ! ហេតុអ្វីក៏សេះទាំងពីរដែលបញ្ចេញកិរិយាសាហាវ
រកគ្នា ហើយត្រឡប់ជាត្រូវគ្នាវិញដូច្នេះ ? ។ បុរោហិតក្រាបទូលថា
បពិត្រមហារាជ ! បានជាសេះកំណាចទាំងពីរនេះ បែរជាស្រុះស្រួល
នឹងគ្នាវិញដូច្នេះ មកពីសេះទាំងពីរ វាមានទម្លាប់មារយាទប៉ុនគ្នា មាន

ធាតុស្មើគ្នា ៗ តាំងពីពេលនោះមក ព្រះរាជាទ្រង់បញ្ជាឲ្យទិញសេះតាមដំណើរស្រួលបួល ដូចធម្មតាមុនវិញ ៗ

ទឡ្ហវិត្ត

## ៨- វាយស្គរ បន្លរចោរ

គួរវាយស្គរដែរ តែកុំរួស    វាយឲ្យជ្រុលហួស ក្រែងអាស្រូវ
ដូចកូនពុំជឿតាមពាក្យឪ    វាយស្គរតាមផ្លូវត្រូវបង់ទ្រព្យ ។

ក្នុងពេលមួយ ដែលគេបើកឲ្យលេងនក្ខត្តឫក្ស, មានបុរសវាយស្គរម្នាក់ នាំកូនទៅវាយស្គរក្នុងមណ្ឌលមហោស្រព ដើម្បីឲ្យបានថ្លៃឈ្នួល ៗ លុះអស់ពេលហើយ អ្នកម្ចាស់មណ្ឌលមហោស្រព ក៏ឲ្យប្រាក់ថ្លៃឈ្នួលយ៉ាងច្រើន ដល់ឪពុកនិងកូននោះ ៗ អ្នកទាំងពីរ លុះបានទ្រព្យច្រើនហើយ ក៏នាំគ្នាត្រឡប់ទៅផ្ទះវិញ ៗ ដើរមកដល់ដងព្រៃដែលមានចោរ ឪពុកនិយាយហាមកូនដែលកំពុងវាយស្គរឮសូរជាប់មិនដាច់ថា កូនឯង កុំវាយស្គរឲ្យឮសូរជាប់មិនដាច់អីចឹង ត្រូវវាយឲ្យឮសូរមួយ ៗ ឲ្យដូចជាស្គរអ្នកធំដើរផ្លូវវិញ ដើម្បីឲ្យពួកចោររត់គេចចេញឆ្ងាយពីផ្លូវយើងទៅ ៗ ឯកូន ពុំព្រមស្តាប់ពាក្យហាមរបស់ឪពុក ក៏ចេះតែវាយស្គរឲ្យឮសូរមិនដាច់

ដោយហេតុតែចិត្តជាប់អារម្មណ៍អរជ្រុលនឹងលាភដែលបានច្រើន ៗ ចំណែកពួកចោរ លុះឮស័ព្ទស្គរ, តម្បូង, នាំគ្នាគេចប្រាសចេញពីផ្លូវអស់ ដោយគិតស្មានថា ជាស្គរអ្នកធំដើរផ្លូវដែរ ប៉ុន្តែ ដល់ឮស្គរជាប់គ្នាមិនដាច់ ក៏យល់ថា ពុំមែនជាស្គរអ្នកធំទេ, ទើបនាំគ្នាទៅលបមើលយកការណ៍ ៗ លុះឃើញតែបុរស ២ នាក់ប៉ុណ្ណោះ ពួកចោរទាំងនោះ ក៏នាំគ្នាចូលវាយយកទ្រព្យអស់មួយរំពេច ៗ

អាសឹសវត្ត

## ៩– សំពងរុយខុសបែកច្រមុះម្តាយ

សត្រូវ ប៉ុន្តែមានប្រាជ្ញា ថ្លៃថ្លាជាងពាលអ្នកផ្គត់ផ្គង់
គួរមើលទាសីស្រីល្ងីតល្ងង់ ភ័យរុយបានបង់ជីវិតម្តាយ ។

មានស្ត្រីម្នាក់ ឈ្មោះនាងរោហិណី ជាទាសីរបស់សេដ្ឋី ហើយជាស្ត្រីកំព្រាឪពុក នៅតែម្តាយចាស់ ដែលនាងផ្គត់ផ្គង់ចិញ្ចឹមបម្រើសព្វថ្ងៃ ៗ ពេលមួយ នាងកំពុងតែបុកស្រូវ ស្រាប់តែម្តាយនាងដែលដេកឈឺដេក លើកូនពនមួយនៅជិតនោះ ស្រែកហៅថា កូនអើយ ! រុយពេកម្តាយច្រើនណាស់ ចូរកូនដេញឲ្យម្តាយផង ! ៗ នាងរោហិណីរឹងទឹងរុយ

ណាស់ ក៏លើកអង្រែដើរលបៗទៅ ហើយសំពងរុយដែលកំពុងទំលើច្រមុះម្តាយមួយអង្រែ យ៉ាងពេញទំហឹងដៃ ៗ យាយចាស់ឥតគិតសង្ខាក៏បែកច្រមុះប្រេកាច់ស្លាប់ភ្លាម ៗ កូនស្រីកម្លៅ ស្រែកទ្រហោយំក្រោយដោយពុំបានយល់ថា ការណ៍ហ្នឹងកើតដល់ម៉ែងសោះ ៗ

អត្ថកាមវគ្គ

## ១០ – តាបស ពស់ឫស្សី

បើគេប្រាជ្ញាការចម្រើន ជួយក្រើនរំឭកប្រយោជន៍ប្រាប់
អ្នកណាឥតចេសពុំជឿស្តាប់ គង់ស្លាប់ដូចតាបសពស់ឫស្សី ។

កូនពស់អាសិរពិសមួយ លូនតាមធម្មតារបស់វា ចូលទៅក្នុងអាស្រមបទនៃពួកតាបសមួយក្រុម ៗ តាបសមួយអង្គ ឃើញកូនពស់នោះ ជាប់ចិត្តស្រឡាញ់ ក៏ចាប់ពស់នោះ យកទៅទុកថែរក្សាឲ្យដេកនៅក្នុងបំពង់ឫស្សី ៗ ដោយការនៅអាស្រ័យក្នុងបំពង់ឫស្សី ទើបពស់នោះ មានឈ្មោះថា ពស់ឫស្សី , ហើយតាបស អ្នករក្សាពស់ឫស្សីនោះ ក៏បានឈ្មោះថា តាបសពស់ឫស្សី តរៀងមក ៗ តាបសឯទៀតៗ នាំគ្នាទៅនិយាយនឹងតាបសពស់ឫស្សីនោះថា លោកកុំចិញ្ចឹមសត្វអាសិរពិស

នោះឡើយ ពីព្រោះធម្មតារបស់អាសិរពិស រមែងពុំត្រូវការសេចក្ដីស្និទ្ធស្នាលទេ ។ តាបសពស់ឫស្សី ពុំជឿស្ដាប់ នៅតែស្និទ្ធស្នាលរក្សាពស់នោះដដែល ។

កន្លងមកពីរបីថ្ងៃ តាបសទាំងអស់ នាំគ្នាចេញទៅស្វែងរកផ្លែឈើក្នុងព្រៃឆ្ងាយ រហូតដល់កន្លែងមួយដែលបរិបូណ៌ដោយផ្លែឈើ ទើបនាំគ្នាសំចតនៅកន្លែងនោះ អស់ពេលបីថ្ងៃ ។ តាបសពស់ឫស្សី ក៏ទៅជាមួយនឹងតាបសទាំងពួងដែរ តែមុននឹងទៅ លោកបានយកពស់នោះទៅដាក់ក្នុងបំពង់ឫស្សីទុក ដោយសេចក្ដីស្រឡាញ់ដូចជាកូនបង្កើត , លុះត្រឡប់មកវិញ ដោយសេចក្ដីនឹករឭកពេក ក៏ប្រញាប់ប្រញាល់ទៅបើកឆ្នុកបំពង់ឫស្សី លូកដៃទៅស្រវាទាញពស់ ដោយពោលថា ហៃកូនសម្លាញ់អើយ ! អ្នកប្រហែលជាស្រេកឃ្លានខ្លាំងណាស់ហើយ មើលទៅ ! ។ ចំណែកពស់ឫស្សី អត់អាហារពីរបីថ្ងៃហើយ កំពុងតែទឹកខឹង ក៏ចឹកដៃតាបសឲ្យដល់នូវមរណកាល មួយរំពេច ហើយរលូនចូលព្រៃបាត់ទៅ ។

អត្តកាមវគ្គ

## ១១– ចចកបកវត្ត

បុគ្គលយកធម៌ធ្វើជាទង់ ដោយចង់ឲ្យគេជឿទុកចិត្ត
ហើយធ្វើអំពើទោសទុច្ចរិត វត្តនេះ បណ្ឌិតហៅវត្តថា ។

ចចកមួយ ឃើញកណ្ដុរមួយហ្វូង ដែលតែងតែនាំគ្នាដើររកស៊ីក្នុងព្រៃនោះ ក៏ប្រើស្មៀតឈរជើងម្ខាង ហាមាត់ បែរមុខឆ្ពោះទៅរកព្រះអាទិត្យ ដើម្បីជាឧបាយកលចាប់កណ្ដុរស៊ី ។ ឃើញដូច្នោះ, កណ្ដុរទាំងឡាយ គិតថា "ព្រះតេជព្រះគុណនេះ ពិតជាអ្នកមានសីលប្រាកដ" គិតហើយ កណ្ដុរមេហ្វូង ក៏ចូលទៅសួរចចកអំពីកិរិយាដ៏ចម្លែកនេះ ។ ចចកឆ្លើយថា យើងនេះ ឈ្មោះធម្មិក, ជើងយើងទាំងបួន កាលបើដាក់ចុះជាន់លើផែនដី, ផែនដីនឹងស្រុត, ដូច្នេះ បានជាយើងឈរតែជើងម្ខាងហើយហាមាត់លេបខ្យល់ ព្រោះយើងពុំបរិភោគអ្វី ក្រៅពីខ្យល់ឡើយ, ម្យ៉ាងទៀត ទំនងដែលយើងបែរមុខចំទៅព្រះអាទិត្យ ព្រោះយើងជាអ្នកធ្វើកិច្ចនមស្ការបករត្តចំពោះព្រះអាទិត្យ ។ កណ្ដុរទាំងឡាយ ឮដូច្នោះជឿជាក់ថា "លោកម្ចាស់នេះ ជាអ្នកមានសីលពិតមែន" ទើបនាំគ្នាទៅក្រាបប្រណិបត្តន៍ជារៀងរាល់ថ្ងៃ ។ ឯចចកវិញ តែងតែលបសង្គ្របចាប់ស៊ីកណ្ដុរដែលដើរលយក្រោយគេបង្អស់ ក្នុងពេលដែលកណ្ដុរទាំងនោះត្រឡប់ពីទីបានខ្លួនទៅវិញ រួចជូតមាត់ជូតកយ៉ាងស្អាត ទៅឈរធ្វើកិរិយាដូចមុនដដែល ។ លុះកន្លងយូរថ្ងៃមក, កណ្ដុរទាំងឡាយ កាលបើចេះតែរលស់អស់គ្នាជាលំដាប់ ក៏ប្រឹក្សាគ្នាថា ទីលំនៅយើងនេះ ពី-ដើមឡើយ បង្កៀតទើសគ្នាណាស់, ចុះឥឡូវនេះ ម្ដេចក៏ទូលាយល្វឹងដូចជាបាត់គ្នាអស់ជាច្រើនអំពីង ? ។

[នៅមានត]

## ផ្នែកកំណត់-ប្រវត្តិការណ៍

# លទ្ធផលនៃការប្រឡងប្រជែងខាងចំរៀងទម្លាប់
# នៅឆមាសទី ២ ឆ្នាំ ១៩៦៩

ក្រុមចំរៀងទម្លាប់ខ្មែរនៅពុទ្ធសាសនបណ្ឌិត្យមានសេចក្ដីរីករាយនឹងផ្សាយដំណឹងចំពោះព្រះតេជព្រះគុណ អស់លោកអ្នកជាសមាជិកហើយទាំងនិងបេក្ខជនទូទៅថា : នៅក្នុងឆមាសទី ២ ឆ្នាំ ១៩៦៩ កន្លងទៅនេះ ក្រុមចំរៀងទម្លាប់បានបើកការប្រឡងប្រជែងខាងចំរៀងទម្លាប់ខ្មែរ ២ មុខ គឺ "អំពីចម្រៀងប្រជាប្រិយ - ទោស និង ការផ្គងផ្គាតាមរបៀបបុរាណ" ដើម្បីប្រមូលឯកសារផ្នែកនេះមកតម្កល់ទុក សម្រាប់ធ្វើជាគោលចារិកនៃប្រពៃណីខ្មែរតទៅ ។ តាំងពីបើកសម័យប្រឡងប្រជែងមក មានបេក្ខជន បានផ្ញើអត្ថបទជាច្រើន មកចូលរួមប្រឡងប្រជែង ។ ក្រុមចំរៀងទម្លាប់បានពិនិត្យវិញ្ញាសាទាំងនោះយ៉ាងហ្មត់ចត់ ហើយបានសម្រេចលទ្ធផល ដូចតទៅនេះ :

## ១– អំពីចម្រៀងប្រជាប្រិយ

- រង្វាន់លេខ ១ លោក ជិម - ឈុំ ភូមិ និង សង្កាត់ បុស្សព្រៃ ស្រុកសណ្ដាន់ កំពង់ធំ "ឯកសារលេខ ៥៨-០៩១"

ត្រូវបានរង្វាន់ . . . . . . ១.០០០រ០០ ៛

- រង្វាន់លេខ ២ លោក ចាយ រិត គ្រូបង្រៀននៅ សាលាសុគន្ធបញ្ញា ហៅ វិហារត្រាញ់ សង្កាត់ព្រែកស្លែង ស្រុកកណ្ដាលស្ទឹង កណ្ដាល "ឯកសារលេខ១៦៨-០៩០"

ត្រូវបានរង្វាន់ . . . . . . ៨០០រ០០ ៛

- រង្វាន់លេខ៣ លោក ជីកា សាលី សង្កាត់ បឹងត្រាញ់ ស្រុកសំរោង តាកែវ "ឯកសារលេខ១៦៨-០៨១"

ត្រូវបានរង្វាន់ . . . . . . ៦០០រ០០ ៛

- រង្វាន់លេខ ៤ ភិក្ខុ ធុំ យី វត្តខារ សង្កាត់ព្រៃទឹង ស្រុកស៊ីធរកណ្ដាល ព្រៃវែង "ឯកសារលេខ ៦៨-០៨៩"

ត្រូវបានរង្វាន់ . . . . . . ៤០០រ០០ ៛

## ២- អំពីទោសនិងការផ្ដន្ទាទោសរបៀបបុរាណ

ក្នុងចំណោមឯកសារផ្ញើមកនេះ គ្មានឯកសារណាមួយល្អគួរឲ្យជាប់ លេខ ១ទេ ក្រុមជំនុំបានសម្រេចឲ្យត្រឹមតែរង្វាន់លេខ ៣ ចុះមក :

- រង្វាន់លេខ ៣ : លោក កុយ ហួត គ្រូបង្រៀន ធ្វើការនៅ សាលាម៉ាន់វ៉ៃ រលួស តំបន់អធិការកិច្ចបឋមសិក្សារលួស សង្កាត់ទឹង ស្រុកសូទ្រនិគមសៀមរាប "អក្ខរ" ឯកសារលេខ១៦៩-០១៦

ត្រូវបានរង្វាន់ . . . . ៦០០រ០០ ៛

-ឆ្នោតលេខ ៤ លោក ចាប រិត គ្រូបង្រៀននៅ សាលាសុគន្ធបញ្ញា "ពៅវិហារត្រាញ់" សង្កាត់ព្រែកស្ដង ស្រុកកណ្ដាលស្ទឹង កណ្ដាល "ឯកសារលេខ ៦៤-១០៦" ត្រូវបានឆ្នោត . . . . . . ៤១០.០០ ៛

ឆ្នោតទាំងនេះ ក្រុមចំរៀមទម្លាប់ បានចាត់ការផ្ញើទៅជូនសាម៉ីខ្លួន តាមរយៈប្រៃសណីយ៍និងទូរគមនាគមន៍ យ៉ាងស្រួលហើយ ។

ក្រុមចំរៀមទម្លាប់សូមថ្លែងអំណរគុណយ៉ាងស្មោះ ចំពោះព្រះតេជព្រះគុណ អស់លោកដែលបានយកព្រះទ័យ យកចិត្តទុកដាក់ ជួយរក្សាកេរ្តិ៍តំណាលរបស់ជាតិដ៏ថ្លៃថ្លាទាំងនេះ ឲ្យបានគង់វង្សតទៅអនាគត ។

ម្យ៉ាងទៀតនៅឆមាសទី ១ ឆ្នាំ ១៩៧០ នេះ ក្រុមចំរៀមទម្លាប់ បានបើកការប្រឡងពីមុខថ្មីទៀត គឺ :

១ – អំពីព្រលឹង

២ – របៀបផ្សំ ល្បិចនិងបច្ចេកទេសផ្សេង ៗ ក្នុងរបររបស់ខ្មែរ ។

ឯសេចក្ដីប្រកាសពីការប្រឡងប្រជែងនេះ មានពិស្ដារដូចមានចុះក្នុងទំព័របន្ទាប់ទៅនេះ ៖

# ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ

## ក្នុងឆមាសទី ១ ឆ្នាំ ១៩៧០

នៅឆមាសទី ១ គឺតាំងពីខែមករា ដល់ខែមិថុនា ឆ្នាំ ១៩៧០ ក្រុមទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើស យកឯកសារទំនៀមទម្លាប់ ដោយបើកការប្រឡងប្រជែង ២ មុខ គឺ:

១– អំពីព្រលឹង

២– របៀបផ្សំ, ល្បែង និង បច្ចេកទេសផ្សេង ៗ ក្នុងរបររបស់ខ្មែរ

*ដូច្នេះអស់លោក-អ្នកចេះដឹងទាំងឡាយ ជាស្ត្រី ជាបុរស ឬ ជាបព្វជិតក្តី ដែលស្ម័គ្រចិត្តប្រឡង, សូមសរសេរតែងអត្ថបទ តាមគោលបញ្ហាដូចរៀបរាប់ខាងមុខ* ឱ្យការណ៍ទៅក្រុមទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ យ៉ាងយូរបំផុត ត្រឹមថ្ងៃដាច់ខែ មិថុនា ឆ្នាំ ១៩៧០ ។

## ការប្រឡងប្រជែងនេះមានរង្វាន់ ៤ ថ្នាក់ :

លេខ ១ . . . . . . . ១.០០០រ០០

លេខ ២ . . . . . . . ៨០០រ០០

លេខ ៣ . . . . . . . ៦០០រ០០

លេខ ៤ . . . . . . . ៤០០រ០០

*បើអស់លោក-អ្នក ត្រូវការសរសេរអត្ថបទដូចខាងលើនេះទៅដាក់ប្រឡង សូមសរសេរលើសៀវភៅ កុំសរសេរលើក្រដាស តែ ១ សន្លឹក ឬ ២ សន្លឹកឡើយ ហើយសូមសរសេរនាម និង ទីលំនៅរបស់ខ្លួនឲ្យច្បាស់លាស់ លើក្រដាសមួយសន្លឹកដោយឡែក ដាក់ក្នុងស្រោមជាមួយនឹងអត្ថបទនោះ យកទៅឲ្យក្រុមជំនុំផ្ទាល់ខ្លួនក៏បាន ផ្ញើទៅតាមរយៈប្រៃសណីយ៍ក៏បាន ដោយកាន់សំបុត្រថា :*

ពុទ្ធសាសនបណ្ឌិត្យ

ការិយាល័យទំនៀមទម្លាប់

# ប្រឡងឆមាស ទី ១ ឆ្នាំ ១៩៧០

## ១– អំពីព្រលឹង

សូមអធិប្បាយអំពីព្រលឹងប្រចាំជីវិតមនុស្សយើង តើព្រលឹងនោះមានការៈយ៉ាងដូចម្ដេចខ្លះ ?

តាមធម្មតា ខ្មែរយើងតែងនិយាយថា ព្រលឹងមនុស្សមាន ១៩ ។ តើ ១៩ នោះ គឺអ្វីខ្លះ ? ខ្មែរតែងនិយាយទៀតថា ព្រលឹងធំ ព្រលឹងតូច តើព្រលឹងធំគឺអ្វីខ្លះ? ហេតុម្ដេចបានជាហៅព្រលឹងធំ ? ព្រលឹងតូចមានអ្វីខ្លះ ? ហេតុម្ដេចបានជាហៅព្រលឹងតូច ? តើព្រលឹងនីមួយៗ ខុសគ្នាដូចម្ដេចខ្លះ ? តើព្រលឹងនីមួយ ៗ មានការទាក់ទងគ្នាទៅលើរូបរាងកាយមនុស្សយ៉ាងណាខ្លះ ?

គេថាព្រលឹងៈចេញពីរូបពីអង្គមនុស្ស ឬថា ព្រលឹងត្រឡប់ចូលមកកាន់រូបកាន់អង្គមនុស្ស ហើយតើព្រលឹងដែលធ្វើដំណើរចេញ ឬ ចូលនោះ តាមទ្វារណា ? តាមបង្ហើយ ? តាមមាត់ ?

–តើគេអាចលួចខាបយកព្រលឹងមនុស្សដោយសិល្ប៍មកធ្វើទារុណកម្មបានឬទេ ? សូមអធិប្បាយអំពីរបៀបដែលគេធ្វើនោះផង ។

– តាមមតិខ្មែរយើង បុគ្គលដែលធ្វើមរណកាលទៅ តើព្រលឹងទៅឯណា ? ចុះដល់ពេលដែលកើតមកវិញ តើព្រលឹងទាំង ១៩ របស់

មនុស្សមួយដែលស្លាប់នោះ មកផ្គុំគ្នាចូលចាប់បដិសន្ធិវិញ ឬព្រលឹងដទៃមកពីនេះមួយ ពីនោះមួយ មកប្រមូលគ្នាគ្រប់ ១៩ មកកើតជាថ្មី? តើគេអាចដឹងថាព្រលឹងចូលមក ចាប់បដិសន្ធិជាថ្មីនៅពេលណាឬទេ ?

- គេធ្វើពិធីហៅព្រលឹងនៅពេលណាខ្លះ ? គេធ្វើដូចម្ដេចខ្លះ ? សូមអធិប្បាយឲ្យបានពិស្ដារ គេថាមានធ្វើពិធីហៅព្រលឹង នៅពេលធ្លង់ទន្លេ នៅពេលមានជំងឺ នៅពេលបំបួសនាគ ។ល។

តើពិធីដែលធ្វើនៅឱកាសផ្សេង ៗ នោះ ខុសគ្នាយ៉ាងណាខ្លះ ?

- ក្នុងពិធីហៅព្រលឹងនោះ បើមានន័យផ្សេង ៗ ប្រចាំកិច្ចនីមួយ ៗ ក៏សូមអធិប្បាយពន្យល់ក្រុមជំនុំឲ្យបានច្បាស់លាស់ផង ។ តើគេធ្វើពិធីជញ្ជាត់ព្រលឹង នៅកាលពេលដែលគេហៅព្រលឹង ឬយ៉ាងដូចម្ដេច? នៅពេលជញ្ជាត់ព្រលឹង គេអាចប្រើឧបករណ៍អ្វីក្រៅអំពីឈ្នាងបានឬទេ? ហេតុម្ដេចបានជាប្រើតែឈ្នាងប៉ុណ្ណោះ?

- តើរបស់អ្វីខ្លះ? ដែលមានឈ្មោះទាក់ទងនឹងព្រលឹង ដូចជាបាយព្រលឹង ទង់ព្រលឹង . . . . . សូមអធិប្បាយអំពីរបស់ដែលមានឈ្មោះទាក់ទងនឹងព្រលឹងនេះផង ។

- ក្រៅអំពីពិធីហៅព្រលឹងមនុស្ស គេមានធ្វើពិធីហៅព្រលឹងស្រូវ តើពិធីទាំងពីរបែបនេះខុសគ្នាយ៉ាងណាខ្លះ ? សូមអធិប្បាយឲ្យបានពិស្ដារផង ។

-តើសត្វមាន ព្រលឹងដូចជាមនុស្សយើងនិងស្រូវដែរឬទេ ? តើគេដែលធ្វើពិធីកម្ចាប់ព្រលឹងសត្វអ្វីទេ ? បើមានចំពោះសត្វណា សូមអធិប្បាយ ។

សូមជម្រាបអស់លោកអ្នកប្រឡងថា សេចក្តីតាំងប៉ុន្មានដែលក្រុមជំនុំជូនជាលំនាំខាងលើនេះ មិនមែនកំហាត់ថាលោកអ្នកប្រឡងត្រូវតែឆ្លើយតាមលំនាំនេះទេ គឺថាបើលោកអ្នកប្រឡងឆ្លើយតាមលំនាំនេះក៏បាន ឆ្លើយតែខណាដែលលោកចេះក៏បាន ឆ្លើយលើសពីសំនួរក៏បាន គ្មានទាស់ខុសអ្វីទេ ព្រោះក្រុមទំនៀមទម្លាប់ត្រូវការប្រមូលឯកសារបើមានគេចេះចាំទំនៀមបុរាណច្រើនក្នុងបញ្ហាដែលដាក់ជាប្រធាន ក្នុងការប្រឡងនេះ រឹតតែល្អណាស់ទៅទៀត ។

ម្យ៉ាងទៀត សូមកុំភ្លេចប្រាប់ថា ការដែលលោកសរសេរតែងនោះ តើលោកចេះដឹងមកពីណា ពីពេលណា នៅឱកាសណា ឃើញគេធ្វើ ឬពួកអ្នកណានិយាយប្រាប់ ។

## ២– អំពីរបៀបផ្សំ ល្បិច និង បច្ចេកទេសផ្សេង ៗ ក្នុងរបររបស់ខ្មែរ

សព្វថ្ងៃនេះ ប្រទេសកម្ពុជាចម្រើនលូតលាស់ហើសណាស់ ព្រោះហើយទំនៀមបុរាណក៏ត្រូវលេត ស្ទើរតែគ្រប់ជំហានដែរ ហេតុនេះហើយបានជាក្រុមទំនៀមទម្លាប់ សុំឲ្យអ្នកប្រឡងអធិប្បាយអំពី ល្បិច, អំពី

របៀបផ្សំ និងអំពីបច្ចេកទេសរបស់ខ្មែរយើង ព្រោះថាកាលដែលមិនទាន់មានរបៀបថ្មីចូលមក គឺខ្មែរយើងក៏ចេះធ្វើអ្វីៗ តាមរបៀបយើងអំពីដើមទៅដែរ ហើយមានប្រដាប់ប្រដាសម្រាប់ប្រើ ដើម្បីប្រកបកិច្ចការទាំងនោះ :

**ឧទាហរណ៍** ដូចឥឡូវនេះ គេប្រើស៊ីម៉ង់ត៍សម្រាប់ភ្ជាប់ឥដ្ឋ បុរាណក៏មានបាយអសម្រាប់ភ្ជាប់ឥដ្ឋដែរ។ តើបុរាណប្រើអ្វីសម្រាប់ភ្ជាប់ឥដ្ឋ របៀបធ្វើហោជាងព្រះវិហារដែលមានក្បាច់ផុសឲ្យមានពណ៌ ផ្សេងៗពីគ្នា ៗ សសរវិហារ ខ្លះមានពណ៌ខ្មៅ ហើយមានក្បាច់ទឹកមាស តើគេធ្វើដូចម្តេចខ្លះ ?

**ផ្នែកជាងទង** តើយកធាតុណាប៉ុន្មាន ធាតុណាប៉ុន្មាន ដើម្បីផ្សំឲ្យបានទៅជាទង់ហ្វី, ជាមាសបារាំង, ជាទង់ដែង, ជាខាត់, ជាមាសជម្ពូទេ, ជាមាសផ្កាកប្បាស, ... ។ល។

លោកអ្នកអាចនិយាយអំពីរបៀបធ្វើស្គរអារក្ស,-អំពីទំហំតាមទំនៀមអំពីក្បាច់ក្បូរលើស្គរនោះ, - អំពីរបៀបដែលគេត្រូវបូកហ្វូនៅលើផ្ទៃស្គរជ័យ, - អំពីរបៀបធ្វើស្នែងផ្លុំឲ្យមានសូរពីរោះ, - អំពីរបៀបធ្វើក្បាំង ធ្វើមួកក្រងស្លាបកំភេមសម្រាប់ពាក់ការ, - អំពីរបៀបធ្វើទឹកអប់ខ្មែរ ធ្វើក្រមួនលាបមាត់ ធ្វើទឹកខ្មេះ ធ្វើប្រាង្គ ធ្វើចេតិយ តើមានខ្នាតយ៉ាងម្តេចខ្លះ របៀបធ្វើផ្កាចន្ទន៍ផាក់មណ្ឌប ..... ។ល។

*របរបស់ខ្មែរយើងមានច្រើនឥតគណនាដែលលោកអ្នកអាចសរសេរបាន បើលោកអ្នកនឹករកបន្តិចទៅ ប៉ុន្តែសូមរើសយកតែរបៀបណាដែលជារបស់ខ្មែរ ហើយសូមបញ្ជាក់ដើមកំណើត និងប្រាប់ថាតើរបៀបនោះគេនៅធ្វើនៅឡើយ នៅស្រុកណា ខេត្តណា ឬថាគេឈប់ធ្វើអស់ទៅហើយ ។*

សេចក្ដីបញ្ជាក់— អត្ថបទដែលបេក្ខជនសរសេរផ្ញើមកប្រឡង ទោះជាប់ក្ដី មិនជាប់ក្ដី ត្រូវទុកជាសម្បត្តិរបស់ក្រសួងតទៅ មិនបង្វិលឲ្យសាមីខ្លួនវិញទេ ។

មានអស់លោក-អ្នក ជាច្រើនដែលមិនទាន់បានផ្ញើរូបថតទៅឱ្យក្រុមជំនុំ ហេតុនេះ សូមផ្ញើរូបថតសាមីខ្លួនលោក-អ្នក ដែលសរសេរអត្ថបទប្រឡងបីសន្លឹកមកជាមួយផង គឺរូបមួយកំណាត់ខ្លួនទំហំ ៤×៦ លើកលែងតែអស់លោកណាដែលបានផ្ញើពីលើកមុន ៗ រួចមកហើយ ។

ក្រុមទំនៀមទម្លាប់ខ្មែរ

# អនុស្សាវរីយ៍

# មហាសន្និបាតលើកទី ២៦ នៃមន្ត្រីសង្ឃ

# ថ្ងៃ ៨ មករា ១៩៧០

ដូចជាឆ្នាំមុនៗដែរ ព្រះសង្ឃរាជាគណៈ ឋានានុក្រម មន្ត្រីសង្ឃ បាន ប្រជុំធ្វើមហាសន្និបាត ក្រោមព្រះអធិបតីភាពនៃសម្ដេចព្រះសង្ឃនាយកតាមគណៈរៀងខ្លួន គឺខាងគណៈមហានិកាយ ប្រជុំនៅវត្តឧណ្ណាលោម គណៈធម្មយុត្តនៅវត្តបទុមវតីរាជវរារាម ។

នៅថ្ងៃទី ៨ មករា ១៩៧០ ជាទិវាបើកពិធីជាផ្លូវការ ដែលមន្ត្រីសង្ឃទាំងអស់ បានមកជួបប្រជុំគ្នា នៅក្នុងបរិវេណពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រោមអធិបតីភាពនៃអ្នកអង្គម្ចាស់ ឧភោត្តម - កាន្តុល ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ នៃសម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះប្រមុខរដ្ឋ ។

ពិធីនេះ បានប្រារព្ធធ្វើឡើងនៅម៉ោង ១៦ ដោយមានការជួបជុំព្រះសង្ឃរាជាគណៈ ឋានានុក្រម មេគណ អនុគណ ចៅអធិការជាមន្ត្រីសង្ឃទាំងអស់ , សមាជិកសភាទាំងពីរ សភាជិករាជរដ្ឋាភិបាល និងមន្ត្រីរាជការ អ្នកមុខអ្នកការ ច្រើនកុះករ រង់ចាំទទួលព្រះដំណើរនៃអ្នកអង្គម្ចាស់ព្រះរាជតំណាង ។ លុះស្ដេចយាងដល់ហើយ ព្រះអង្គទ្រង់

គោរពភ្លេងជាតិ   រួចយាងក្រាបបង្គំព្រះសង្ឃដែលមានសម្តេចព្រះសង្ឃ-នាយកទាំងពីរគណៈជាអធិបតី ហើយទ្រង់គង់សម្រួលឥរិយាបថបន្តិច, សហជីវិន ឌី.ឡុង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ និង សាសនសិក្សា ថ្លែងសុន្ទរកថាមួយ ។ បន្ទាប់មកទៀតព្រះឃោសធម្ម ប៉ុណ្ណ - សរម្ភាជ តំណាងព្រះសង្ឃ ថ្លែងសុន្ទរកថាមួយទៀត ។ ឆ្លើយតបនឹងសុន្ទរកថាទាំងពីរនេះ អ្នកអគ្គម្ចាស់ព្រះរាជតំ-ណាង ក៏ថ្លែងសុន្ទរកថាមួយដែរ ដែលយើងសូមចុះផ្សាយ សុន្ទរកថាទាំងបីនេះ បន្តបន្ទាប់គ្នាដូចតទៅ ៖

# សុន្ទរកថា

## រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុក ក្រសួងធម្មការ និង សាសនសិក្សាធិការ ថ្លែងក្នុងឱកាសអនុសំវច្ឆរៈលើកទី ២៦ នៅថ្ងៃទី ៨-១-៧០

---

សូមក្រាបបង្គំទូល អ្នកអង្គម្ចាស់ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃសម្ដេចព្រះមហាក្សត្រិយានី និង សម្ដេចព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ។

តាងនាមក្រសួងធម្មការ និង សាសនសិក្សាធិការ នាមព្រះសង្ឃព្រមទាំងពុទ្ធបរិស័ទ និង ក្នុងនាមផ្ទាល់ ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំថ្វាយនូវអំណរព្រះមហាករុណាធិគុណយ៉ាងក្រៃលែង និង ជ្រាលជ្រៅបំផុត ចំពោះព្រះវត្តមានដែលទ្រង់សព្វព្រះហឫទ័យយាងមកជាព្រះរាជតំណាង ជាព្រះអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីអនុសំវច្ឆរៈលើកទី ២៦ ដ៏មហោឡារិកនេះ ។

អនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃ ដែលប្រព្រឹត្តកល់ឆ្នាំមកបានចំនួន ២៦ លើកនេះ គឺជាព្រះកេរ្តិ៍ដ៏ថ្លៃថ្លា ដែលកើតពីព្រះប្រាជ្ញាញាណផ្ទាល់នៃព្រះករុណាព្រះបាទ នរោត្តម សីហនុ តាំងពីគ្រាដែលព្រះអង្គគ្រប់គ្រងរាជសម្បត្តិនៅឡើយ ។ ព្រះរាជយោបល់ដែលទ្រង់

ឧប្បត្តិវិធានការនេះឡើង ពិតជាបានហុចប្រយោជន៍ធំណាស់ក្នុងការប្រ-
តិបត្តិព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋយើង ព្រោះរាល់លើក
រាល់គ្រាដែលធ្វើសន្និបាតនេះ ព្រះសង្ឃទាំងអស់សុទ្ធសឹងតែបានប្ដូរយោ-
បល់ ហើយដោះស្រាយរកឃើញនូវមធ្យោបាយ ជាលទ្ធផលដ៏ប្រពៃៗ
សម្រាប់ពុទ្ធសាសនា និង ប្រយោជន៍ប្រទេសជាតិផង ។ ព្រះរាជចិន្តា
ជាប់ជំពាក់ក្នុងព្រះពុទ្ធសាសនារបស់ព្រះអង្គ បង្ហាញឲ្យឃើញច្បាស់នូវ
ព្រះរាជតម្រិះជ្រៅជ្រះក្នុងព្រះពុទ្ធសាសនា ដែលប្រកបដោយទឹកអម្រឹត
ប្រោះព្រំទៅលើមនុស្សទូទៅ គោលគឺ សុខ សន្តិភាព និង អហឹង្សា ។
ព្រះពុទ្ធវចនៈ បានសាបព្រោះគោលគំនិតនេះ មកក្នុងសន្តានចិត្តខ្មែរយើង
តាំងពីសម័យអង្គរ ដែលញុំាងវឌ្ឍនភាព សម័យនោះឲ្យបានថ្កើងរុងរឿង
ក្រៃលែងដែលខ្មែរមានធម៌សាមគ្គី បានរួបរួមនៅជុំវិញព្រះរាជបល្ល័ង្កគោរព
តាមព្រះមហាក្សត្រ និង តាមព្រះពុទ្ធោវាទ បានខិតខំធ្វើការឲ្យបានសុខ-
ចម្រើន រក្សាការពារទឹកដីកសាងប្រាសាទអង្គរ និង ប្រាសាទបុរាណដ៏ល្អ
អស្ចារ្យល្បីល្បាញ ទុករហូតមកដល់សព្វថ្ងៃ ព្រមទាំងមានកេរ្តិ៍ដំណែល
វត្ត ព្រះវិហារ ព្រះពុទ្ធរូបល្អៗ រហូតមកដល់សម័យឧដុង្គ ទោះបីមាន
បរទេសមកប្រាថ្នាចង់បំផ្លិចបំផ្លាញបំបែកបំបាក់យ៉ាងណាក្តី ក៏ព្រះពុទ្ធសាសនា
នៅតែរីកសាយសព្វក្នុងព្រះរាជាណាចក្រ ដោយសារព្រះមហាក្សត្របាន
ឧបត្ថម្ភទ្រទ្រង់រហូតមកដល់សម័យសង្គមរាស្ត្រនិយម ដែលសម្តេចឪព្រះ

អង្គទ្រង់ព្រះតម្រិះយកមធ្យោបាយមកផ្តួចផ្តើមទៀតជាបលនាជាតិ គឺសង្គមនិយមព្រះពុទ្ធសាសនា ឲ្យជាតិមានសាមគ្គីធម៌ កាន់នយោបាយអព្យាក្រឹត្យ អ្នកជាតិនិយម និងព្យាយាមខំប្រឹងកសាងជាតិតាមគំនិតជួយខ្លួនដោយខ្លួនឯង ឲ្យមានវឌ្ឍនភាពគ្រប់វិស័យ ក្នុងព្រះរាជាណាចក្រដែលពិភពលោកគោរពកោតសរសើរប្រទេសយើងជាជាកោះសន្តិភាព ប្រកបដោយសាមគ្គី ។

សម្តេចឪ ជាព្រះអគ្គមគ្គុទ្ទេសក៏ដ៏ធំឆ្នើមនៃយើង ព្រះអង្គបានលើកបញ្ជាក់ឲ្យយើងកាន់ដោយខ្ជាប់ខ្ជួនតាមគោលការណ៍ជាតិទាំងបញ្ចសីលគឺ: អ្នកជាតិនិយម, ឯករាជ្យនិយម, អព្យាក្រឹតនិយម, បូរណភាពទឹកដីនិយម, សង្គមនិយមព្រះពុទ្ធសាសនា

តទៅនេះ សូមក្រាបបង្គំទូលថ្វាយកិច្ចការដោយសង្ខេបគឺ:

សព្វថ្ងៃ ប្រទេសយើងមានវត្តទាំងពីរគណៈចំនួន ៣.៣៦៩ វត្តនិងមានព្រះសង្ឃចំនួន ៦៥.០៦២ អង្គ ដោយប្រជាជាតិខ្មែរសុទ្ធសឹងជាពុទ្ធបរិស័ទ ។ យើងមានវត្តអាកមចំនួន ៥០០ វត្ត ព្រះសង្ឃខ្មែរចំនួន ២៥.០៤០ អង្គ ព្រមទាំងពុទ្ធបរិស័ទខ្មែរប្រមាណជិត បួនលាននាក់ នៅក្នុង ១៤ ខេត្ត នៅកម្ពុជាក្រោម ដែលកំពុងការពាររក្សាកេរ្តិ៍តំណែលវប្បធម៌ អារ្យធម៌ខ្មែរ ដោយអង់អាច ប្រកបដោយសន្តិវិធីតាមច្បាប់និងតាមគន្លងធម៌ នូវសេចក្តីសុចរិត យុត្តិធម៌ ព្រមទាំងតាមតារសិទ្ធិរបស់

ខ្មែរយើងអ្នកកាន់ព្រះពុទ្ធសាសនា ហើយដែលព្រះសង្ឃនិងប្រជាពលរដ្ឋទាំងអស់ ជាពុទ្ធបរិស័ទនៅប្រទេសកម្ពុជាមួយរយភាគរយ ក៏បានគាំទ្រយ៉ាងពេញទំហឹងជានិច្ច ។

ទូលព្រះបង្គំជាខ្ញុំ សូមទ្រង់ព្រះមេត្តាប្រោស ដើម្បីបញ្ជាក់សេចក្តីយ៉ាងខ្ជីនូវព្រះរាជបន្ទូលដ៏ថ្លៃថ្លា នៃសម្តេចឪជាអម្ចាស់ អំពីការកសាងព្រះវិហារ ដោយសុំឲ្យធ្វើតែ ១ ដាន់ តូចល្មមសមរម្យ ហើយវត្តនីមួយៗ ដែលសន្មតថាក្រអឺតរើងបាន គឺនៅត្រង់ចេះរៀបចំតាក់តែងឲ្យស្អាតមានអនាម័យ មានសួនច្បារ រុក្ខជាតិលំអផង ។

ឯសមិទ្ធិសំខាន់ៗ ខាងវិស័យពុទ្ធចក្រនោះគឺ :

១- អំពីផ្នែកសាសនសិក្សាធិការ កំពុងតែបានសេចក្តីចម្រើនទាំងវិបស្សនាធុរៈ ទាំងគន្ថធុរៈ ក្រោមព្រះកិច្ចដឹកនាំនៃសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ។ សព្វថ្ងៃនេះមានដូចតទៅ:

ក- ពុទ្ធិកបឋមសិក្សា.– មានថ្នាក់រៀនចំនួន២៩១ និងមានសមណៈ-និស្សិត ៩.៥២៥ រូប ។

ខ- ពុទ្ធិកមធ្យមសិក្សា.– មានពុទ្ធិកវិទ្យាល័យពីរ មួយនៅភ្នំពេញនិងមួយទៀតនៅបាត់ដំបង មានថ្នាក់ចំនួន ២៤ និងមានសមណសិស្សចំនួន ១.០៥០ រូប ។ ក្នុងឆ្នាំកន្លងទៅនេះ បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាចំនួន ២៦៣ រូប ក្នុងបណ្តាបេក្ខសមណៈ ២៨៦ រូប ។

គ- ពុទ្ធិកឧត្តមសិក្សានៅភ្នំពេញ.-- នៅឆ្នាំនេះមានសមណនិស្សិត ១៧៦ រូប គឺនៅបឋមភូមិ ១២៩ រូប និង ទុតិយភូមិ ៤៧ រូប ដែលសិក្សាបានផ្នែកភាសាសំស្ក្រឹត; ភាសាទាប្រៀបធៀប ប្រវត្តិភាសា និង ទស្សនវិជ្ជា ។

២- ផ្នែកស្រាវជ្រាវ និងបោះពុម្ពផ្សាយ.-- ផ្នែកនេះក៏មានការប្រព្រឹត្តទៅប្រកបដោយវឌ្ឍនភាពជាលំដាប់ ។ រៀងរាល់ថ្ងៃតែងមានអ្នកប្រាជ្ញ អ្នកស្រាវជ្រាវ អ្នកសិក្សាជាតិបរទេសនិងជនរួមជាតិជាច្រើននាក់ បានចូលទាក់ទងជាមួយនឹងមជ្ឈមណ្ឌលវប្បធម៌យើង ហៅថា "វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ" ដែលកើតឡើងដំណាលនឹងសាលាបាលីជាន់ខ្ពស់ និងក្រុមជំនុំប្រែព្រះត្រៃបិដកតាមព្រះរាជតម្រិះពេញយល់នៃព្រះករុណា ព្រះបាទព្រះ ស៊ីសុវត្ថិ មុនីវង្ស និង ក្រោមព្រះរាជាធិបតីភាព នៃសម្តេចព្រះវរចក្រណារិទ្ធិ ឆរោត្តមសុជារស ដែលទ្រង់សព្វព្រះរាជហឫទ័យយ៉ាងមុតមាំចំពោះវប្បធម៌អក្សរសាស្ត្រជាតិ, ទ្រង់ផ្តើមកសាងឡើងកាលពី គ.ស ១៩២៦ ហើយដែលជាតំណមក ក៏បានទទួលព្រះរាជូបត្ថម្ភដ៏មាំមួន អំពីព្រះបាទសម្តេចព្រះមហាកាញ្ចនកោដ្ឋ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និង សម្តេចឪជាអម្ចាស់ តាំងពីគ្រាដែលព្រះអង្គទ្រង់គ្រប់គ្រងរាជសម្បត្តិរហូតមកដល់បច្ចុប្បន្ន ជាក់ស្តែង គឺព្រះអង្គបាន ប្រោសព្រះរាជទាន ប្រគេនសម្តេចព្រះមហាសុមេធាធិបតី តាំងពីនៅ

ជាសមណសក្តិជាសម្តេចព្រះពោធិវង្សនៅឡើយ ដើម្បីរុះរើអគារចាស់ ហើយកសាងសំណង់នេះឡើងជាថ្មី ហើយដែលឥឡូវនេះកំពុងតែតាក់-តែងបង្ហើយដោយមានថវិកាស្តួចស្តើង និងដោយត្បិតត្បៀតផង ដែលសម្តេចព្រះសង្ឃនាយកជាសាកលវិទ្យាធិការ និងអគ្គាធិការ បានដឹកនាំការស្ថាបនានេះផ្ទាល់ដោយមធ្យ័តមាំមួនជាទីបំផុត ។

វិជ្ជាស្ថាននេះ ទៅថ្ងៃមុខនឹងតែមានកិត្តិយសបំពេញមុខការខ្លួនបានចម្រើនថែមឡើងទៀត ដោយសារព្រះរាជហឫទ័យប្រោសប្រណីឲ្យមានទីស្ថានដ៏ល្អធេងធាយ ។ សកម្មភាពនានាក្នុងអគារនេះគឺមានបណ្ណាល័យដ៏ធំមួយ, មានក្រុមជំនុំព្រះត្រៃបិដក, ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ និងសារមន្ទីរនៃវត្ថុសិល្បៈខាងពុទ្ធសាសនៈមួយជួយបម្រើកិច្ចការពិនិត្យស្រាវជ្រាវនូវក្បួនខ្នាត ហើយផ្ទៀងផ្ទាត់ឲ្យត្រឹមត្រូវ និងបោះពុម្ពផ្សាយឯកសារខ្លះទៅសម្រាប់ការចេះដឹងនៃសាធារណជន និងដាក់ជាវជូនតាមសេចក្តីត្រូវការ ។ ដូចជាក្នុងឆ្នាំកន្លងទៅនេះសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូងនិងសម្តេចព្រះប្រមុខរដ្ឋជាអម្ចាស់ ទ្រង់ព្រះតម្រិះឲ្យចាត់ចែងធ្វើពិធីសម្ពោធព្រះត្រៃបិដកជាមហោឡារិកពេញប្រទេសកម្ពុជាទាំងមូល ហើយដែលជាមហាជោគជ័យរបស់ខ្មែរយ៉ាងឧត្តមក្នុងព្រះពុទ្ធសាសនា ។ ប្រាក់ចំណូលខាងបោះពុម្ពផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យក្នុងឆ្នាំ ១៩៦៩ កន្លងទៅនេះ បានជិត ១៦ លានរៀល ។ ក្នុងឆ្នាំនេះ វិជ្ជាស្ថានបានបោះពុម្ព

សៀវភៅនានាដល់ទៅ ១៣៤.៤៤៩ ក្បាល ហើយផ្សាយជូនសាធារណជនទិញពុទ្ធបរិស័ទមានចំនួនដល់ទៅ ១៧៨.៨៧៧ ក្បាល ។

ទូលព្រះបង្គំ សូមរំលឹកព្រះគុណដ៏ធំ របស់សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ " ជួន ណាត " ហើយសូមថ្វាយព្រះរាជកុសលចំពោះព្រះវិញ្ញាណក្ខន្ធ ដែលកាលព្រះអង្គគង់ព្រះជន្មនៅឡើយ ទ្រង់បានយកព្រះរាជហឫទ័យទុកដាក់ ខិតខំប្រទានឱវាទបង្ហាត់បង្រៀន រៀបចំគម្ពីរក្បួនខាតមានគម្ពីរព្រះត្រៃបិដក និងអក្សរសាស្ត្រជាតិឲ្យបានលទ្ធផលដ៏ប្រសើរព្រមទាំងថ្លែងអំណរព្រះគុណ សម្តេចព្រះសង្ឃនាយក ព្រះសង្ឃទាំងអស់ និង សាស្ត្រាចារ្យ ពុទ្ធបរិស័ទ ដែលបានបំពេញកិច្ចការជាប្រយោជន៍ចំពោះព្រះពុទ្ធសាសនា និង ជាតិនេះ ។

ម្យ៉ាងទៀត ទូលព្រះបង្គំ ក៏មានកតញ្ញូតាយ៉ាងគោរព ចំពោះសម្តេចព្រះសង្ឃនាយក គណៈធម្មយុត្តិកនិកាយ ដែលទោះបីព្រះអង្គមានព្រះជរាយណាស់ហើយក៏ដោយ ក៏ព្រះអង្គបានខិតខំប្រោសប្រទានព្រះឱវាទចំពោះព្រះសង្ឃ ពុទ្ធបរិស័ទ ឲ្យមានសាមគ្គីភាពជានិច្ច ។

សូមទ្រង់មេត្តាប្រោស

ទូលព្រះបង្គំជាខ្ញុំ សូមប្រោសព្រះបរមរាជកាស ដើម្បីថ្លែងក្នុងនាមនៃរាជរដ្ឋាភិបាលនូវអំណរព្រះគុណ និង កតញ្ញូតាដ៏ជ្រាលជ្រៅបំផុត

ចំពោះសម្ដេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ព្រមទាំងព្រះរាជាគណៈ ឋានានុក្រម ព្រះមេគណ អនុគណ និង ចៅអធិការគ្រប់ព្រះអង្គ ដែលបានជួយជ្រោមជ្រែងរាជរដ្ឋាភិបាល ក្នុងការចម្រើនព្រះពុទ្ធសាសនា និងការកសាងជាតិគ្រប់វិស័យ ជាពិសេសវិស័យវប្បធម៌ សង្គមកិច្ច និងសេដ្ឋកិច្ច មានការកសាងសាលាពុទ្ធិកសិក្សា បណ្ណាល័យ សាលារៀន មន្ទីរពេទ្យ ធ្វើថ្នល់ ស្ពាន ជីកអណ្ដូងទឹក ជីកស្រះ ទំនប់ទឹក ប្រឡាយទឹក ហើយនៅឆ្នាំ ១៩៦៩ នេះទៀត ជាពិសេសតាមព្រះរាជបញ្ជាដាស់តឿននោះ ព្រះសង្ឃដោយរួបរួមជាមួយរាជការ បានដឹកនាំប្រជាពលរដ្ឋ ឲ្យខិតខំធ្វើនយោបាយទឹក បានលទ្ធផលជាអតិបរមាលើសពីឆ្នាំមុនៗ ។ នេះជាភស្ដុតាងបង្ហាញច្បាស់នូវសាមគ្គីធម៌ ជុំវិញព្រះរាជបល្ល័ង្ក ទាំងព្រះសង្ឃទាំងគ្រហស្ថ ក្នុងការកសាងជាតិ ។ បន្ទាប់ពីនយោបាយទឹក ដែលជាមូលដ្ឋានកសិកម្មនិងសេដ្ឋកិច្ចជាតិ ដែលត្រូវតែខិតខំធ្វើក្នុងឆ្នាំនេះ និងតទៅមុខទៀតទ្វេឡើង សម្ដេចឪទ្រង់សព្វព្រះរាជហឫទ័យ អំពាវនាវចំពោះព្រះសង្ឃដើម្បីជួយអប់រំប្រជាពលរដ្ឋខាងចលនាអក្ខរកម្មឲ្យបានសម្រេចលទ្ធផលប្រសើរ ចេះអក្សរគ្រប់គ្នា ១០០ ភាគរយឡើង ដើម្បីធ្វើយ៉ាងណាឲ្យអស់អនក្ខរជន អំពីគ្រប់ជនបទចុងកាត់មាត់ញក ទុកជាសក្ខីភាពនៃតម្លៃសិក្សាធិការ សមនឹងប្រទេសយើងទើបនឹងបានទទួលរង្វាន់អន្តរជាតិលេខ ១ គឺមេដាយមាសនៃអង្គការ

អ៊ុយណេស្កូ ក្នុងឆ្នាំ ១៩៦៩ ។ ទៅឆ្នាំ ១៩៧០ នេះ ប្រទេសយើងនឹងមានកិត្តិយសទទួលទូរការចាត់ថែងរង្វាន់អន្តរជាតិខាងអក្ខរកម្មជាលើកទី ២ ។

សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និង សម្តេចព្រះប្រមុខរដ្ឋ និងរាជរដ្ឋាភិបាល មានសេចក្តីជឿជាក់ថាព្រះសង្ឃជាគំរូ ជាទីពឹងពំនាក់ ជាគ្រូ ជាអ្នកដឹកនាំប្រជាពលរដ្ឋ ដើម្បីទៅកាន់សេចក្តីសុខសេចក្តីចម្រើនជូនប្រទេសជាតិ ។ សូមព្រះពុទ្ធសាសនា ដែលមានព្រះវិហារវត្ត និង ព្រះសង្ឃជាតំណាង បានថ្កុំថ្កើងរុងរឿងមានជោគជ័យ ក្នុងគោលសង្គមនិយមព្រះពុទ្ធសាសនាដរាបរៀងទៅ ។

ជាទីអវសាន ទូលព្រះបង្គំជាខ្ញុំគ្នានាមពុទ្ធបរិស័ទទាំងអស់ សូមបួងសួងចំពោះគុណានុភាពនៃព្រះរតនត្រ័យ និងវត្ថុសក្តិសិទ្ធិទាំងអស់ក្នុងលោក មានព្រះវិញ្ញាណក្ខន្ធនៃព្រះអតីតមហាក្សត្រគ្រប់ព្រះអង្គ មានព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម ព្រះសុវណ្ណកោដ ជាដើម សូមជួយបីបាច់ថែរក្សាអង្គសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខរដ្ឋ សូមបានប្រកបដោយព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ព្រមទាំងមានព្រះសុខភាព និងព្រះកាយ-

ពលបរិបូណ៌ ដើម្បីបានជាម្លប់ត្រជាក់នៃព្រះសង្ឃ ពុទ្ធបរិស័ទ ប្រជាពលរដ្ឋ ជាកូនចៅព្រះអង្គជានិច្ចនិរន្តរ៍ ។

ដោយតេជានុភាពនិងកុសលសកស ដែលកើតឡើងអំពីពិធីបុណ្យអនុសំវច្ឆរៈលើកទី ២៦ នេះ សូមសម្តេចឪជាអង្គម្ចាស់ ដែលទ្រង់បានស្តេចយាងទៅព្យាបាលព្រះរោគនៅប្រទេសបារាំង ព្រះអង្គឆាប់បានជាសះស្បើយ មានព្រះកាយពលព្រះបរមសុខភាពបរិបូណ៌ ដើម្បីនឹងបានយាងត្រឡប់មកគ្រប់គ្រងកូនចៅ ព្រះសង្ឃ ប្រជាពលរដ្ឋគ្រប់ៗគ្នា ជាកេរយោភាពតទៅ ។

# សុន្ទរកថា

## ព្រះឃោសធម្ម ប៊ុណ្ណា - សម្ភាជ តំណាងព្រះសង្ឃ

---

សូមថ្វាយព្រះពរចំពោះអ្នកអង្គម្ចាស់ ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ នៃ សម្តេចព្រះមហាក្សត្រិយានី និងសម្តេចព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ។

សម្តេចព្រះមហាសុមេធាធិបតីព្រះសង្ឃនាយក បានតម្រូវរូបអាត្មាភាព ឲ្យជាតំណាងសង្ឃ ដែលបាននិមន្តមកជួបជុំក្នុងទីចំពោះព្រះភ័ក្ត្រនាមហាសន្និបាតនេះ ឲ្យអាត្មាភាពថ្វាយសេចក្តីបន្តអំពីសុន្ទរកថានៃលោកអ្នកឧកញ៉ា រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ និងសាសនសិក្សាធិការ ក្នុងនាមនៃមន្ត្រីសង្ឃគ្រប់ឋានៈ ក្នុងព្រះរាជធានីភ្នំពេញ ក្នុងខេត្ត និងអនុខេត្តដែលឋិតនៅក្រោមឱវាទ នៃសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ អាត្មាភាពសូមថ្វាយព្រះពរ ថ្វាយនូវអំណរចំពោះព្រះមហាករុណាធិគុណដ៏ខ្ពង់ខ្ពស់បំផុត នៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតព្រះមាតាជាតិ និងសម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាឯករាជ្យជាតិ ដែលទ្រង់សព្វព្រះរាជហឫទ័យ ព្រោសព្រះរាជទាន ព្រះបរមរាជូបត្ថម្ភ ចំពោះពិធីអនុស្សាវរីយមហាសន្និបាត នៃមន្ត្រីសង្ឃ

តាំងពីឆ្នាំទី មួយ រហូតដល់ឆ្នាំទី ២៦ នេះ ។

សូមថ្វាយព្រះពរ !

អម្បាញមិញនេះ លោកអ្នកឧកញ៉ា រដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសេចក្ដីថ្វាយពត៌មាន អំពីមហាសន្និបាតនេះ ដែលមានសេចក្ដីទាក់ទងដល់គុណសម្បត្តិ នៃព្រះពុទ្ធសាសនា ដល់គណៈសង្ឃ និងដល់ប្រទេសកម្ពុជាផង ។ ព្រះសង្ឃទាំងអស់ បានដឹងច្បាស់លាស់ណាស់ថា ដោយសារតែព្រះបរមពុទ្ធបតម្ភជានិច្ចនិរន្តរ៍ នៃសម្ដេចព្រះមហាក្សត្រិយានី និង សម្ដេចព្រះប្រមុខរដ្ឋជាអម្ចាស់ ការសិក្សាផ្នែកខាងព្រះពុទ្ធសាសនា ក៏កាន់តែមានការចម្រើនលូតលាស់ ឡើងជាលំដាប់ ។ កិច្ចការដទៃទៀត មានការគ្រប់គ្រងគណៈសង្ឃជាដើម ក្នុងព្រះរាជអាណាចក្រទាំងមូល ក៏កាន់តែមានរបៀបរៀបរយ ប្រកបដោយសុខសន្តិភាពជាលំដាប់ដរាបមកនេះ ក៏អាស្រ័យនឹងការប្រជុំជាអនុសំវច្ឆរមហាសន្និបាត ក្រោមព្រះបរមពុទ្ធបតម្ភដែរ ។ នេះជាព្រះមហាករុណាធិគុណដ៏ខ្ពង់ខ្ពស់ ឥតមានព្រះសង្ឃរូបណាមួយបំភ្លេចបានឡើយ ។

នៅទីបញ្ចប់នេះ អាត្មាភាពជាតំណាងមន្ត្រីសង្ឃ សូមលើកយកកុសលបុញ្ញកោដ្ឋិដែលសង្ឃគ្រប់វត្ត បានប្រព្រឹត្តប្រតិបត្តិ ក្នុងរយៈកាលមួយឆ្នាំ កន្លងមកហើយនេះ ជាព្រះរាជកុសល ថ្វាយ :

សូមសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត ទ្រង់ប្រកបដោយព្រះពរបវរសួស្តីជោគជ័យមហាមង្គល វិបុលសុខ គ្រប់ប្រការ ។

សូមសម្តេចព្រះប្រមុខរដ្ឋ ជាអម្ចាស់ ទ្រង់ឆាប់បានជាស្រឡះពាកព្រះអាការរោគ មានព្រះកាយពល និង ព្រះបរមសុខភាព ដ៏ល្អបរិបូណ៌ឡើងវិញ ។

សូមសម្តេចជាអម្ចាស់ ទាំងពីរព្រះអង្គ ទ្រង់ប្រកបដោយព្រះសិរីសុខគ្រប់ប្រការ មានព្រះជន្មាយុយឺនយូរ អស់កាលជាអង្វែងវែងឆ្ងាយ ។

សូមថ្វាយព្រះពរ

មួយទៀត សូមថ្វាយ សូមជូន សព្ទសាធុការពរ ចំពោះទ្រង់ ចំពោះអស់លោកជាសមាជិក នៃព្រះរាជរដ្ឋាភិបាល និង អស់លោកមន្ត្រីធំតូចគ្រប់ថ្នាក់គ្រប់ក្រុម ។

សូមទ្រង់ និង អស់លោកបានប្រកបដោយសុភមង្គលគ្រប់យ៉ាងសព្វកាលវេលា ទិវា រាត្រី ។

សូមកម្ពុជរដ្ឋ ឯករាជ្យ អព្យាក្រឹត្យ ស្ថិតនៅជាស្ថាពរ ប្រកបដោយសេចក្តីចម្រុងចម្រើនជានិច្ចនិរន្តរ៍ ។

សូមចម្រើនពរ !

# សុន្ទរកថានៃអ្នកអង្គម្ចាស់
## នរោត្តម-ភន្ទុល ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃសម្តេច
## ព្រះមហាក្សត្រិយានី និង សម្តេចព្រះប្រមុខរដ្ឋ

---

សូមថ្វាយបង្គំ ចំពោះសម្តេចព្រះសង្ឃនាយក ទាំងពីរព្រះអង្គ

សូមថ្វាយបង្គំ ចំពោះសម្តេចព្រះធម្មវិន័យាធិបតី ព្រះរាជាគណៈ ព្រះបាទានុក្រម-ព្រះមេគណ-អនុគណ-ព្រះចៅអធិការ និង ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ដែលគង់ក្នុងមហាសន្និបាតជាឧឡារិកនេះ

សូមជម្រាប ឯកឧត្តម សហជីវិន សហជីវិនី និង ពុទ្ធបរិស័ទ ទាំងអស់ ។

ខ្ញុំព្រះករុណា-ខ្ញុំ ក្នុងឋានៈជាព្រះរាជតំណាង សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និង សម្តេចព្រះប្រមុខរដ្ឋជាអម្ចាស់ សូមសម្តែងជាបឋម នូវគារវៈ កតញ្ញូតា ចំពោះសម្តេចជាអម្ចាស់ ព្រះតេជព្រះគុណគ្រប់ព្រះអង្គ ដែលបាននិមន្តមករួមប្រជុំក្នុងពិធីអនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃក្នុងឱកាសនេះ ។ ពិធីដ៏មហាឧឡារិកនេះ មិនគ្រាន់តែជាប្រពៃណីមួយដ៏វិសេស ដែលជាព្រះកេរ្តិ៍មរតក ដែលមិនអាចបំភ្លេចបាន នៃព្រះបាទសម្តេច ព្រះសីហនុវរ្ម័ន កាលព្រះអង្គគង់ក្នុងព្រះសិរីរាជសម្បត្តិនៅឡើយ ហើយដែលព្រះអង្គតែងតែ

ជួយឧបត្ថម្ភ តាមព្រះរាជសទ្ធាដ៏មោះមុត ក្នុងផ្លូវព្រះពុទ្ធសាសនានេះ កាន់តែមានគតិតខ្ពស់ឡើងជាលំដាប់ ព្រមទាំងព្រះអង្គ បានបញ្ចូលព្រះពុទ្ធសាសនាទៅក្នុងនយោបាយជាតិថែមទៀត គឺ ព្រះរាជនយោបាយសង្គមនិយមព្រះពុទ្ធសាសនា ដូចសម្តេចជាអម្ចាស់ និង ព្រះករុណាម្ចាស់គ្រប់ព្រះអង្គ ទ្រង់បានជ្រាបសព្វគ្រប់ស្រាប់ ហើយជាពិសេស ឱកាសនេះ គឺជាឱកាសដ៏ល្អមួយ ដើម្បីជួបជុំព្រះសង្ឃ ដែលនិមន្តមកអំពីគ្រប់វត្តអារាម នៃព្រះរាជាណាចក្រ ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ដើម្បីពិភាក្សារកសេចក្តីចម្រើនក្នុងផ្លូវព្រះពុទ្ធសាសនា និង វឌ្ឍនភាពនៃប្រទេសកម្ពុជាទាំងមូល តាមគោលត្រៃបាវចនា គឺ ជាតិ សាសនា ព្រះរាជបល្ល័ង្ក ដែលជាគ្រឹះដ៏មាំបំផុត សម្រាប់ជាតិខ្មែរ ដូចដែលសហជីវិនវឌ្ឍលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ ទើបបានថ្លែងសុន្ទរកថារួចហើយនេះថា ប្រទេសកម្ពុជាយើងក្រោមព្រះកិច្ចដឹកនាំនៃសម្តេចព្រះប្រមុខរដ្ឋ ជាព្រះប្រធាននៃសង្គមរាស្ត្រនិយម និងក្រោមការឧបត្ថម្ភនៃសម្តេចទាំងពីរព្រះអង្គ និងព្រះករុណាគ្រប់ព្រះអង្គ បានចម្រើនលូតលាស់គ្រប់វិស័យ ក្នុងតម្រាយផ្លូវសង្គមនិយមព្រះពុទ្ធសាសនា ។

ខ្ញុំព្រះករុណា-ខ្ញុំ សូមថ្លែងនូវព្រះមហាករុណាធិគុណចំពោះសម្តេច

អំណរព្រះគុណចំពោះព្រះករុណាគ្រប់ព្រះអង្គ ដែលបានខិតខំផ្សាយនូវព្រះមេត្តាធម៌ ឱ្យប្រជាពលរដ្ឋ ពុទ្ធបរិស័ទ មានសាមគ្គីភាពរួបរួមគ្នាជាធ្លុងមួយក្នុងចលនាសង្គមរាស្ត្រនិយម ក្នុងគោលបញ្ចសីលាជាតិ គឺជាតិនិយម, ឯករាជ្យនិយម; បូរណភាពនៃដែនដីនិយម,, អព្យាក្រិត្យនិយម និងសង្គមនិយមព្រះពុទ្ធសាសនា ដែលមានសម្តេចព្រះប្រមុខរដ្ឋទ្រង់គង់ជាព្រះអគ្គមគ្គុទ្ទេសក៍ ។

ជាទីអវសាន ខ្ញុំព្រះករុណា-ខ្ញុំ សូមប្រសិទ្ធពរ សុំគុណបុណ្យព្រះរតនត្រ័យ ជួយអភិបាលរក្សា សម្តេចទាំងពីរព្រះអង្គ សម្តេចព្រះធម្មវង្សាធិបតី ព្រះតេជៈព្រះគុណគ្រប់ព្រះអង្គ សូមបានប្រកបតែនូវព្រះបរមសុខភាព ព្រះកាយពលមាំមួន មានព្រះទីឃាយុ ព្រះជន្មយឺនយូរ ដើម្បីបានជាម្លប់នៃពុទ្ធបរិស័ទ និង ប្រជាពលរដ្ឋគ្រប់ៗរូប ។

ទីបំផុតនេះ ខ្ញុំព្រះករុណា-ខ្ញុំ មានសេចក្តីក្រៀមក្រំក្នុងដួងចិត្តឥតឧបមា ចំពោះការបាត់បង់អ្នកប្រាជ្ញជាតិដ៏ជាទីសោកស្តាយមួយព្រះអង្គ គឺ សម្តេចព្រះសង្ឃរាជព្រះនាម ជួន-ណាត ដែលព្រះអង្គទើបនឹងសោយព្រះទីវង្គត ក្នុងពេលកន្លងមកនេះ ។ ទៀតឱកាសដ៏ប្រសើរនេះ ខ្ញុំព្រះករុណា-ខ្ញុំ សូមឧទ្ទិសកុសលកសី ដែលកើតឡើងដោយសារមហាសន្និបាតនៃមន្ត្រីសង្ឃតាមគន្លងព្រះពុទ្ធសាសនានាថ្ងៃនេះ ថ្វាយ

បំពោះព្រះវិញ្ញាណក្ខន្ធព្រះអង្គ សូមព្រះអង្គស្តេចយាងទៅកាន់សុគតិភព អស់កាលជានិរន្តរ៍តរៀងទៅ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំព្រះករុណា-ខ្ញុំ សូមប្រកាសបើក អនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃលើកទី ២៦ នេះ ។

សូមអរព្រះគុណ សូមអរគុណ